ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

Extraordinary Chambers in the Courts of Cambodia

Chambres Extraordinaires au sein des Tribunaux Cambodgiens

---

អង្គជំនុំជម្រះសាលាដំបូង

Trial Chamber

Chambre de Premiere instance

# កំណត់ហេតុជាលាយលក្ខណ៍អក្សរ
# នៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះក្តី "ឌុច"
# សាធារណៈ

សំណុំរឿងលេខ ០០១/១៨-០៧-២០០៧-អវតក/អជសដ

**ថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០០៩**

**សវនាការលើកទី៤៦**

**ចៅក្រមសាលាដំបូង៖**

លោក និល ណុន ជាប្រធាន

លោកស្រី ស៊ីលយ៉ា ខាតរ៉ាយថ៍

*(Judge Silvia Carwright)*

លោក យ៉ា សុខន

លោក ហ្សង់ម៉ាក ឡាវែន៍

*(Judge Jean-Marc Lavegne)*

លោក ធូ មណី

លោក យូរ ឧត្តរា

លោកស្រី ក្លូឌា ហ្វេនស៍ *(Judge Claudia Fenz)*

**ក្រឡាបញ្ជីសាលាដំបូង៖**

លោក ឌុច ផារី

លោក ម៉ាតូ គ្រីស្ពារ

*(Mr. Matteo Crippa)*

លោកស្រី សែ កុលវុឌ្ឍី

កញ្ញា ណាថាក់ វិចស៊ែល

*(Ms. Natacha Wexels-Riser)*

លោក អាឡាញ ប្រៃអត (Aline BRIOT)

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក តាន់ សេណារ៉ុង

លោក សេង ប៊ុនឃាង

លោក វិលៀម ស្មីត *(Mr. William SMITH)*

លោក ពេជ្រ សម្បត្តិ

លោក ហ្សាឆិរី ឡាំពែល *(Mr.Zachery LAMPEL)*

**ជនជាប់ចោទ៖**

លោក កាំង ហ្គេកអ៊ាវ

**មេធាវីការពារជនជាប់ចោទ៖**

លោក ការ សាវុត្ថ

លោក ហ្វ្រង់ស្វ័រ រូ *(Mr. François ROUX)*

លោកស្រី ហេឡឺន អ៊ុយណាក់

*(Ms. Heleyn UÑAC)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោក ហុង គឹមសួន

លោក គឹម ម៉េងឃី

លោកស្រី ស៊ីលឃី ស្ទួតហ្ស៊ីនស្គី

*(Ms. Silke Studzinsky)*

លោកស្រី ម៉ាទីន ហ្សាកឃ្វីន (ហ្សាកកាំង)

*(Mrs. Martine Jacquin)*

កញ្ញា ទី ស្រ៊ីនណា

លោក អាឡាំង វ៉ែនណឺ

*(Mr. Alain Werner)*

**មេធាវីជំនួយការរបស់សាក្សី ហ៊ីម ហ៊ុយ៖**

លោក គង់ សំអុន

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុំ អរុណ

# ឧបសម្ព័ន្ធ

## សាក្សី

### លោក ហ៊ិម ហ៊ុយ ហៅ ហ៊ីម ហ៊ុយ

សួរបន្តដោយ ប្រធានអង្គជំនុំ ផ្ដើមពី ........ទំព័រ ១
សួរដោយ ចៅក្រម ស៊ីលយ៉ា ខាតវ៉ាយថ៍ ផ្ដើមពី ........ទំព័រ ៦៨
សួរដោយ ចៅក្រម យ៉ា សុខន ផ្ដើមពី ........ទំព័រ ៧៤
សួរដោយ ចៅក្រម ហ្សង់ម៉ាក ឡាវែន៍ ផ្ដើមពី ........ទំព័រ ៧៥

**បញ្ជីឈ្មោះ អ្នកនិយាយ៖**

ភាសា ដែលប្រើប្រាស់ លើកលែងតែបានកំណត់ដាក់លាក់នៅក្នុងប្រតិចារឹក

| **អ្នកនិយាយ** | **ភាសា** |
|---|---|
| ចៅក្រម ស៊ីលយ៉ា ខាតវ៉ាយថ៍ | អង់គ្លេស |
| លោក ហ៊ីម ហ៊ុយ | ខ្មែរ |
| លោកស្រី ម៉ាទីន ហ្សាកកាំង | បារាំង |
| ចៅក្រម ហ្សង់ម៉ាក ឡាវែរ៍ | បារាំង |
| លោក ហ្វ្រង់ស្វ័រ រូ | បារាំង |
| លោក វីលៀម ស្មីត | អង់គ្លេស |
| ជនជាប់ចោទ | ខ្មែរ |
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំជម្រះ) | ខ្មែរ |
| លោក អាឡាំង វ៉ែនណឺ | អង់គ្លេស |
| ចៅក្រម យ៉ា សុខន | ខ្មែរ |

# កិច្ចដំណើរការនីតិវិធី

*[ចៅក្រមចូលមកកាន់បន្ទប់សវនាការ]*

[០៩:០៥:២៥]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយចុះ ។ អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការពិភាក្សាដេញដោលចំពោះសាក្សីឈ្មោះ ហ៊ីម ហ៊ុយ ។

**សួរដោយប្រធានអង្គជំនុំ៖**

អរុណសួស្តីលោក ហ៊ីម ហ៊ុយ ។ មន្ត្រីតុលាការជួយរៀបចំគាត់ឲ្យប្រើប្រាស់កាស ។

**ស៖** លោក ហ៊ីម ហ៊ុយ តើលោកបានប្រឹក្សាយោបល់ជាមួយនិងមេធាវីរួចហើយឬនៅ?

**ឆ៖** បាទ ខ្ញុំបានរក្សាហើយពិភាក្សាហើយ ។

**ស៖** នៅពេលនេះ តើលោកសំណូមពរយ៉ាងម៉េចចំពោះមេធាវី របស់លោកសុំឲ្យគាត់អង្គុយនៅទីនេះជាមួយលោក ឬក៏មិនបាច់ទេ?

**ឆ៖** មិនបាច់ក៏បានដែរ បើអង្គុយក៏បាន ប៉ុន្តែយកល្អអង្គុយក្បែរខ្ញុំ ស្រណុកគាត់បានស្តាប់ ។

**ស៖** អង្គុយទីនេះបានន័យថា អង្គុយនៅកន្លែងដែលគាត់អង្គុយនៅខាងស្តាំដៃលោកហ្នឹង ឬមួយក៏ឲ្យគាត់ទៅសម្រាកនៅខាងក្រៅពីកន្លែងនេះ ហើយពេលដែលលោកត្រូវការពិភាក្សាទើបសុំឲ្យគាត់មកពិភាក្សា មិនមែនឲ្យមកអង្គុយនៅជិតលោកទេ ។ សុំឲ្យគាត់នៅវត្តមាននៅក្នុងសាលសវនាការនេះ ឬក៏មិនបាច់ទេ ពេលដែលជួបនូវសំណួរដែលមានការសង្ស័យពាក់ព័ន្ធនឹងថា ចម្លើយលទ្ធផលនៃសំណួរនោះគឺអាចឆ្លើយតបទៅ នាំឲ្យមានពិរុទ្ធភាពដាក់បន្ទុកលើលោក ទើបលោកត្រូវការអញ្ជើញគាត់មកពិភាក្សា ឬមួយក៏ឲ្យគាត់នៅអង្គុយនៅក្នុងបន្ទប់សវនាការហ្នឹងជាមួយទីនេះ រហូតនៅក្នុងអំឡុងពេលដែលលោកធ្វើសក្ខីកម្មនេះ?

**ឆ៖** បាទ, សូមឲ្យគាត់អង្គុយនៅក្នុងសវនាការនេះ រហូតដល់ពេលបញ្ចប់ ។

**ស៖** ខ្ញុំសូមជម្រាបលោក ហ៊ីម ហ៊ុយ ថានៅក្នុងអំឡុងពេល ដែលលោកផ្តល់សក្ខីកម្មចំពោះមុខអង្គជំនុំជម្រះនេះ លោកអាចសុំពិគ្រោះយោបល់ ជាមួយនឹងមេធាវីរបស់លោកជាមុនសិន មុននឹងលោកឆ្លើយនឹងសំណួរ ឬក៏ធ្វើសេចក្តីអះអាងណាមួយ ដែលលោកមានការសង្ស័យថា ចម្លើយរបស់លោក

ឬសេចក្ដីអះអាងរបស់លោកហ្នឹង វាអាចដាក់បន្ទុកលើលោក ។ ដោយឡែកសំណួរផ្សេងទៀត ដែលមិនមានការពាក់ព័ន្ធដូច្នេះទេ លោកអាចឆ្លើយដោយខ្លួនឯង អ៊ីចឹងការពិគ្រោះហ្នឹងគឺ លុះត្រាតែសំណួរណាដែលនាំឱ្យមានចម្លើយ ឬសេចក្ដីអះអាងនោះអាចថា លោកយល់ថាអាចដាក់បន្ទុកនៃពិរុទ្ធភាពលើខ្លួនលោក ។ លោកយល់ទេបញ្ហានេះ?

[០៩:១០:១៧]

**ឆ៖** បាទ ខ្ញុំយល់ ។

**ស៖** លោក ហ៊ឹម ហ៊ុយ តើលោកអាចនិយាយរៀបរាប់ដោយសង្ខេបអំពីទីកន្លែងនិងមុខរបរដែលលោកបានរស់នៅនិងប្រកបរបររកស៊ីក្នុងអំឡុងពេលចន្លោះឆ្នាំ១៩៧០ រហូតដល់ថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ តើលោកធ្វើការងារអ្វី? នៅទីណា?

**ឆ៖** ខ្ញុំសូមជម្រាបលោកចៅក្រមអស់លោកទាំងអស់! កាលពីឆ្នាំ១៩៧០ ខ្ញុំជាកុមារ បានអាយុជាង១០ឆ្នាំ ម៉ែឪឱ្យ-- ប្រហែលជា១០ឆ្នាំ ១១ឆ្នាំ ខ្ញុំបានទៅរៀនសូត្រនៅសាលា រហូតដល់ឆ្នាំ-- សូមទោសៗ ពីឆ្នាំ៧០ខុសហើយ ។ ពីឆ្នាំ៧០ គឺខ្ញុំឈប់រៀនហើយ ខ្ញុំប្រកបរបររកស៊ីជាមួយឪពុកម្ដាយធ្វើចម្ការ រហូតដល់ឆ្នាំចុងឆ្នាំ៧២ហ្នឹង ដើមឆ្នាំ៧៣ មេភូមិគេកែនអ្នកមានអាយុពី១៧-១៨ឆ្នាំ ចូលធ្វើកងទ័ព ហើយគេកែនពីភូមិយកមកអស់ឱ្យពួកខ្ញុំមកកងទ័ពស្រុក ហាត់រៀននៅនឹងស្រុក ។ ពេលនោះខ្ញុំហាត់រៀននៅនឹងស្រុកកោះធំហ្នឹង ក៏អាល័យម៉ែឪខ្លាំងពេក ក៏ខ្ញុំសុំគណៈសាលាទៅផ្ទះ ខ្ញុំភូតគេថា ម៉ែឪខ្ញុំឈឺ ខ្ញុំសុំទៅផ្ទះ គេថា "មិត្តឯងទៅផ្ទះហ្នឹង មិត្តឯងពេទ្យឬក៏អី ម៉ែឪមិត្តឯងឈឺ មិត្តឯងមើលកើតអី?" ដល់អញ្ចឹងខ្ញុំ ថាខ្ញុំមិនមែនជាពេទ្យទេ តែម៉ែឪឈឺហើយ ខ្ញុំសុំទៅមើលគាត់ ច្រើនណាស់តែមួយម៉ោងពីរម៉ោងមកវិញ រហូតមកគេអត់ឱ្យទៅ ខ្ញុំក៏លែងបានទៅ ។

ក្រោយមកទៀត ពីរនាក់បងប្អូនជីដូនមួយនាំគ្នា ថ្ងៃគេឈប់រៀនសូត្រហ្នឹង ឈប់ហាត់ហ្នឹង ក៏នាំគ្នារត់ទៅរត់ទៅលេងផ្ទះ ដេកបានមួយយប់ ។ មកវិញខាងសាលាគេដាក់វិន័យ ខ្ញុំទាំងពីរនាក់នេះ គេថាបើយន្តហោះមកទម្លាក់ចំកន្លែងទីតាំងកងទ័ពហាត់ គេចាប់ខ្ញុំពីរនាក់បងប្អូនជីដូនមួយហ្នឹង យកទៅបាញ់ចោល ។ មុននឹងគេប្រកាសហ្នឹង ក៏គេឱ្យមើលកាំភ្លើងបីដើមមកហើយ គេថា "អ្អែងស្ម័គ្រចិត្តយកកាំភ្លើងមួយណា ចង្អុលទុកឱ្យហើយទៅ" ហើយយន្តហោះស្ពាបកាត់ពីពោធិចិនតុងទៅ ទម្លាក់ទៅខាងត្បូងហ្នឹង ទៅកន្លែងត្រពាំងជ្រៃ ។ រហូតទៅ ខ្ញុំចេះតែភ័យបីថ្ងៃ ហើយគេទណ្ឌកម្មឱ្យរែកទឹកដាក់ពេញពាង គេអត់ឱ្យយាម អត់ឱ្យអីទេ ដេកតែស៊ីបាយនៅស្មៀម ។ ពេលនោះយន្តយោះក៏លែងទម្លាក់បីថ្ងៃ

ហ្នឹងក៏ឈប់ទម្លាក់ទៅ ក៏បានរួចខ្លួនមួយពេលហ្នឹង ។

[០៩:១៤:៣៨]

ក្រោយមកទៀតមក បានគេដកពួកអង្គភាពដែលហាត់ហ្នឹងបញ្ជូនមកខាងព្រៃល្វា ស្រុកព្រៃកប្បាសហ្នឹងបានកងពល១២ហ្នឹងគេរើសយកទៅបញ្ចូលកងទ័ពរបស់គេ មានទៅ-- អ្នកណាមាឌធំៗគេបញ្ចូលទៅកាំភ្លើងធំ អ្នកណាមាឌតូចៗគេមកឲ្យទៅខាងថ្មើរជើងទៅ ។ រហូតខ្ញុំនៅកងទ័ពហ្នឹងរហូតទៅខាងថ្មើរជើង ហើយគេហាត់ទាហានបច្ចេកទេសយោធារហូតរៀបចំការវាយប្រហារគ្នានៅផ្លូវជាតិលេខ២ ក៏វ៉ៃគ្នានៅផ្លូវជាតិលេខ២ ។ ក្រោយមកទៀតដកមកផ្លូវជាតិលេខ២១ មកវ៉ៃនៅ២១នេះទៀត ។ ដល់ក្រោយមកខ្ញុំឈឺរត់ទៅផ្ទះ ណាមួយអាល័យម៉ែឪផងទៅមើល ។ ហើយស្តាប់សភាពការណ៍នៅភូមិ បើធូរធារអាហ្នឹងខ្ញុំអត់មកទ័ពវិញទេ ទៅផ្ទះបានមួយថ្ងៃតឹងតែងមកវិញមក ។ ក្រោយមកទៀត ទៅវ៉ៃនៅតាមទន្លេមេគង្គទៀត ដកពីទន្លេមេគង្គមកទៀត មកទន្លេបាសាក់វិញ វ៉ៃទន្លេបាសាក់ខ្ញុំក៏សម្រាកនៅជិតផ្ទះសុំគេទៅទៀត លេងផ្ទះ ។ ដល់ក្រោយមកទៀត តឹងតែងខ្លាំងបាក់ស្មារតីហើយក៏--

**ប្រធានអង្គជំនុំ៖**

មានបញ្ហាអីទៀតទៅមេធាវី?

**លោក អាឡាំង វែនណឺ៖**

សូមគោរពលោកប្រធាន! ខ្ញុំសូមអភ័យទោស គឺថាសាក្សីគាត់បានអានពីឯកសារ ហើយខ្ញុំគិតថា បើសិនឲ្យហេតុអ្វីបានជាសាក្សីបានមានឯកសារអាន អ៊ីចឹងហើយខ្ញុំសួរថាតើលោកចៅក្រម អាចនឹងសួរស្នើសុំឯកសារមើលដែរ ឬក៏មានដែរឬទេឯកសារហ្នឹង?

**ប្រធានអង្គជំនុំ៖**

លោកឆ្លើយហ្នឹងអានតាមឯកសារ ដូចមេធាវីកត់សម្គាល់ទេ?

**លោក ហ៊ីម ហ៊ុយ៖**

*(អត់បើកមេក្រូហ្វូន)*

**សួរដោយប្រធានអង្គជំនុំ៖**

លោក ហ៊ីម ហ៊ុយ ចាំណេះៗ ហ៊ីម ហ៊ុយ ណេះ ចាំរង់ចាំក្បាលមីក្រូហ្នឹងមានភ្លើងពណ៌ក្រហមហើយទើបលោកចាប់ផ្តើមនិយាយបាន ហើយសំឡេងនិយាយហ្នឹង នឹងអាចចូលទៅប្រព័ន្ធនៃការបក

ប្រែភាសា ដើម្បីឲ្យការបកប្រែភាសាឯទៀតមានភាសាបារាំង និងអង់គ្លេស ហើយនិងប្រតិចារឹកកត់ត្រាចូលក្នុងប្រតិចារឹកផង ។

[០៩:១៨:២២]

**ស៖** លោក ហ៊ុម ហ៊ុយ និយាយដោយសង្ខេប យើងចង់ដឹងពត៍មានដោយសង្ខេប អំពីការដែលលោកធ្វើការងារអ្វីខ្លះ? ហើយនៅទីណាខ្លះតែប៉ុណ្ណោះទេនៅក្នុងអំឡុង៧៣ លោកអំមិញថា យើងចង់ឲ្យនិយាយថាពី ៧០ ទល់ ៧៥ តែសំខាន់ហ្នឹងគឺពី ៧៣ ដែលលោកបាននិយាយរហូតដល់ថ្ងៃ១៧ ខែមេសា ឆ្នាំ៧៥ ដែលកងទ័ពខ្មែរក្រហម បានផ្តួលរំលំរបប លន់ នល់ នេះជាដំណាក់កាលមួយ ។ យល់ពាក្យសង្ខេបទេនិយាយត្រួសៗនូវមុខងារភារកិច្ច និងទីកន្លែងប្រតិបត្តិការធ្វើការងាររបស់លោកតែប៉ុណ្ណោះ ។

**ឆ៖** បាទ, ខ្ញុំសុំជម្រាបបន្តទៀត ។ ក្រោយមក ខ្ញុំបម្រុងរត់ទៅផ្ទះ បាក់ស្មារតីហើយ ខ្ញុំបានរត់ទៅផ្ទះម្តងពេលដែលខ្ញុំឈឺ ពេលដែលខ្ញុំឈឺហ្នឹង គឺខ្ញុំថាលែងមកវិញហើយ គឺប្រាំថ្ងៃប្រធានភូមិសួររហូត ទ្រាំមិនបានទាល់តែរត់មកវិញមកទ័ពវិញ ។ ហើយការមកទ័ពវិញហ្នឹង កងរយសួរខ្ញុំថា អ្ហែ! ប្រញាប់មកម៉េ្លះ អញថាស្អែកទៅអញ្ជើញពីផ្ទះមក ។

**ប្រធានអង្គជំនុំ៖**

យ៉ាងម៉េចមេធាវី អាឡាំង វែណឺ ចង់និយាយអីឲ្យបានច្បាស់លាស់ ហើយសំណួមពរថាម៉េច? មិននិយាយទទេៗដូច្នេះទេ និយាយឲ្យបានច្បាស់លាស់ ហើយនិយាយថាម៉េច បំណងនៃការស្នើនិយាយនេះ?

**លោក អាឡាំង វែនណឺ៖**

សូមអភ័យទោសលោកប្រធាន ខ្ញុំនឹងបញ្ជាក់ ខ្ញុំសូមស្នើឲ្យអង្គជំនុំជម្រះស្នើថា តាមដែលខ្ញុំយល់គឺសាក្សីគឺថា អាចនឹងៗ ខ្ញុំមិនខ្ញុំគ្រាន់តែស្នើសុំចៅក្រម ឲ្យស្នើឲ្យយល់ថា តើអ្វីឯកសារដែលគាត់អានហ្នឹង គឺសាក្សីគាត់មានឯកសារ ហើយខ្ញុំចង់ដឹងថាឯកសារហ្នឹងជាឯកសារអ្វី? គ្រាន់តែប៉ុណ្ណឹងទេ ។

**ប្រធានអង្គជំនុំ៖**

លោក ហ៊ុម ហ៊ុយ លោកអានឯកសារមែនទេ?

**លោក ហ៊ុម ហ៊ុយ៖**

*(អត់បើកមីក្រូហ្វូន)*

ហើយខ្ញុំនិយាយនេះ គឺខ្ញុំខ្លួនរបស់ខ្ញុំយ៉ាងម៉េចពីមុនមក គឺខ្ញុំនិយាយអ៊ីចឹង ។

**ប្រធានអង្គជំនុំ៖**

មន្ត្រីតុលាការទៅពិនិត្យមើល ហើយដកឯកសារហ្នឹងឲ្យយើង ។

*(ចៅក្រមពិនិត្យឯកសាររបស់សាក្សី)*

ណោះមន្ត្រីតុលាការយកឲ្យគាត់វិញទៅ អាហ្នឹងឯកសារយើងបានអនុញ្ញាតឲ្យគាត់មើលតាំងពីម្សិលមិញ ។ នេះជាកំណត់ហេតុដែលស្តាប់ចម្លើយសក្ខីកម្មរបស់សាក្សី នៅដំណាក់កាលចំពោះមុខសហចៅក្រមស៊ើបអង្កេត ។

[០៩:២២:៥៩]

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** លោកនិយាយអម្បាញ់មិញថា លោកចូលធ្វើកងទ័ពនៅក្នុងប្រហែលជាដើមឆ្នាំ៧៣ ចូលទ័ពនៅកងទ័ពស្រុក ។ នៅស្រុកណា? កងទ័ពស្រុកខាងណាទៅ?

**ឆ៖** បាទ, កាលជំនាក់អាពតហ្នឹង គេហៅ កងទ័ពស្រុក១៨ ស្រុកកោះធំ ខេត្តកណ្តាល ។

**ស៖** ក្រោយពីធ្វើកងទ័ពនៅស្រុក១៨ លោកបានអះអាងថា គេជ្រើសរើសក្នុងការចូលទៅកងទ័ពមួយថ្នាក់ទៀត ដែលមាឌធំទៅខាងរថក្រោះ ហើយអ្នកដែលធម្មតាទៅខាងកងទ័ពថ្មើរជើង ហើយលោកទៅខាងកងទ័ពថ្មើរជើង ។ កងទ័ពដែលលោកចូលទៅខាងថ្មើរជើងកាលណោះ កងទ័ពគេហៅកងទ័ពអីទៅ? អង្គភាពអីគេ?

**ឆ៖** បាទ, ខ្ញុំសុំជម្រាបលោក គឺកងទ័ពថ្មើរជើងលេខ១១២ កងវរៈសេនាតូច ។

**ស៖** ឈរជើងនៅកន្លែងណាដែរ?

**ឆ៖** បាទ, ឈរជើងនៅគេហៅថា ក្រាំងយ៉ូវ អណ្តូងសំរោង និងដំរីស្លាប់ ។

**ស៖** វរៈ១១២ ហ្នឹងចំណុះឲ្យអង្គភាពណា? អង្គភាពណាធំជាងកង១១២ ហ្នឹងទៀត?

**ឆ៖** បាទ, កងហ្នឹង គឺកងគេហៅថា កងពល១២ កាលណោះ គេមិនទាន់ប្រកាសកងពល១២ទេ តែខ្ញុំស្តាប់អត់បានទេ ខ្ញុំទើបមកដល់អ៊ីចឹង គឺគេហៅថា កងពល១២ ។

**ស៖** ចាប់ពីពេលដែលលោកចូលទៅធ្វើការនៅកងវរៈ កងទ័ពនៅវរសេនាតូច១១២ ក្នុងកងពល១២នោះ រហូតដល់ថ្ងៃ១៧ ខែមេសា ឆ្នាំ៧៥ តើលោកបានដូរអង្គភាពដែរឬទេ? ឬក៏នៅតែអង្គភាពដដែល?

**ឆ៖** បាទ, ខ្ញុំដូរអង្គភាពតាំងពីឆ្នាំ១៩៧៤ ព្រោះខ្ញុំសុំបញ្ជាក់ថា កាលខ្ញុំនៅ១១២ហ្នឹង តាម៉ុន គឺ

កងរយ ស្នងការកងរយខ្ញុំ តាម៉ុន ។ កាលនៅច្បាំងខ្ញុំបាក់ស្មារតី ខ្ញុំរត់ទៅផ្ទះ ខ្ញុំចូលសាលាសេរីពីរដង រត់ទៅផ្ទះបីដង រឿងហ្នឹងហើយដែល តាម៉ុន គាត់លែងទទួលស្គាល់ខ្ញុំ គាត់ថាខ្ញុំជាមនុស្សអស់ការអប់រំរបស់គេហើយ គាត់ក៏ប្រគល់ខ្ញុំទៅឱ្យ តាហ៊ី កងវរៈ១១២ ហ្នឹង ។ តាហ៊ី កងវរៈ១១២ អតីតមកក្រោយមកក្នុងនេះហ្នឹង គឺអនុប្រធានរបស់ តាឌុច ។

[០៩:២៦:៣៩]

**ស៖** កាលពីអំឡុងពេលលោកធ្វើកងទ័ព ក្នុងសម័យសង្គ្រាម៧០-៧៥ ដែលលោកថា ធ្វើនៅអង្គភាពវរៈ១១២ ដែលមានប្រធានវរៈឈ្មោះ ហ៊ី នោះ លោកនៅអង្គភាពណានៃវរៈហ្នឹង? ហើយអង្គភាពលោកហ្នឹងមានភារកិច្ច ឬក៏មានមុខងារប្រតិបត្តិការយ៉ាងម៉េចដែរ?

**ឆ៖** បាទ, ពេលដែលតាម៉ុន ដក លែងទទួលស្គាល់ខ្ញុំទៅ តាហ៊ី យកខ្ញុំឱ្យមកនៅជាមួយ គាត់ថា “ឱ្យអ្នែងទៅ អ្នែងទៅនែកន្លែងនេះទៅកន្លែងកងវរៈទៅ” ដល់ហើយខ្ញុំក៏មកកងវរៈ កន្លែងតាហ៊ីហ្នឹង ដល់ហើយក៏ឱ្យនីរសារគាត់ជូនខ្ញុំមកព្រៃតូច ។ ព្រៃតូចហ្នឹង គឺគេរៀបចំជាកងសម្រុករបស់គេមួយនៅកន្លែងហ្នឹង គ្រប់គ្រងដោយបង ហ៊ុយ, បង ហ៊ុយ ស្រែ ជាអតីតនៅស-២១ គឺបង ហ៊ុយ ស្រែ ។

**ស៖** កងម៉េច កងសម្រុក? កងម៉េចច្បាស់លាស់មើល ក្នុងកងអីគេ?

**ឆ៖** បាទ, កាលនោះគាត់ដាក់ឈ្មោះថាជា កងសម្រុក១ ។ អាហ្នឹងហៅឱ្យច្បាស់ថា កងពិសេស ប៉ុន្តែជំនាន់ខ្មែរក្រហមហ្នឹង គេអត់ហៅអ៊ីចឹងទេ គេហៅថា កងសម្រុក១ ។

**ស៖** កងរបស់លោក កងសម្រុកហ្នឹងមានគ្នាប៉ុន្មាននាក់?

**ឆ៖** បាទ, កាលនោះពួកខ្ញុំទាំងអស់គ្នាប្រហែលជា ហាហុកសិបនាក់ ហើយនិងខាងសហការជាមួយនិងអង្គភាពខាងបូព៌ា ប្រហែលជាហាហុកសិបនាក់ទៀត ហាត់ជាមួយគ្នា ។

**ស៖** រហូតដល់ថ្ងៃទី១៧ ខែមេសា ៧៥ និយាយឱ្យចំនៅក្នុងថ្ងៃទី១៧ ខែមេសា ឆ្នាំ៧៥ តើលោកធ្វើអ្វីនៅទីកន្លែងណា?

**ឆ៖** ថ្ងៃទី១៧ មេសា គឺខ្ញុំវ៉ៃពីខាងត្បូងភ្នំពេញ តាមផ្លូវតាខ្មៅ រហូតចូលមកដល់ក្រុងភ្នំពេញតាមផ្លូវរោងចក្រកែវ ។

**ស៖** លោកនិយាយរៀបរាប់ដោយសង្ខេប អំពីការដែលលោកចូលមកក្រុងភ្នំពេញថ្ងៃទី១៧ ខែមេសា ឆ្នាំ៧៥ តាមរោងចក្រកែវ មកពីទិសខាងត្បូងនៃទីក្រុងភ្នំពេញនេះ រហូតដល់ថ្ងៃរំដោះ៧ មករា ឆ្នាំ៧៩ តើលោកធ្វើអ្វី? នៅទីណាខ្លះ?

[០៩:៣០:០០]

**ឆ៖** បាទ, ខ្ញុំសូមរៀបរាប់ពេលដែលវ៉ៃចូលឆ្នាំ១៩៧៥ គឺខ្ញុំវ៉ៃតាមផ្លូវជាតិលេខ២១ តាខ្មៅ ហើយបត់ទៅព្រែកកំពិស ទៅតាមរោងចក្រកែវ ។ ពេលនោះ ខ្ញុំបានចាប់បានទាហានខាង លន់ នល់ កាំភ្លើងធំពីរដើមនិងគ្រាប់កាំភ្លើងពីរឡាន ហើយនិងសក្តិប្រាំម្នាក់និងកូនគាត់ម្នាក់ទៀត ។ កាលនោះ ខ្ញុំក៏ឲ្យគាត់ទៅណាទៅៗ ។ គាត់នៅក្រាបគ្រាប់យន្តហោះទម្លាក់ជាមួយខ្ញុំហ្នឹង ហើយខ្ញុំក៏នាំកម្លាំងពួកខ្ញុំទៅតាមផ្លូវរោងចក្រកែវវ៉ៃចូលភ្នំពេញទៀត បានរហូតដល់ខ្ញុំមកនៅដល់កន្លែងពេទ្យចិន ពេទ្យកន្លែងសាលាយុគន្ធរហ្នឹង ។ ដល់ល្ងាចប្រហែលជាម៉ោងពីរម៉ោងបី កាលហ្នឹងគេឲ្យ គេប្រកាសឲ្យមេធំៗ ឲ្យទម្លាក់កាំភ្លើងទាំងអស់ទាហានដែលនៅក្រុងភ្នំពេញ ។ ដល់ពីម៉ោងពីរម៉ោងបីល្ងាចហ្នឹង តាហ៊ី បានប្រាប់ឲ្យខ្ញុំទៅប្រាប់ខាងទាហាន លន់ នល់ ឲ្យយកឡានដឹកកាំភ្លើងនៅតាមផ្លូវជាតិដែលប្លូនជ្រុងកន្លែងពេទ្យចិនហើយនិងសាលាយុគន្ធរហ្នឹង ។

ដល់ពេលល្ងាចម៉ោងប្រាំពីរ ម៉ោងប្រាំបី ពេលនោះម៉ោងប្រាំបីក៏កន្លែងអង្គភាពរបស់ខ្ញុំ បីក្រុមហ្នឹងក៏រៀបចំឈរជាជួរ គ្រាន់តែឈរជាជួរម៉ោងប្រាំបីហ្នឹងបានផ្ទុះគ្រាប់បែកនិងបាញ់កាំភ្លើងដោយការ- - ក៏M72 ក៏មិនដឹងទេ កាលនោះ គឺដាច់ខ្លួន អាខ្លះដាច់ខ្លួនមួយកំណាត់ ខ្លះងាប់អស់គ្នាច្រើនអាហ្នឹងហើយ ហើយខ្ញុំក៏របួស ខ្ញុំក៏បោះកាំភ្លើងបោះអីចោល ខ្ញុំរត់បណ្តោយ ។

**ស៖** លោក ហ៊ឹម ហ៊ុយ តើលោកស្គាល់មន្ទីរសន្តិសុខស-២១ ដែរឬទេ?

**ឆ៖** បាទ, ខ្ញុំស្គាល់ ។

**ស៖** លោកដែលរស់នៅ និងធ្វើការនៅក្នុងមន្ទីរសន្តិសុខ ស-២១ ដែរ ឬទេ?

**ឆ៖** បាទ, ខ្ញុំធ្វើការនៅកន្លែងសន្តិសុខស-២១ ហ្នឹង ។

**ស៖** លោកចូលទៅមកធ្វើការនៅក្នុងមន្ទីរសន្តិសុខស-២១ នៅថ្ងៃខែឆ្នាំណាដែរ? ហើយអ្នកណាជាអ្នកយកលោកមកធ្វើការនៅក្នុងមន្ទីរសន្តិសុខស-២១?

**ឆ៖** ខ្ញុំសូមជម្រាបលោកចៅក្រម! បែកហើយឆ្នាំ១៩៧៥ គឺខ្ញុំគេឲ្យអង្គភាពហ្នឹងទៅផ្ទាក់ដីនៅកន្លែងអគ្គិសនីចាក់អង្រែ ក្រោយអគ្គិសនីចាក់អង្រែហ្នឹង ។ ផ្ទាក់ដី លើកភ្លឺស្រែ ធ្វើចបកាប់ ចបអីខ្លួនឯងរៀបកង់ រៀបអីមួយម្នាក់ៗជិះទៅ ដាក់បាយខ្លួនឯងទៅស៊ីផ្ទាក់ដី រៀបដី លើកភ្លឺស្រែហ្នឹង ។

ក្រោយមកទៀតបានគេបញ្ជូនពួកខ្ញុំឲ្យទៅនៅព្រែកជ្រៅៗទៅនៅធ្វើស្រែហ្នឹង លើកភ្លឺ ផ្ទាក់ដី ផ្ទាក់អី ហើយរាស់រនាស់ បាចទឹកដាក់រាស់រនាស់--

[០៩:៣៤:០៥]

**ស៖** អត់ចង់ដឹងទេ ។ ឥឡូវចង់ដឹងពីព្រោះលោករៀបរាប់ វាគ្រាន់តែជាពាក្យថាសង្ខេប លោកអត់ស្គាល់ពាក្យសង្ខេបទេ ។ អ៊ីចឹងអង្គជំនុំជម្រះមិនចង់ស្ដាប់បញ្ហាទុំងទេ ។ ឥឡូវនេះ ចូលក្នុងរឿងពាក់ព័ន្ធជាមួយនឹងអង្គហេតុដែលត្រូវធ្វើសក្ខីកម្មសួរថា លោកត្រូវបានបញ្ជូនមកធ្វើការនៅក្នុងមន្ទីរស-២១ នៅពេលណា? ថ្ងៃខែឆ្នាំណា? តើអ្នកណាជាអ្នកឧទ្ទេសនាម ឬក៏ជាអ្នកនាំលោក ឬក៏ចាប់លោកឲ្យមកធ្វើការនៅក្នុងមន្ទីរសន្តិសុខ ស-២១? នេះជាសំណួរ ។

**ឆ៖** បាទ, ខ្ញុំសូមជម្រាបថា ខ្ញុំនៅព្រៃកជ្រៅ តាហ៊ កន្ទុញ កងវរៈ គាត់បានឲ្យខ្ញុំមកកន្លែងគាត់ គាត់ថាឲ្យខ្ញុំផ្លាស់អង្គភាពទៅអាមីរីន ។ មកដល់ថ្ងៃរសៀល ដល់ពេលយប់ម៉ោងប្រាំបី គាត់ឌុបខ្ញុំមកចូលគុក ។ គាត់ថាអ្ហែងមានរឿង ខ្ញុំថាខ្ញុំដឹងមានរឿងអីបង? អ្ហែងទៅដល់គង់តែដឹង ។ ខ្ញុំនឹកឃើញថាខ្ញុំកាលពីមុនខ្ញុំធ្វើទ័ព ខ្ញុំរត់ទៅផ្ទះ ចូលសាលាសេរីពីរដងហើយ ច្បាស់ជារឿងហ្នឹង ។

បានហើយខ្ញុំមកនៅគុកហ្នឹងពីរបីថ្ងៃនៅហ្នឹងទៅ ក្រោយមកបានគេឲ្យយាមឲ្យអីអ៊ីចឹងរហូត ។ នៅក្នុងចុងឆ្នាំ១៩៧៦ ដែលខ្ញុំចូលមកកន្លែងហ្នឹង ។

**ស៖** អ៊ីចឹងបានន័យថានៅក្នុងឆ្នាំ១៩៧៦ គឺឈ្មោះ ហ៊ ហ្នឹងជាអ្នកជ្រើសរើស ឬចាប់លោកឲ្យធ្វើការនៅមន្ទីរស-២១ អ៊ីចឹងមែនទេ?

**ឆ៖** បាទ, មិនមែន ហ៊ ខ្វាក់ភ្នែកម្ខាងដែលអនុប្រធានរបស់ តាឌុច ទេ គឺហ៊ កន្ទុញមួយទៀតដែលជាកងវរៈផ្សេងមួយទៀត ឈ្មោះ ហ៊ ដែរ ។

**ស៖** កាលពីលោកមកធ្វើការនៅមន្ទីរសន្តិសុខស-២១ហ្នឹង កាលនោះឈ្មោះពិតប្រាកដនៃកន្លែងលោកធ្វើការហ្នឹង គេដាក់ឈ្មោះអី? មន្ទីរសន្តិសុខស-២១ ឬក៏ឈ្មោះផ្សេងពីនេះ?

[០៩:៣៦:៤៤]

**ឆ៖** បាទ, កាលមុនដាក់ឈ្មោះ ស-២១ ។

**ស៖** លោកស្គាល់ច្បាស់ទេ មន្ទីរសន្តិសុខស-២១ បើធៀបនឹងបច្ចុប្បន្នហ្នឹងទីកន្លែងណា? គេហៅអីបច្ចុប្បន្ននេះ?

**ឆ៖** បាទ, បច្ចុប្បន្ននេះ គេហៅ ទួលស្លែង ។

**ស៖** គេហៅ សារមន្ទីរគុកទួលស្លែង ហ្នឹងមែនទេ?

**ឆ៖** បាទ ។

**ស៖** ពេលលោកត្រូវគេបញ្ជូនមកធ្វើការនៅមន្ទីរសន្តិសុខស-២១ លោកធ្វើការអ្វីដែរ? គេចាត់ឲ្យលោកធ្វើការងារអ្វីដែរ?

**ឆ៖** បាទ, កាលមុនខ្ញុំជាយុទ្ធជននៅការពារកន្លែងអ្នកទោសហ្នឹង ។ ហើយក្រោយមកទៀត គេឲ្យខ្ញុំទៅនៅកន្លែងដែលចាំទទួលអ្នកទោសនៅកន្លែងផ្ទះដាក់តេអូមួយ បច្ចុប្បន្ននេះ កន្លែងប៉ុស្តិ៍សំបុកឃ្មុំនោះ ។

**ស៖** តាមដែលលោកនៅចងចាំ តើនៅក្នុងអង្គភាពស-២១ ទាំងមូលហ្នឹង កាលពីលោកចូលមកដល់ហ្នឹង អ្នកណាជាប្រធាន? អ្នកណាជាអនុប្រធាន? ហើយមានសមាជិកដែរឬទេ?

**ឆ៖** បាទ, ផ្នែកការពារពីមុនមក គឺមានប្រធានគ្នាប៉ុន្មាននោះ ប្រធានកងរយគ្នាជិតដប់នាក់ ។

**ស៖** ប្រធានទទួលខុសត្រូវរួម ឬក៏ពាក្យថាគណៈកម្មាធិការមន្ទីរស-២១ ពាក្យនេះដែរលោកដែលលោកឮទេ? គណៈកម្មាធិការមន្ទីរស-២១?

**ឆ៖** ខ្ញុំអត់ដែលបានឮទេ គណៈកម្មាធិការ ខ្ញុំឮតែប្រធានស-២១និងអនុប្រធាន និងសមាជិក ។

**ស៖** អំមិញយើងសួរថាលោកស្គាល់ទេ កាលពីមកដល់លោកមកធ្វើការហ្នឹងប្រធានមន្ទីរស-២១ ហ្នឹងឈ្មោះអ្វី? អនុប្រធានមន្ទីរស-២១ ឈ្មោះអ្វី? សមាជិកនៃមន្ទីរស-២១ហ្នឹងឈ្មោះអ្វី? យើងនិយាយពីប្រធានអង្គភាពទាំងមូល មិនមែននិយាយពីកងរយទេ ។ លោកស្គាល់ទេអ្នកណាគេ?

**ឆ៖** បាទ, ប្រធានអង្គភាពស-២១ គឺតាឌុច គាត់ជាប្រធាន, អនុប្រធានគឺ តាហ៊ា ហើយសមាជិកស-១២នោះ គឺបងហ៊ុយ ។

**ស៖** ហ៊ុយណា? ហ៊ុយ ឈ្មោះពេញឈ្មោះអីទៅហ៊ុយហ្នឹង? ហើយកន្លែងធ្វើការគាត់នៅកន្លែងណានៃមន្ទីរស-២១?

[០៩:៤០:៣១]

**ឆ៖** បាទ, កាលមុនហៅគាត់តែបងហ៊ុយ ធំៗ គាត់សមាជិករបស់ស-២១ គាត់ធ្វើការនៅព្រៃស ។

**ស៖** លោកនិយាយអំមិញថា គេឲ្យលោកធ្វើការងារជាអ្នកនៅប្រចាំការនៅប៉ុស្តិ៍មួយដែលមានដាក់វិទ្យុទាក់ទង ហើយកន្លែងនោះបច្ចុប្បន្ន គឺជាស្ថានីយវិទ្យុសំបុកឃ្មុំនៅម្តុំកន្លែងនឹងស្ថានីយនៃរថយន្តពន្លត់អគ្គិភ័យ ។ តើអង្គភាពរបស់លោកដែលលោកទៅធ្វើការហ្នឹងគេហៅអង្គភាពអីទៅ? អង្គភាពនុ៎ង?

**ឆ៖** បាទ, អង្គភាពខ្ញុំមួយក្រុមហ្នឹងគឺគេហៅថាអង្គភាពចាំទទួលអ្នកទោសនិងទៅចាប់អ្នកទោស ហើយនិងដឹកអ្នកទោសដែលគេសួរចម្លើយហើយយកទៅជើងឯក ។

**ស៖** លោកដែលឮមានអង្គភាពកងពិសេសទេ?

**ឆ៖** បាទ,រឿងអង្គភាពកងពិសេសជាធម្មតាទេ ចេះតែនាំគ្នាហៅទៅ ប៉ុន្តែតាមការពិតខាងផ្នែកការពារទាំងអស់ ។

**ស៖** តើមានការបែងចែកទេ អង្គភាពការពារ មានការពារខាងក្រៅ និងការពារខាងក្នុងដែរឬទេ?

**ឆ៖** បាទ,ខ្ញុំសូមជម្រាប មានបែងចែកផ្នែកការពារខាងក្នុងផ្សេង ហើយការពារខាងក្រៅផ្សេង។

**ស៖** អង្គភាពកងការពារខាងក្រៅដែលលោកនិយាយថាលោកធ្វើការនៅទីនោះ ហើយបំពេញភារកិច្ច ទទួលបញ្ជាទៅចាប់មនុស្ស នាំមនុស្សចូលទៅដាក់ឃុំឃាំងហើយនាំមនុស្សចេញយកទៅកម្ទេចដែលលោកបាននិយាយអំបាញ់មិញនេះ ។ តើអង្គភាពនុ៎ងមានគ្នាចំនួនប៉ុន្មាននាក់? ហើយគេបែងចែកការគ្រប់គ្រងយ៉ាងដូចម្ដេច? ដូចជាកងចំណុះអង្គភាពហ្នឹងជាច្រើនកង ហើយក្នុងមួយកងមានគ្នាប៉ុន្មាននាក់ដែរ?

**ឆ៖** បាទ, ខ្ញុំសូមជម្រាបថា អង្គភាពមួយក្រុមៗហ្នឹងទេ តែដល់ពេលទៅចាប់អ្នកទោសអ្នកអីនៅកន្លែងណាគឺ តាហ៊ី គាត់ដកកម្លាំងពីផ្នែកការពាររើសអ្នកមាឌធំៗយកមកទៅចាប់ជាមួយពួកខ្ញុំហើយនិងតាហ៊ីហ្នឹង ។

**ស៖** អ៊ីចឹង ក្រុមរបស់លោកមានគ្នាប៉ុន្មាននាក់? ក្រុមរបស់លោកផ្ទាល់មានគ្នាប្រហែលប៉ុន្មាននាក់?

[០៩:៤៣:៥៧]

**ឆ៖** បាទ, ក្រុមរបស់ខ្ញុំដែលខ្ញុំនៅកាន់កាប់ចាំទទួលអ្នកទោស និងដឹកជញ្ជូនយកទៅនេះហ្នឹងមួយក្រុមគ្នាដប់នាក់កាលហ្នឹង ។

**ស៖** លោកនិយាយអំមិញថាមានទទួលប្រតិបត្តិការ និងបទបញ្ជាដែលចុះទៅចាប់ខ្លួនមនុស្សពីកន្លែងផ្សេងៗក្រោមការដឹកនាំរបស់ ហ៊ី ដែលជាអនុប្រធានដោយមានការជ្រើសរើសនូវកងការពារនៅអង្គភាពផ្សេងទៀតដែលមានមាឌធំៗដើម្បីជាជំនួយ ។ តើការចុះប្រតិបត្តិការក្នុងការចាប់មនុស្សនុ៎ងដែលមានហ៊ី ជាអ្នកដឹកនាំបញ្ជានោះទៅចាប់នៅទីក្រុងភ្នំពេញ ឬចាប់នៅតំបន់នានានៅក្នុងភូមិភាគ ឬក៏

តំបន់ផ្សេងៗទៀតទូទាំងប្រទេស ហើយញឹកញាប់ដែរឬទេ?

[០៩:៤៥:00]

**ឆ៖** បាទ, ទៅចាប់នៅតាមខេត្តដូច បាត់ដំបងក៏ទៅ តែបាត់ដំបងទៅហ្នឹងក៏កម្លាំងដែលគេចាប់នៅនោះហើយ ឡានទៅដល់ដឹងតែដឹកមកពេលយប់មកវិញ ។ ហើយនៅខាងស្វាយរៀងៗ ពួកខ្ញុំទៅយកហ្នឹងក៏ជាកងទ័ពវៀតណាមដែលគេចាប់បាននៅតាមសមរភូមិប្រយុទ្ធហ្នឹង ។ ហើយទៅខាងកំពង់សោមៗហ្នឹងក៏គេចាប់ហើយ ដឹងតែទៅដឹកយកមក។ ហើយតាមបទបញ្ជារបស់ តាហ៊ា និង តាឌុចដែលបញ្ជាឲ្យពួកខ្ញុំទៅ គឺខ្ញុំទៅជាមួយ ផល ដែលជាប្រធានកងការពារ ។

**ស៖** អំមិញនេះលោកនិយាយពីរឿងទៅដឹក ។ ពីមុនលោកនិយាយរឿងចាប់ ឥឡូវនិយាយរឿងចាប់យើងធីបទុកមួយដុំសិន យើងសួររឿងដឹកពីព្រោះលោកឆ្លើយរឿងដឹក និយាយដំបូងថារឿងចាប់ឥឡូវនិយាយពីរឿងដឹក ។ សួរថាតើការទៅដឹកមនុស្សនៅបាត់ដំបងក្តី ទៅស្វាយរៀងក្តី ទៅកំពង់សោមក្តី ទីមួយសួរថាទៅមួយជើងៗហ្នឹងមានគ្នាប៉ុន្មាននាក់? ហើយទៅដោយមធ្យោបាយអី? ហើយការដឹកជញ្ជូនមនុស្សហ្នឹងពីនោះមកកាន់គុកទួលស្លែងហ្នឹងមួយជើងៗមានទទួលមនុស្សមកប្រហែលប៉ុន្មាននាក់ដែរតាមដែលលោកចងចាំ?

**ឆ៖** បាទ, ដូចទៅបាត់ដំបងៗ គឺឡានឡង់រូវ៉ែពីរ ទៅគ្នាប្រាំមួយនាក់អីចឹងទៅ ។ ដូចទៅពីកំពង់សោមគឺឡាន ឡង់រូវ៉ែ មួយទៅគ្នាបួនប្រាំនាក់ជាមួយ ផល ដែលជាប្រធានរបស់ពួកខ្ញុំ ។ ហើយទៅខាងស្វាយរៀងនេះក៏គ្នាតិចណាស់បួននាក់ ដែលទៅជាមួយនាក់បើកឡានជាមួយគ្នាហ្នឹង ។

**ស៖** ឡានឡង់រូវ៉ែមួយហ្នឹង អាចដឹកអ្នកដែលត្រូវចាប់ខ្លួនបញ្ជូនពីខេត្តពីតំបន់នានាមកកាន់ទីក្រុងភ្នំពេញហ្នឹងបាន ផ្ទុកបានប៉ុន្មាននាក់ដែរ? អ្នកដែលត្រូវចាប់ខ្លួន យើងមិននិយាយអំពីកងការពារនោះទេនិយាយអំពីមនុស្សដែលត្រូវចាប់ខ្លួន ដឹកអាចបានប៉ុន្មាននាក់ទៅ? លោកនិយាយថាឡានឡង់រូវ៉ែ មួយគ្រឿង?

**ឆ៖** ឡានឡង់រីវ៉ែ មួយគ្រឿងគឺដឹកបានគ្នាប្រាំពីរ ប្រាំបីនាក់ ដែលជាអ្នកទោសដែលចាប់មក ។ ហើយអ្នកកងការពារទៅម្តងបួន ប្រាំនាក់ ជាមួយហ្នឹងក៏ជិះខាងមុខខ្លះ ជិះការពារខាងក្រោយខ្លះជាមួយគ្នាហ្នឹង ។ ហើយដូចទៅបាត់ដំបង គឺឡានឡង់រូវ៉ែ ផ្លូវឆ្ងាយគឺទៅឡានពីរ ។

**ស៖** របៀបនិងការឃុំគ្រោងអ្នកត្រូវចាប់ខ្លួនដាក់រថយន្តបញ្ជូនពីតំបន់នានា ដូចជាពីបាត់ដំបងពីស្វាយរៀង ឬក៏ពីតំបន់ពិសេសកំពង់សោម មកកាន់មជ្ឈមណ្ឌលមន្ទីរសន្តិសុខស-២១ ភ្នំពេញ ចាត់

ចែងយ៉ាងម៉េចទៅ? ទៅលើអ្នកដែលត្រូវចាប់ខ្លួននោះដូចជាការចងដៃ ដាក់ខ្នោះ ដាក់ខ្នោះជើង ចងរុំមុខ ឬក៏គេធ្វើយ៉ាងដូចម្តេច? ប្រព្រឹត្តចំពោះអ្នកដែលត្រូវចាប់ខ្លួនក្នុងអំឡុងពេលនៃការដឹកជញ្ជូនពីទីនោះមកកាន់មន្ទីរសន្តិសុខស-២១?

[០៩:៤៩:១៣]

**ឆ៖** បាទ, ខ្ញុំសុំជម្រាបលោកចៅក្រម! ការដឹកជញ្ជូនយកមកគឺទៅដល់គេចាប់បានហើយៗ គេចងស្លាបសេកមកក្រោយ ហើយចងក្រណាត់បិទភ្នែកឲ្យជិតទៀត ដល់ពេលពួកខ្ញុំទៅដល់ គឺដូរយកខ្នោះអូតូម៉ាទិកដាក់ ខ្នោះដៃមកក្រោយហ្នឹងហើយរៀបចំចងមុខឲ្យស្អាតមកវិញ កុំឲ្យអ្នកទោសស្គាល់ផ្លូវ ហើយលើកអ្នកទោសនោះដាក់ឡានឲ្យអង្គុយរៀបគ្នាស្រួលហើយបាននាំគ្នាឡើងឡានមក ។

**ស៖** នៅក្នុងរថយន្តហ្នឹងមានខ្នោះជើងទេ? មានខ្នោះជើងអាខ្នោះធ្វើអំពីឈើ ឬក៏ខ្នោះធ្វើអំពីដែកជាស្នួរ ហើយក្នុងអំឡុងពេលនៃការដឹកជញ្ជូននោះក្រៅពីដាក់ខ្នោះដៃទៅក្រោយចងមុខ គឺមានដាក់ខ្នោះជើងទៀត?

**ឆ៖** ខ្ញុំសូមជម្រាបលោក! ពេលដែលដាក់ខ្នោះពីនោះមកហើយគឺអត់មានដាក់ខ្នោះជើងអីទៀតទេ ព្រោះអ្នកការពារប្រយ័ត្នប្រយែងណាស់ ព្រោះការពារមិនឲ្យងក់ទេម្នាក់ៗគឺការពាររហូតទាល់មកដល់កន្លែងគុកទួលស្លែងនេះវិញ ។

**ស៖** ចុះបើផ្លូវឆ្ងាយដល់ម្លឹង ឧបមាថាខេត្តបាត់ដំបងបីរយគីឡូ ហើយបីរយគីឡូម៉ែត្រសម័យនោះទិដ្ឋភាពផ្លូវដែលក្រោយសង្គ្រាមនោះវាមានការខូចខាតជាច្រើន ដោយសារថា មូលហេតុនៃទម្ងន់នៃការទម្លាក់គ្រាប់បែកផង នៃគ្រោះធម្មជាតិផ្សេងៗផង ហើយមិនបានជួសជុលសម័យសង្គ្រាមមានការលំបាកមែនទែន អាចចំណាយពេលវេលាច្រើន រហូតដល់ច្រើនថ្ងៃ ឬក៏មួយយប់មួយថ្ងៃឯណោះ ចម្ងាយបីរយគីឡូនោះ។ តើគាត់បត់ជើងបត់ដៃអីយ៉ាងម៉េចទៅអ្នកដែលត្រូវចាប់ខ្លួនបើលោករៀបចំដោយវិធីនៃការដាក់ខ្នោះទៅក្រោយ ដល់គាត់ត្រូវការបត់ជើងតូចបត់ជើងធំគាត់ធ្វើយ៉ាងម៉េច?

**ឆ៖** បាទ, ខ្ញុំសូមជម្រាប! ពេលដែលផ្លូវឆ្ងាយហ្នឹងទោះបីអ្នកទោសបត់ជើងបត់ដៃយ៉ាងម៉េចក៏ដោយក៏មិនប៊ានឲ្យឈប់បត់ជើងបត់ដៃទេ ព្រោះខ្លាចអ្នកទោសរត់រួច ។ អ៊ីចឹង អ្នកទោសជាធម្មតាអាចម៍នោមយ៉ាងម៉េច អាចម៍នោមទៅ ព្រោះម្នាក់ៗខ្លាចតែរឿងរួច ហើយផ្លូវតំបន់អស់នោះក៏ស្ងាត់ទៀត ។ អ៊ីចឹង ខ្លាចចេះតែបរបើកមកបណ្តោយ ។

[០៩:៥២:១៧]

**ស៖** លោកនិយាយអំមិញ វាលឿនបន្តិច តែយើងសួរតែម្តងទៅកុំឲ្យវាសន្ធឹងសំណួរនេះឡើងវិញថា តើលោកទៅដឹកជញ្ជូនឈ្លើយសឹកវៀតណាមនៅខេត្តស្វាយរៀង ទីមួយថាអំឡុងពេលឆ្នាំណាដែលលោកទៅដឹកជញ្ជូននោះ? ទីពីរ លោកដឹកជញ្ជូនពីខេត្តស្វាយរៀងមកកាន់មជ្ឈមណ្ឌលសន្តិសុខមន្ទីរស-២១ ទួលស្លែងភ្នំពេញនោះ អ្នកណាជាអ្នកបញ្ជាឲ្យទៅដឹកជញ្ជូន? ទីបីថា ដឹកប៉ុន្មានជើង? ហើយក្នុងមួយជើងៗមានគ្នាប៉ុន្មាននាក់? សរុបដែលលោកទៅដឹកជញ្ជូនមកហ្នឹងមានគ្នាប៉ុន្មាននាក់ជាឈ្លើយសឹកវៀតណាមនោះ?

**ឆ៖** បាទ, ពេលដែលខ្ញុំទៅហ្នឹងគឺទៅដឹកពីរជើង ។ ពីរជើងនោះ សរុបមានគ្នាដប់ប្រាំនាក់។

**ស៖** ហើយអ្នកណាជាអ្នកបញ្ជាឲ្យលោកទៅដឹកឈ្លើយសឹកវៀតណាមនោះ?

**ឆ៖** ខ្ញុំសូមជម្រាបគឺ តាឌុច គាត់ឲ្យនីរសារគាត់មកប្រាប់ខ្ញុំឲ្យទៅដឹកអ្នកទោសនៅស្វាយរៀងដែលជនជាតិវៀតណាម ។

**ស៖** ពេលលោកធ្វើដំណើរទៅដឹកអ្នកទោសនៅបាត់ដំបងក្តី នៅស្វាយរៀងក្តី នៅតំបន់ពិសេសកំពង់សោម តើលោកកាន់លិខិតធ្វើដំណើរ តើមានលិខិតធ្វើដំណើរដែរទេ? ហើយប្រសិនបើមានតើលិខិតធ្វើដំណើរហ្នឹងអ្នកណាជាអ្នកចេញឲ្យ? អ្នកណាជាអ្នកចុះហត្ថលេខានៅលើលិខិតដែលអនុញ្ញាតឲ្យលោកទៅដឹកជញ្ជូនមនុស្ស? ទៅធ្វើដំណើរទៅដឹកជញ្ជូនមនុស្សមកវិញដូច្នេះ? អ្នកណាគេ?

**ឆ៖** បាទ, លិខិតដើរផ្លូវនេះ គឺតាឌុច ។ ខ្ញុំយកបានពីតាហ៊ ទេ តាហ៊ឲ្យមកគឺលិខិតហ្នឹងស៊ីញ៉េចេញពី សុន សេន ។

**ស៖** លោកនិយាយពីខាងដើមមកវិញ ។ អំមិញយើងបានបង្អង់នូវសំណួររបស់យើងដោយសារលោកបានឆ្លើយពាក់ព័ន្ធទៅនឹងការបង្គាប់បញ្ជាដោយមានការដឹកនាំ ហ៊ ដែលជាអ្នកដឹកនាំប្រតិបត្តិការនៅក្នុងការដែលចាប់មនុស្សពីកន្លែងផ្សេងៗយកមកកន្លែងមន្ទីរសន្តិសុខស-២១ មជ្ឈមណ្ឌលភ្នំពេញ ។ សំណួរសួរថា ក្នុងប្រតិបត្តិការនៃការចាប់អំមិញនេះគឺយើងបញ្ជាក់ឡើងវិញ សំណួរអ្វីដែលលោកបាននិយាយគឺជាការដឹកជញ្ជូន ទៅទទួលមនុស្សដែលគេបានចាប់រួចហើយ គឺបន្លាស់ទីមនុស្សនោះពីបាត់ដំបងមកកាន់មជ្ឈមណ្ឌលមន្ទីរសន្តិសុខស-២១ ភ្នំពេញ ឬក៏ពីស្វាយរៀង ពីតំបន់ពិសេសកំពង់សោមយកមក ។ ឥឡូវនិយាយពីរឿងចេញចាប់វិញ បញ្ជាឲ្យចាប់ខ្លួន សួរថាតើប្រតិបត្តិការនៃការចាប់ខ្លួនហ្នឹងមានករណីណាខ្លះ? ហើយចាប់ខ្លួននៅទីណា? ចាប់មនុស្សនៅទីក្រុងភ្នំពេញ? ឬក៏លោកមានការចុះទៅចាប់នៅតាមតំបន់ ឬក៏ភូមិភាគនានាដែរឬទេ?

**ឆ៖** បាទ, ខ្ញុំសូមជម្រាប! ការចាប់ខ្លួនគឺចាប់ខ្លួននៅកន្លែងផ្សារថ្មីមួយកន្លែង ទទួលបទបញ្ជាពី តាហ៊ី ឲ្យខ្ញុំរៀបចំកម្លាំងទៅ ហើយគាត់ទទួលបញ្ជាពី តាឌុច មកទៀត ។ ពេលចាប់នោះ គឺពេលចាប់យប់ទៀត នៅកន្លែងផ្សារថ្មី ។

**ស៖** បទបញ្ជានោះជាបទបញ្ជាដោយផ្ទាល់មាត់ ដោយនិយាយតែមាត់ទទេ ឬក៏មានសរសេរជាក្រដាសស្នាមជាបទបញ្ជាឲ្យចាប់អ្នកណាៗមានសរសេរក្រដាសស្នាមហុចមកឲ្យលោកដែរ?

**ឆ៖** គាត់បញ្ជាតាមរយៈមកខាង តាហ៊ី មក ។ តាហ៊ី ឲ្យពួកខ្ញុំរៀបចំកម្លាំងទៅជាមួយគាត់ទៅ។

**ស៖** អ៊ីចឹងបានន័យថាកិច្ចប្រតិបត្តិការរបស់លោក គឺលោកទៅជាមួយ ហ៊ី ទេ ព្រោះហ៊ីជាអនុប្រធានជាអ្នកបញ្ជាលោកផ្ទាល់ អ៊ីចឹងមែនទេ?

**ឆ៖** បាទ ។

**ស៖** ចាប់នៅម្តុំផ្សារថ្មី ថ្ងៃដែលលោកនិយាយហ្នឹងចាប់មនុស្សប៉ុន្មាននាក់?

**ឆ៖** បាទ, ខ្ញុំភ្លេចចាំហើយ ព្រោះចាប់នោះដឹងតែពេលយប់ចាប់នៅកន្លែងនុ៎ង ។

**ស៖** មានចេញប្រតិបត្តិការចាប់មនុស្សផ្សេងទៀតទេ ក្រៅពីករណីផ្សារថ្មីដែលលោកលើកឡើងនេះ?

**ឆ៖** បាទ, មានពេលចាប់ដូចថាអ្នកមកពីប្រទេសបារាំងគឺគេនីរសារក្រុង គេបញ្ជូនមកកន្លែងខ្ញុំដែលនៅចាំទទួលអ្នកទោសនៅកន្លែងប៉ុស្តិ៍សំបុកឃ្មុំសព្វថ្ងៃហ្នឹង គឺនីរសារក្រុងគេបញ្ជូនយកមកមនុស្សច្រើនមកម្តង បួនដប់នាក់ៗ មកចាប់នៅកន្លែងខ្ញុំហ្នឹង ។

**ស៖** អ៊ីចឹងការទទួលបទបញ្ជា ហើយចេញប្រតិបត្តិការចាប់មនុស្សខាងក្រៅដែលលោកអះអាងថា ដឹកនាំដោយហ៊ី ដែលជាអនុប្រធាននៅមន្ទីរសន្តិសុខស-២១ មានបានទៅប្រតិបត្តិការនៅបណ្តាតំបន់ភូមិភាគនានាក្រៅពីទីក្រុងដែរឬទេ?

**ឆ៖** បាទ, គឺចាប់នៅក្រុងច្រើនជាង ។

**ស៖** ទៅចាប់មនុស្សនៅក្នុងក្រុងអ៊ីចឹងអត់មានក្រដាសស្នាម អត់មានរូបថត មានអីផង តើការទៅចាប់នោះយ៉ាងម៉េចមានច្រឡំមនុស្សដែរឬទេ? ឬក៏គេកំណត់នូវមុខសញ្ញាយ៉ាងម៉េចមុននឹងអនុវត្តការចាប់ខ្លួន?

[០៩:៥៩:៣៨]

**ឆ៖** បាទ, គេបានណែនាំពួកខ្ញុំហើយពេលដែលទៅចាប់ ទៅដល់នោះមានតែអ្នក មានតែកម្មា-ភិបាលគេមួយ ឬពីរនាក់គេអង្គុយមួយផ្នែក ហើយអ្នកដែលត្រូវជាប់ត្រូវការចាប់ខ្លួនគឺអង្គុយជុំគ្នាហ្នឹងដែរ តែមានសញ្ញារបស់គេសម្រាប់ឲ្យចាប់ ។

**ស៖** សញ្ញាសម្គាល់ដែលលោកជួបប្រទះហ្នឹង គេសម្គាល់សញ្ញាដោយវិធីយ៉ាងម៉េចទៅ? សញ្ញានៃមុខសញ្ញាដែលត្រូវចាប់ខ្លួន ។

**ឆ៖** បាទ, ដូចអង្គុយ ថាកម្មាភិបាលដែលគេនៅអង្គុយពីរនាក់ជាប់គ្នានៅក្បែរគ្នាហ្នឹង គឺយើងមិនអាចចាប់ខ្លួនទេ យើងចាប់ខ្លួនដែលអ្នកអង្គុយឃ្លាតបន្តិច ព្រោះគេដាក់កៅអីសម្រាប់ឲ្យអង្គុយដាច់ដោយឡែកពីគ្នា និងធ្វើការចាប់ខ្លួន ។

**ស៖** អ៊ីចឹងបានន័យថា កិច្ចប្រតិបត្តិការរបស់លោក ដែលដឹកនាំដោយ ហ៊ី ក្នុងការទទួលបញ្ជាចាប់មនុស្សនុ៎ង មិនដែលចេញទៅចាប់មនុស្សក្រៅផ្សេងពីមនុស្សនៅក្នុងទីក្រុងភ្នំពេញទេ អ៊ីចឹងមែនទេ?

**ឆ៖** បាទ ។ បើទៅតាមជនបទហ្នឹង តាមក្រៅ គឺដឹងតែចាំទទួលពីគេយកមក ប៉ុន្តែក៏ ហ៊ី ទៅជាមួយខ្ញុំ ទាំង ផល ទៅជាមួយខ្ញុំ ។ ជួនកាលដូរបាន ប៉េង ទៅជាមួយខ្ញុំទៀត ។

**ស៖** អម្បាញ់មិញលោកនិយាយដល់ចំណុចមួយថា លោកនៅប្រចាំការកន្លែងផ្ទះមួយដែលមានដាក់នូវវិទ្យុទាក់ទង ហើយទីនោះដែលគេស្គាល់ជាទូទៅ បច្ចុប្បន្ននេះ គឺស្ថានីយវិទ្យុសំបុកឃ្មុំ ហើយបច្ចុប្បន្នហ្នឹងនៅតាមដងផ្លូវវិថី៣៦០ ម្តុំខាងកើតនៃអង្គភាពរថយន្តពន្លត់អគ្គិភ័យ ។ មុខងារនៃកងការពារនៅទីនោះធ្វើអ្វីខ្លះ?

**ឆ៖** បាទ, មុខងារកងការពារនៅកន្លែងនោះ គឺដូចក្រុមរបស់ខ្ញុំ នៅចាំទទួលអ្នកទោសដែលគេបញ្ជូនមក ធ្វើម៉េចកុំឲ្យមានឡានគេចូលទៅដល់ក្នុង ចូលដល់ក្នុងគឺត្រូវតែទទួលខុសត្រូវ គេមិនឲ្យដឹងកន្លែងទេ ។ ហើយមួយទៀត ពួកខ្ញុំក្រៅពីការងារអស់ហ្នឹង គឺចាំទទួលអ្នកទោសដែលគេបញ្ជូនមក ឬមួយក៏ចាប់នៅចាំកន្លែងខ្ញុំ ខុសពីការងារហ្នឹងទៅ គេឲ្យចិញ្ចឹមសត្វ ចិញ្ចឹមអីនៅកន្លែងហ្នឹង ។

**ស៖** អំមិញលោកបាននិយាយថា ភារកិច្ចនៃក្រុមរបស់លោកគឺប្រចាំការនៅទីនោះ ហើយកាលបើគេបញ្ជូនមនុស្សមកដល់ គឺទីមួយ គឺចាប់ ចាប់បានន័យថា ចាប់មនុស្សហ្នឹងចងដាក់ខ្នោះ ។ មួយទៀតបានន័យថា មានមុខងារចាំទទួលមនុស្សដែលគេបញ្ជូនមកពីអង្គភាពនានា ។ មានន័យថា មនុស្សនុ៎ងគេចាប់ចងរួចហើយ គេដឹកបញ្ជូនមកដល់ គ្រាន់តែធ្វើការផ្ទេរផ្ទួរពីអង្គភាពដែលគេចាប់បញ្ជូនមកឲ្យលោក ហើយក្រុមលោកហ្នឹងបញ្ជូនបន្តទៅខាងក្នុងតែប៉ុណ្ណោះ អ៊ីចឹងមែនទេ?

[១០:០៣:៤៤]

**ឆ៖** បាទ, អ៊ីចឹងមែនលោក ។

**ស៖** លោកនិយាយមើលអំពីករណីអំមិញថា ពួកនីរសារក្រុង ដែលជាញឹកញាប់តែងតែចាប់មនុស្សមកពីខាងក្រៅប្រទេស ដែលចូលមកនៅក្នុងប្រទេសកម្ពុជា ។ គេបញ្ជូនមនុស្សនុ៎ង បញ្ជូនមកតាមរបៀបយ៉ាងម៉េច? មានដាក់ខ្នោះអីដែរទេ ឬក៏គេបញ្ជូនមកតាមធម្មតា ហើយគេនិយាយយ៉ាងម៉េចទើប ប្រតិបត្តិការរបស់លោកចាប់ផ្តើមធ្វើការចាប់មនុស្សទាំងនោះ? ហើយបញ្ជូនចូលក្នុងមន្ទីរសន្តិសុខ ស-២១ ។

**ឆ៖** បាទ, មុននឹងចាប់ខ្លួន គេមកប្រាប់មុនហើយ ប្រាប់មុនហើយ គេបញ្ជូនមនុស្សដែលមកពីបរទេសធ្វើការចាប់ខ្លួន ហើយគេក៏បកទៅវិញទៅ ហើយគេនឹងនាំកម្លាំងដឹកជញ្ជូនយកមក ។ ដឹកជញ្ជូនយកមកដល់កន្លែងផ្ទះខ្ញុំ ខ្ញុំក៏រៀបកម្លាំងចាំចាប់ ព្រោះតាមអ្នកឲ្យព័ត៌មានដឹង គឺ តាឌុច ហើយនិង តាហ៊ី ដែលអ្នកឲ្យព័ត៌មានដឹង ហើយអ្នកដែលមកប្រាប់ខ្ញុំ គឺ តាប៉ង់ ហើយអ្នកដែលមកប្រាប់ថា នឹងបញ្ជូនមនុស្សមកពេលអីឡូវនេះ ។

**ស៖** អ៊ីចឹងទទួលព័ត៌មានក្នុងការចាប់មនុស្សនេះ គឺមានប្រភពពីរ ។ ទីមួយគឺបញ្ជារបស់ ឌុច ហើយនិងអនុប្រធានរបស់គាត់គឺ ហ៊ី ឲ្យត្រៀមកម្លាំងដើម្បីទទួលមនុស្ស ។ ហើយមួយទៀត គឺទទួលពីនីរសារក្រុងដែលមានឈ្មោះ ប៉ង់ បានមកប្រាប់លោកផ្ទាល់ថា បន្តិចទៀតនឹងបញ្ជូនមនុស្សមកដល់ ហើយមានចំនួនជាក់លាក់ប៉ុន្មាននាក់ៗអ៊ីចឹង អ៊ីចឹងមែនទេ?

**ឆ៖** បាទ, អ៊ីចឹងមែនលោក ។

**ស៖** ចុះនីរសារក្រុងគេបញ្ជូនមនុស្សមកហ្នឹង ដែលគេចង គេដាក់ខ្នោះមកស្រេច ឬសុទ្ធតែបញ្ជូនមក គឺអត់មានដាក់ខ្នោះទេ របៀបថាប្រើវិធីផ្សេងៗ បញ្ជូនមកកាន់ទីនេះទីនោះទៅ មកដល់កន្លែងរបស់លោក ទើបលោកបញ្ជាឲ្យចាប់ខ្លួន សុទ្ធតែអ៊ីចឹងមែនទេ?

**ឆ៖** បាទ, ពេលដែលបញ្ជូនយកមក គឺមនុស្សទាំងអស់នោះក៏គេមិនទាន់ចាប់ឯណោះដែរ គេភូតថាឲ្យមកកន្លែងធ្វើការ ។ មកកន្លែងធ្វើការក៏ចេះមកជាមួយគេមក មកដល់កន្លែងខ្ញុំហ្នឹង ដឹងម៉ូគ្នាហើយ ខ្ញុំធ្វើការចាប់ខ្លួនឲ្យគាត់ចូលមកក្នុងបន្ទប់ ហើយអង្គុយនឹងតុ អង្គុយនឹងកៅអីហ្នឹង ហើយពួកខ្ញុំធ្វើការចាប់ខ្លួនពេលនោះតែម្តង ។

**ស៖** បញ្ជូនដោយនីរសារក្រុងដែលលោកបាននិយាយអម្បាញ់មិញនេះ ដែលមានឈ្មោះ ប៉ង់ ជាអ្នកសម្របសម្រួលរវាងមន្ទីរនីរសារក្រុងជាមួយនឹងសន្តិសុខស-២១ មានករណីរបៀបអ៊ីចឹងច្រើនទេ យើងសរុបប៉ាន់ស្មានប្រហែលជាប៉ុន្មាននាក់? ដែរបញ្ជូនដោយនិរសារក្រុងដែលលោកអះអាងថា អ្នកដែលមកពីបរទេស មានប្រហែលប៉ុន្មាននាក់ដែរ?

[១០:០៧:១៥]

**ឆ៖** បាទ, ខ្ញុំសូមជម្រាបលោក គឺច្រើនដែលគាត់យកមក គឺច្រើនណាស់ អ្នកដែលមកសុទ្ធតែនិស្សិតមកពីស្រុកបារាំង ហើយខ្ញុំមិនចាំថាមកប៉ុន្មាន គ្នាប៉ុន្មាននាក់ទេ តែច្រើនយកមក ។

**ស៖** អ៊ីចឹងគ្រប់ពេលដែលគេបញ្ជូនមក គឺគេសុទ្ធតែដឹកដោយរថយន្តមកដល់កន្លែងដែលលោកនៅប្រចាំការ អ៊ីចឹងមែនទេ?

**ឆ៖** បាទ, អ៊ីចឹងមែន ។

**ស៖** ចុះករណីផ្សេងទៀត ដូចជាខាងលោកដែលមានទទួលមនុស្សដែលត្រូវចាប់ខ្លួនពីអង្គភាពផ្សេងៗទៀតទេ ដូចជាអង្គភាពកងទ័ព អង្គភាពនៃស្ថាប័នមន្ទីរនានានៅក្នុងក្រុង ឬក៏ទីកន្លែងផ្សេងទៀតដែលគេបញ្ជូនមកពីតំបន់ភូមិភាគនានាគេបញ្ជូនមក តើគេបញ្ជូនរបៀបនៃខាងនីរសារក្រុង បញ្ជូនមក ឬក៏គេបញ្ជូនតាមរបៀបផ្សេង ដូចជាមានការចាប់ដាក់ខ្នោះ ឬក៏រុំមុខជាស្រេចបញ្ជូនមកដល់កន្លែងដែលលោកប្រចាំការនោះ?

**ឆ៖** បាទ,ខ្ញុំសូមជម្រាប! គឺមានការខុសប្លែកគ្នាទាំងអស់ គឺតាមរយៈដែលក្រសួង និងអង្គភាពកងទ័ពរបស់គេដោយខ្លួនៗពីគ្នា ដែលបញ្ជូនមកស-២១ ។

**ស៖** ខុសៗយ៉ាងម៉េចខ្លះទៅ? លោកអាចនិយាយឲ្យច្បាស់បានទេ លើភាពខុសគ្នានេះ លក្ខណៈដែលលោកថាខុសគ្នាទៅតាមអង្គភាពនីមួយៗហ្នឹង ខុសគ្នាយ៉ាងម៉េច?

**ឆ៖** បាទ, ខ្ញុំជម្រាបថា ដូចជាអង្គភាពកងទ័ព ដូច៣១០អ៊ីចឹង កងពល៣១០ ហ្នឹងបញ្ជូនមកគេចាប់បានមក គេបញ្ជូនមកខ្លួនគេតែម្តង ដាក់ឡានយកមក ដូចកន្លែងផ្សេងទៀតក៏គេបញ្ជូនមកខ្លួនគេសុទ្ធតែដាក់ខ្នោះហើយ ។

**ស៖** ក្រៅពីក្រុមនីរសារក្រុង តើគេមានប្រើវិធីនៃការនិយាយភូតកុហក ថាផ្លាស់ប្តូរកន្លែងធ្វើការដោយដឹកជញ្ជូនមនុស្សដែលត្រូវចាប់ខ្លួនហ្នឹងមកក្នុងលក្ខណៈធម្មតា មិនបានចាប់ខ្លួន មិនបានវៃដាក់ខ្នោះ ឬក៏ចងមុខទេ មកធម្មតា មកដល់ទីកន្លែងលោកទើបអនុវត្តប្រតិបត្តិការដូចដែលលោក ក្រុមលោកធ្លាប់

បានធ្វើចំពោះមុខសញ្ញានៃមនុស្សដែលបញ្ជូនមកពីខាងនីរសារក្រុងដែរឬទេ?

[១០:០៩:៥១]

**ឆ៖** បាទ, ហ្នឹងក៏មានដែរ ។ គេបោកប្រាស់យកមកឲ្យចាប់ខ្លួននៅកន្លែងហ្នឹងក៏មានដែរ ។

**ស៖** អ៊ីចឹងមានន័យសរុបមកវិញ មានន័យថា កន្លែងក្រុមលោកដែលគេបានចាត់ឲ្យប្រចាំការនៅកន្លែងដែលផ្ទះមួយដែលមានវិទ្យុដាក់ប្រចាំការនោះ គឺការទទួលមនុស្សមានពីរប្រភេទ ។ ទីមួយគឺមនុស្ស ដែលគេរៀបចំប្រើល្បិចបោកប្រាស់គាត់ ឲ្យមកថាប្តូរកន្លែងធ្វើការ មកជាមនុស្សធម្មតា ហើយមកដល់ទីនេះទើបអនុវត្តប្រតិបត្តិការក្នុងការចាប់ខ្លួនគាត់ អានេះមួយបែប ។ ហើយមួយបែបទៀតបានន័យថា អង្គភាពសាមីរបស់គេនោះ គេបានធ្វើការអនុវត្តចាប់ចងមនុស្សរួចហើយ ហើយដឹកយកមកប្រគល់ឲ្យអង្គភាពរបស់លោក ដើម្បីចាប់បញ្ជូនចូលទៅក្នុងតែម្តង អ៊ីចឹងមែនទេ?

**ឆ៖** បាទ, អ៊ីចឹងមែនលោក ។

**ស៖** ក្នុងប្រតិបត្តិការក្នុងការទទួលមនុស្ស អង្គភាពរបស់លោកធ្វើការយ៉ាងម៉េចទៅ? ធ្វើការតែពេលថ្ងៃទេ ឬក៏ធ្វើការទាំងពេលយប់ដែរ? ហើយបើធ្វើការពេលយប់ម៉ោងប៉ុន្មានសម្រាក ដែលមិនទទួលធ្វើការ? ឬក៏ទទួលធ្វើការដោយមិនកំណត់ពេលទេ ពេលណាក៏យើងប្រតិបត្តិការ ក៏ធ្វើការបានដែរក្នុងការទទួលមនុស្ស?

**ឆ៖** បាទ, សូមជម្រាបថា អត់មានពេលវេលាដែលសម្រាកទេ គឺមានពេលវេលាធ្វើការរហូតតែម្តង អត់ទៀង ។

**ស៖** អ៊ីចឹង គឺធ្វើការជាអចិន្ត្រៃយ៍បានន័យថា ទាំងយប់ទាំងថ្ងៃ មកដល់ពេលណា គឺចាត់ការពេលនោះ មានន័យថាអ៊ីចឹងទេ?

**ឆ៖** បាទ, ខ្ញុំសូមជម្រាបថា ការងារដែលចាប់ ការងារដែលបញ្ជូន ការងារដែលទទួល គឺនៅពេលដែលគេបញ្ជាមក គឺពួកខ្ញុំទៅ ក្រៅពីការងារហ្នឹង គឺផ្លាក់ដីចិញ្ចឹមសត្វ ចិញ្ចឹមអីធម្មតា ។

**ស៖** អ៊ីចឹង បានន័យថាក្រុមរបស់លោកមិនមែនទៅអង្គុយ ឬក៏ឈរធ្វើការនៅទីនោះជាអចិន្ត្រៃយ៍ទេ ការងារគឺអាស្រ័យទៅលើបទបញ្ជា បើបទបញ្ជាថា ឲ្យព័ត៌មានថាត្រូវប្រចាំការដើម្បី ទទួលមនុស្សគឺទើបទៅប្រចាំការនៅទីនោះ ហើយការប្រចាំការនោះ គឺមិនកំណត់ពេលទេ ពេលណាក៏ដោយឲ្យទទួលបញ្ជា យប់ក៏ដោយ ថ្ងៃក៏ដោយ ជិតភ្លឺក៏ដោយ ឲ្យតែមានបទបញ្ជាគឺអនុវត្តដាច់ខាត អ៊ីចឹងមែនទេ?

**ឆ៖** បាទ, អ៊ីចឹងមែនលោក ។

[១០:១២:៥៧]

**ស៖** ចុះកន្លែងសម្រាក ស្នាក់នៅផ្ទះរបស់លោកស្នាក់នៅកាលនោះ ក្រុមលោកនោះនៅឯណា នៅកន្លែងណា? ឬក៏សម្រាកនៅទីនោះតែម្តង ដេក កន្លែងដេក កន្លែងស្នាក់នៅក្នុងជីវភាពឯកជនប្រចាំថ្ងៃ រៀងរាល់ថ្ងៃនុ៎ងនៅកន្លែងណា?

**ឆ៖** បាទ ខ្ញុំសូមជម្រាបលោក គឺកន្លែងចាប់នុ៎ងជាកន្លែងដេកនៅរហូតតែម្តង ជាអចិន្ត្រៃយ៍ ។

**ស៖** ឥឡូវលោកនិយាយអំពីដំណើររឿងនៃការចាប់មនុស្ស ឬក៏ទទួលមនុស្សពីកន្លែងដែលលោក ក្រុមលោកបានទទួលការងារប្រចាំការមកក្នុងវិញ តើប្រព្រឹត្តទៅយ៉ាងដូចម្តេច មកក្នុងបានន័យថា មកសំដៅអគារឃុំខ្លួននានានៅក្នុងបរិវេណនៃមន្ទីរស-២១ តើប្រព្រឹត្តទៅយ៉ាងដូចម្តេច?

**ឆ៖** ខ្ញុំសូមជម្រាបលោក ពេលដែលមនុស្សដែលចាប់បានហើយ ឬមួយក៏ដឹកជញ្ជូនយកមក គឺយកមកចូលទៅក្នុងកន្លែងគុក ក្នុងបរិវេណគុក ទៅដល់កន្លែងនោះ គឺកន្លែងការិយាល័យរបស់បង សួស ធី ហ្នឹង គឺខ្ញុំប្រគល់ឲ្យទៅខាង បងធី ហ្នឹងទៅរួចបង ធី ហ្នឹងក៏ធ្វើឈ្មោះ ធ្វើអីកត់ឈ្មោះ កត់អីហើយ បានទៅខាងអ្នកថតរូប គេថត ថតហើយគេដាក់ស្លាក ដាក់អីគេហ្នឹង ថតហើយ ហើយក៏គេយកទៅឲ្យបង ធី ហ្នឹងយកទៅឲ្យឈ្មោះ ប៉េង មើលតាមបន្ទប់ណាដែលនេះ គេដាក់តាមបន្ទប់មួយៗ ដែលបន្ទប់តូចៗ ។

**ស៖** អ៊ីចឹងមានន័យថា ក្រុមរបស់លោកប្រតិបត្តិការ គឺគ្រាន់តែជញ្ជូនមនុស្សពីកន្លែងផ្ទះដែលជាប៉ុស្តិ៍ប្រចាំការទទួលមនុស្ស ដែលគេបញ្ជូនពីខាងក្រៅមក ហើយបញ្ជូនទៅដល់ត្រឹមតែកន្លែងថតរូប ឬក៏កន្លែងធ្វើការដកស្រង់នូវជីវប្រវត្តិរបស់អ្នកទោស ឬក៏អ្នកចាប់ខ្លួនតែប៉ុណ្ណឹងទេ ។ ចប់ពីហ្នឹង គឺក្រុមហ្នឹង គឺដកកម្លាំងមកវិញហើយ ឬមួយក៏កម្លាំងរបស់លោកហ្នឹងនៅរង់ចាំបន្តក្នុងការបញ្ជូនមនុស្សយកទៅដល់កន្លែងឃុំឃាំងទៀត ឬក៏ចាប់ពីនោះទៅមានកម្លាំងផ្សេងទៀតគេអ្នកទទួលបន្ទុក?

**ឆ៖** បាទ, ខ្ញុំសូមជម្រាបលោក ពេលកម្លាំងពួកខ្ញុំដែលបញ្ជូនចូលទៅដល់កន្លែងបង សួស ធី កន្លែងការិយាល័យសួរឈ្មោះ ថតរូបហ្នឹងហើយ ដែលគេធ្វើឈ្មោះថតហើយអីហើយហ្នឹង គឺខាងកម្លាំងប៉េង យកទៅដាក់បន្ទប់តូចៗហ្នឹង ។

**ស៖** អ៊ីចឹងបានសេចក្តីថា ការផ្លាស់ប្តូរកម្លាំងរវាងក្រុមរបស់លោក ដែលជាអ្នកការពារខាងក្រៅក្នុងការបញ្ជូនមនុស្សចូលហ្នឹង គឺត្រូវផ្ទេរផ្ទួរគ្នាត្រឹមកន្លែងដែលឈ្មោះ ធី ជាអ្នកធ្វើបញ្ជីឯកសារ ហើយនិងមានការថតរូប ។ ត្រឹមហ្នឹង គឺមានការផ្ទេរផ្ទួរកម្លាំងគ្នា ប្រគល់ឲ្យកម្លាំងខាងកងការពារ

ខាងក្នុង ឯចំណែកក្រុមកម្លាំងខាងលោកដកចេញមកខាងក្រៅវិញ ដកខ្លួនមកខាងក្រៅ អ៊ីចឹងមែនទេ?

**ឆ៖** បាទ, អ៊ីចឹងមែនលោក ។

**ស៖** និយាយពីដំណើរនៃការជញ្ជូនមនុស្សទៅពីកន្លែងបច្ចុប្បន្នយើងងាយយល់ គឺថាកន្លែងធ្វើការយាមប្រចាំប្រការរបស់ក្រុមលោក គឺស្ថានីយ៍នៃវិទ្យុសំបុកឃ្មុំបច្ចុប្បន្ននេះទៅដល់ រហូតដល់កន្លែងទទួលប្រគល់មនុស្សនៅខាងបរិវេណខាងក្នុងនៃទួលស្លែងបច្ចុប្បន្ននេះ ។ តើប្រព្រឹត្តទៅយ៉ាងដូចម្ដេច? ដាក់ដឹកឡានទៅទៀត ឬក៏បណ្ដើរទៅទេ? ហើយបើបណ្ដើរទៅ បណ្ដើរអ្នកដែលត្រូវចាប់ខ្លួនតាមរបៀបយ៉ាងម៉េច? ក្នុងករណីតិចនាក់ ហើយក្នុងករណីដែលមានមនុស្សច្រើននាក់ តើលោកគេធ្វើ-- ក្រុមរបស់លោកធ្វើចាត់ការហ្នឹងយ៉ាងដូចម្ដេចទៅ?

**ឆ៖** បាទ, កម្លាំងដែលពួកខ្ញុំចាប់បាន គឺថាកម្លាំងគេបញ្ជូនមកច្រើនអ៊ីចឹង គឺថាមកទាំងឡានអ៊ីចឹង គឺកម្លាំងគេចងហើយពីនោះមក គឺគេយកខ្សែៗមួយស៊កតាមដៃទាំងអស់ ហើយដឹកយកទៅចូលទៅក្នុងគុក ។ ដឹកបន្តិចៗទៅ ព្រោះពេលដឹកទៅហ្នឹង គឺចងមុខចងអីជិតមើលផ្លូវមិនឃើញទេ ។

ហើយពេលខ្លះដែលគេបញ្ជូនយកមកច្រើន គឺចូលគុកហ្នឹងៗ គឺហៅឡើងទៅលើផ្ទះ គេបិទទ្វារចាក់សោរតែម្ដង ។ ហើយគេឲ្យដោះសម្លៀកបំពាក់ចេញអស់រលីង អាហ្នឹងអត់មានតដៃជាមួយខាងសន្តិសុខបានទេ ។

[១០:១៨:៤៨]

**ស៖** មនុស្សដែលមកដល់កន្លែងលោក ហើយក្រុមលោកអង្គភាពរបស់លោកជាអ្នកទទួលខុសត្រូវក្នុងការចាប់បញ្ជូនបន្តទៅខាងក្នុង ដើម្បីចាត់ចែងក្នុងការដាក់គុក ឬក៏យើងប្រើពាក្យថា ឃុំឃាំងនោះ តើកម្រិតមនុស្សដែលច្រើនអតិបរិមានៅក្នុងលើកណាដែលថា វាច្រើនជាងគេបំផុតហ្នឹង មានចំនួនប្រហែលជាប៉ុន្មាននាក់?

**ឆ៖** ច្រើនចូល ហា-ហុកសិបនាក់ មកអ្នកដែលមិនទាន់ចាប់ខ្លួនហ្នឹង ប៉ុន្តែចូលមកដល់កន្លែងៗគុកហ្នឹង គឺគេឲ្យចូលម្ដងមួយៗ ។

**ស៖** វាអត់ចង់ដឹងអ៊ីចឹងទេ ។ ចង់ដឹងពីកន្លែងលោក ទីកន្លែងដែលលោកប្រចាំការ កន្លែងពីវិទ្យុសំបុកឃ្មុំហ្នឹង បច្ចុប្បន្នហ្នឹងណា ទៅដល់កន្លែងឈ្មោះ ស្ទួស ធី ។ អាដំណើរហ្នឹង អាក្នុងការបញ្ជូនមនុស្សហ្នឹង អាតិបរិមាដែលលោកធ្លាប់បានឃើញ និងបានជួបហ្នឹង ទទួលមនុស្សដែលមានចំនួនច្រើនហ្នឹង ប៉ុន្មាននាក់?

**ឆ៖** បាទ, ពេលដែលមនុស្សដែលគេបញ្ជូនមកឲ្យពួកខ្ញុំហ្នឹង គឺចំនួនហា-ហុកសិបនាក់ ហើយហា-ហុកសិបនាក់ហ្នឹង គឺដាក់ខ្សែតែម្តង ដាក់ខ្សែដោតខ្សែតាមប្រឡោះដៃហ្នឹង ព្រោះគ្នាច្រើន ហើយកម្លាំងរបស់ខ្ញុំតិច ។ បានបញ្ជូនទៅចូលទៅឲ្យខាងបង ធី ហ្នឹងទៅ ។

**ស៖** ដោតខ្សែទៅ ដល់ពេលបណ្តើរចូលទៅហ្នឹង កម្លាំងរបស់លោកមានគ្នាប៉ុន្មានដែរ? បើមនុស្ស ដល់ ហា-ហុកសិប នាក់អ៊ីចឹង កម្លាំងៗកងការពារដែលនាំចូល នាំអ្នកទាំងនោះចូលទៅក្នុងអគារដើម្បីឃុំខ្លួនហ្នឹង ត្រូវប្រើកម្លាំងប៉ុន្មាននាក់ដែរ?

**ឆ៖** បាទ, ដោតខ្សែហ្នឹង គឺកម្លាំងប្រាំមួយ ប្រាំពីរនាក់ គឺកាន់តែខ្សែហ្នឹង ធ្វើម៉េចឲ្យតឹងកុំឲ្យអ្នកទោសហ្នឹង ដួល ហើយបណ្តើរទៅរហូតទៅ ហើយចេះប្រាប់ទៅកាច់ទៅផ្លូវនេះផ្លូវនោះៗ ។

**ស៖** អ្នកដឹកខ្សែហ្នឹង មានដឹកខ្សែដឹកមុខ ដូចយើងដឹកគោ ដឹកក្របីដែរទេ? បានន័យថា មានខ្សែអ៊ីចឹងហើយ មានអ្នកដើរពីមុខ ។ បានន័យថា សន្តិសុខម្នាក់ហ្នឹងដើរពីមុខ ទាញខ្សែហ្នឹងដើរតម្រង់ផ្លូវអ៊ីចឹងមែនទេ?

[១០:២១:២២]

**ឆ៖** បាទ, គឺម្នាក់គឺដើរតម្រង់ផ្លូវទៅ បើមិនអ៊ីចឹងអ្នកទោសអត់ដឹងផ្លូវថា ទៅច្រកណា គឺម្នាក់គឺកាន់ដើរទៅមុនអ៊ីចឹងហើយអ្នកនៅចំហៀង គឺកាន់ធ្វើម៉េចឲ្យខ្សែតឹងទៅកុំឲ្យអ្នកទោសហ្នឹងដួល ហើយផ្លូវណាកាច់ គឺកាច់តាមគ្នាហ្នឹងរហូត ។

**ស៖** នៅក្នុងការសិក្សាសំណុំរឿងមានករណីមួយ ដែលមានចំនួនច្រើននាក់ គឺជាកម្មាភិបាលកងទ័ពនៃកម្លាំងភូមិភាគបូព៌ា ដែលបានបញ្ជូនមកដល់មន្ទីរសន្តិសុខស-២១ មានចំនួនច្រើនរហូតដល់បីរយនាក់ ។ សំណួរសួរថា តើកន្លែងរបស់លោកហ្នឹង មានដែលទទួលមនុស្សម្តង ឬក៏មួយថ្ងៃរហូតដល់បីរយនាក់ដែរឬទេ? ហើយប្រសិនបើទទួលរហូតដល់បីរយនាក់ហ្នឹង តើចំណាត់ការនៃក្រុមរបស់លោក ដើម្បីចាប់បញ្ជូនពីចំណុចទទួល ហើយនិងមកទៅប្រគល់ទៅខាងក្នុងហ្នឹង ប្រព្រឹត្តទៅយ៉ាងដូចម្តេច?

**ឆ៖** បាទ, ខ្ញុំសូមជម្រាបថា អ្នកដែលយកមកច្រើនអ៊ីចឹង គឺឲ្យគេឈប់ត្រឹមកន្លែងពួកខ្ញុំ ហើយពួកខ្ញុំដែលអ្នកបើកបរឡានហ្នឹង គឺសុំឡានគេបើកចូលតែម្តង ចូលទៅគុកតែម្តង ។ ម្តងមួយឡានៗចូលទៅ ។

**ស៖** លោកនិយាយអំមិញថា កិច្ចការប្រតិបត្តិការទាំងអស់ គឺ ឌុច ដែលជាប្រធានមន្ទីរស-២១ ជាអ្នកបញ្ជា ហើយទៅបញ្ជារទៅលើ ហ៊ី ហើយ ហ៊ី ក៏បញ្ជាមកក្រុមរបស់លោក ថ្នាក់ក្រោមទៀត ដើម្បីអនុវត្ត ហើយក្នុងករណីខ្លះ គឺ ហ៊ី ក្នុងប្រតិបត្តិនោះ គឺ ហ៊ី ទៅដែរ គឺក្រោមការដឹកនាំផ្ទាល់របស់គាត់ក្នុងនាមជាអនុប្រធាន ។ សំណួរសួរថា តើលោកដឹងទេថា បទបញ្ជារបស់ ឌុច ចំពោះ ហ៊ី ហ្នឹង គេប្រើប្រាស់បទបញ្ជាយ៉ាងដូចម្តេច? ជាលាយលក្ខណ៍អក្សរ ឬក៏បញ្ជាដោយផ្ទាល់មាត់?

**ឆ៖** ខ្ញុំអត់បានដឹងដែរលោក តាមបញ្ជានេះ គឺព្រោះ គាត់មានទូរស័ព្ទដៃមួយម្នាក់ទាំងអស់។ ដឹងគាត់និយាយតាមទូរស័ព្ទហ្នឹង ឬមួយក៏ក្រដាសនីរសារគាត់យកមកឲ្យក៏មិនដឹងដែរ ។

**ស៖** និយាយពីក្រុមរបស់លោក លោកទទួលបញ្ជាផ្ទាល់ជាទូទៅពីអនុប្រធានរបស់លោកឈ្មោះ ហ៊ី ឬក៏លោកទទួលបញ្ជាក្នុងការប្រតិបត្តិការផ្សេងផ្ទាល់ពីជនជាប់ចោទឈ្មោះ ឌុច?

**ឆ៖** បាទ, ខ្ញុំសូមជម្រាបថា ទទួលបញ្ជាភាគច្រើនខ្ញុំទទួលពី តាហ៊ី ព្រោះ តាហ៊ី ជាប្រធានរបស់ខ្ញុំផ្ទាល់ ។ តាឌុច គាត់ប្រធានលើ តាហ៊ី អ៊ីចឹងគាត់បញ្ជាមក តាហ៊ី ។បានបញ្ជាមកលើក្រុមពួកខ្ញុំ ។

**ស៖** លោកដែលទទួលបញ្ជាផ្ទាល់ពីជនជាប់ចោទឈ្មោះ ឌុច ដែរឬទេ?

[១០:២៥:១៧]

**ឆ៖** បាទ, ខ្ញុំសូមជម្រាបថា ខ្ញុំក៏ធ្លាប់បានទទួលបញ្ជាពីគាត់ដែរ ។

**ស៖** ក្នុងករណីណាខ្លះទៅ? លោកអាចរៀបរាប់ករណីដែលលោកទទួលបញ្ជាផ្ទាល់ពីជនជាប់ចោទឈ្មោះ ឌុច ក្នុងការអនុវត្តដែរឬទេ?

**ឆ៖** បាទ, ខ្ញុំសូមជម្រាបថា ឌុច គាត់ឲ្យខ្ញុំទៅស្វាយរៀងទៅយកកងទ័ពវៀតណាម ដែលចាប់ខ្លួនបានហ្នឹង គឺបញ្ជាពីគាត់ឲ្យទៅ ។

**ស៖** ក្នុងអំឡុងពេលដែលលោកទៅ បានទៅធ្វើការនៅមន្ទីរសន្តិសុខស-២១ មជ្ឈមណ្ឌលភ្នំពេញហ្នឹង តើលោកបានទទួលព័ត៌មាន ឬក៏បានដឹងអំពីព្រឹត្តហេតុដោយឡែកផ្សេងទៀត ដែល ឌុច ខ្លួនឯងផ្ទាល់ក្នុងនាមជាប្រធានមន្ទីរស-២១ បានអនុវត្តនូវប្រតិបត្តិការចាប់ខ្លួនមនុស្សដែរឬទេ? បានន័យថា ចាប់ខ្លួន ដោយខ្លួនគាត់ផ្ទាល់ក្នុងការបញ្ជាចាប់ក្នុងប្រតិបត្តិការក្នុងការចាប់ខ្លួនមនុស្ស ។ តើលោកដឹងអំពីព្រឹត្តហេតុហ្នឹងដែរឬទេ? តើមានករណីហ្នឹងដែរឬទេ?

**ឆ៖** បាទ, មានក្នុងករណីហ្នឹង តែគាត់មិនចាប់ផ្ទាល់ខ្លួនគាត់បានទេ ព្រោះមាឌតូចជាងគេកាលនោះ ។ គាត់បញ្ជាមកលើពួកខ្ញុំ និង-- ដូចថា ពួកផ្សេងដូច ពួក ប៉េង ពួក ផល អីក៏គាត់បញ្ជាបានដែរ ។

**ស៖** ការបញ្ជាផ្ទាល់ហ្នឹងក្នុងករណីណាខ្លះទៅ? លោកអាចនិយាយរៀបរាប់បានទេ? យើងនិយាយក្របខ័ណ្ឌតែបញ្ជាចាប់ខ្លួនទេ ព្រោះយើងនិយាយក្នុងអង្គហេតុពាក់ព័ន្ធក្នុងការចាប់ខ្លួន ក្នុងការបញ្ជូនមនុស្សចូលមកស-២១ ចំពោះអង្គហេតុផ្សេងមិនទាន់ដល់ដំណាក់កាលត្រូវសួរទេ ។ អ៊ីចឹងហើយយើងសួរអំពីអង្គហេតុពាក់ព័ន្ធនឹងការចាប់ខ្លួន ។ ករណីដែលគាត់បញ្ជាផ្ទាល់ក្នុងការចាប់ខ្លួនមនុស្សនេះ ដែលថាគាត់មិនធ្វើខ្លួនគាត់ទេ គាត់បញ្ជាអ្នកផ្សេងៗទៀត ។ តើករណីណាខ្លះដែលលោកដឹង តាមលោកដឹង?

**ឆ៖** បាទ, តាមខ្ញុំដឹង គឺគាត់ហៅពួកខ្ញុំណែនាំ ចាប់ តាប៉ង់ នៅផ្ទះគាត់ ។

**ស៖** ប៉ង់ ដែលលោកនិយាយអំមិញថា នីរសារក្រុងហ្នឹងមែនទេ តែងតែនាំមនុស្សមកពីបរទេសនិស្សិតមកពីបរទេសមកប្រគល់ឲ្យលោក ដើម្បីបញ្ជូនបញ្ចូលទៅក្នុងគុក ប៉ង់ ហ្នឹងមែនទេ?

**ឆ៖** បាទ, គឺតាប៉ង់ ដែលគាត់ហៅពួកខ្ញុំណែនាំឲ្យចាប់ខ្លួន តាប៉ង់ ហ្នឹង ។

**ស៖** លោកនិយាយអំពីប្រតិបត្តិការក្នុងការចាប់ខ្លួនឈ្មោះ ប៉ង់ ហ្នឹងមើល៍ តើការប្រព្រឹត្តទៅយ៉ាងដូចម្ដេច?

[១០:២៨:៤១]

**ឆ៖** បាទ, ខ្ញុំសូមជម្រាបថា ពេលដែលធ្វើការចាប់ខ្លួន តាប៉ង់ ហ្នឹង គឺគាត់អប់រំណែនាំពួកខ្ញុំចាប់អ្នកសំខាន់ម្នាក់គឺ បងប៉ង់ ។ ពេលដែលម៉ោងប៉ុន្មានៗ គាត់មកដល់គឺពួកខ្ញុំលាក់ខ្លួន លាក់ខ្លួនហើយតាប៉ង់ ហ្នឹងជិះម៉ូតូចូលមក គឺចូលផ្ទះគាត់ ហើយអង្គុយជាមួយគាត់ ពួកខ្ញុំចាប់ខ្លួនតែម្ដង ។

**ស៖** អ៊ីចឹងបានន័យថា យើងបាននិយាយគ្នាពិភាក្សាគ្នារួចហើយអំពីមុខសញ្ញាត្រូវចាប់ គឺឈ្មោះ ប៉ង់ ហើយការចាប់នេះ គឺពេលដែលមកដល់ផ្ទះរបស់គាត់ ហើយគាត់ណែនាំថា ពេលដែលមកដល់ហើយរៀបចំអង្គុយស្រួលបួលហើយ ចាប់ផ្ដើមចាប់តែម្ដង ។ មានប្រើបញ្ជាថែមទៀតទេ ឬក៏មានជាម៉ូជាសញ្ញាអីផ្សេងៗទៀត លើកដើម្បីជាៗកំណត់ថា ដល់ពេលត្រូវចាប់ហើយទេ ឬក៏គ្រាន់តែនិយាយពិគ្រោះគ្នាជាមុន ហើយពេលមកដល់ គឺប្រតិបត្តិការតែម្ដង?

**ឆ៖** បាទ, ខ្ញុំសូមជម្រាប! គឺបានដាក់ម៉ូគ្នាហើយអស់ហើយ ពេលដែលចូលមក គឺបានអង្គុយៗបានបន្តិច គឺធ្វើការចាប់ខ្លួនតែម្ដង ។

**ស៖** ចុះការចាប់ខ្លួន ហ៊ុយ ស្រែ ឬក៏ នុន ហ៊ុយ លោកអំមិញ ហៅថា ហ៊ុយ ធំ ។ លោកដឹងពីព្រឹត្តិការណ៍នៃការចាប់ខ្លួន នុន ហ៊ុយ ហៅ ហ៊ុយ ស្រែ ដែលជាសមាជិកនៃគណៈកម្មាធិការ ស-២១ នៅព្រៃស ដែរឬទេ?

**ឆ៖** បាទ, ខ្ញុំសូមជម្រាបលោកប្រធាន! ការចាប់ខ្លួនបង ហ៊ុយ ស្រែ គឺខ្ញុំក៏នៅជើងឯកដែរ ។ ពេលដែលចាប់ខ្លួនហ្នឹង ក៏តាហ៊ី ឲ្យគេទៅហៅខ្ញុំមក ពេលនោះ គឺក្រុមរបស់ ប៉េង នៅភ្នំពេញ ហើយនិងពួក ប៊ូ ពួកអីហ្នឹងទៅជាមួយ ទុយ ជាមួយអីគ្នាច្រើនណាស់ ធ្វើការចាប់ខ្លួនគាត់ពេលនោះ គឺខ្ញុំទៅអត់ទាន់ដល់ផងគាត់ជិះម៉ូតូចូលទៅ គេធ្វើការចាប់ខ្លួនគាត់ហើយ ។ ខ្ញុំទៅដល់របងផ្ទះកន្លែងផ្ទះ លន់ ណុន ហ្នឹង ។

**ស៖** ផ្ទះ លន់ ណុន នៅកន្លែងណាទៅកាលនោះ?

**ឆ៖** បាទ, កន្លែងស្លាគូហ្នឹង ដែលហៅថា បាគូៗ ស្លាគូហ្នឹង ។

**ស៖** អ៊ីចឹងការចាប់ នុន ហ៊ុយ ហៅ ហ៊ុយ ស្រែ ដែលជាសមាជិកនៃគណៈកម្មាធិការគ្រប់គ្រងមន្ទីរស-២១ ហ្នឹង គឺចាប់នៅផ្ទះអតីតផ្ទះរបស់ លន់ ណុន គឺនៅស្លាគូ ឬក៏ហៅថា បាគូ ។ ហើយសំណួរសួរថា ថ្ងៃនោះមានវត្តមានជនជាប់ចោទឈ្មោះ ឌុច ដែរឬទេ?

**ឆ៖** បាទ, ខ្ញុំសូមជម្រាបនៅពេលនោះ គឺខ្ញុំអត់បានចាប់អារម្មណ៍មើលគាត់ទេ តែភ័យៗត្រង់ចាប់បងហ៊ុយ ខ្ញុំភ័យខ្លួនបណ្តោយ ។ ភ័យខ្លួនថា ខ្ញុំជិតដល់ថ្ងៃត្រូវចាប់ខ្លួនទៀតហើយ ព្រោះគាត់បំបែកខ្ញុំឲ្យទៅធ្វើស្រែហើយ គាត់នឹងអាចចាប់ខ្លួនខ្ញុំ ។ ពេលនោះ ខ្ញុំនៅមន្ទីរស-២១ ភ្នំពេញ ម៉ុក ងួន បានឆ្លើយដាក់ខ្ញុំថា ខ្ញុំមានគម្រោងធ្វើការបះបោរ ។ ក្រោយមកខ្ញុំឃ្លាំមើលកាំភ្លើងៗ ក្រោយមកគេដឹងថាពួកខ្ញុំនឹងអាចធ្វើការបះបោរ ព្រោះ តាហ៊ី បានទំនាស់ជាមួយគាត់បីដងហើយ ហើយមួយទៀត តាប៉ាងកងពល៧០៣ ចាប់ខ្លួនមក ខ្ញុំលួចសួរគាត់ៗគាត់ថា គាត់មកកន្លែងនេះ គាត់ឆ្លើយដាក់ អាហ៊ី ។ អ៊ីចឹងពួកខ្ញុំនឹងអាចជាប់គុកថ្ងៃណាមិនខាន បើអ៊ីចឹងចាប់បង ហ៊ុយ ស្រែ នេះ គឺខ្ញុំភ័យខ្លួនរហូត ញាក់សាច់ ។ ភ័យខ្លួនលែងគិតឃើញអីអស់ ។

**ប្រធានអង្គជំនុំ៖**

ឥឡូវហ្នឹង អង្គជំនុំជម្រះ ដោយឃើញថា សាក្សីគាត់មានការរំជួលចិត្តផង ហើយដល់ពេលត្រូវសម្រាកផង អ៊ីចឹងអង្គជំនុំជម្រះប្រកាសសម្រាកដប់ប្រាំបីនាទី រហូតដល់ម៉ោងដប់មួយខ្វះដប់នាទី សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចពិភាក្សាស្តាប់សក្ខីកម្មសាក្សីរូបនេះទៀត ។

មន្ត្រីតុលាការ សម្របសម្រួលរកកន្លែងសម្រាកសមរម្យសម្រាប់សាក្សីរូបនេះ នៅក្នុងអំឡុងពេលសម្រាក ហើយឱ្យនាំគាត់មកកាន់សាលសវនាការមុនម៉ោងដប់មួយខ្វះដប់នាទី ។

*[សវនាការសម្រាកពីម៉ោង ១០:៣៥នាទី ដល់ម៉ោង ១០:៥២នាទី]*

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយចុះ។ អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការស្តាប់សក្ខីកម្មសាក្សីឈ្មោះ ហ៊ីម ហ៊ុយ ។

**សួរដោយប្រធានអង្គជំនុំ៖**

លោក ហ៊ីម ហ៊ុយ អម្បាញ់មិញ យើងបានដល់ព័ត៌មានដែលបានទទួល គឺក្នុងកិច្ចប្រតិបត្តិការចាប់ខ្លួន នុន ហ៊ុយ ហៅ ហ៊ុយ ស្រែ ដែលជាសមាជិកនៃគណៈកម្មាធិការមន្ទីរសន្តិសុខ ស-២១ នៅបាគូ ឬក៏អ្នកខ្លះហៅថា ស្លាគូ នោះ ។

**ស៖** សំណួរបន្តសួរថា ការចាប់ខ្លួនហ្នឹងប្រព្រឹត្តទៅនៅពេលយប់ ឬពេលថ្ងៃ ហើយក្រោយពេលចាប់រួច តើគេចាប់បញ្ជូនគាត់មកកាន់កន្លែងណា? មកស-២១ មជ្ឈមណ្ឌលភ្នំពេញ ឬក៏បញ្ជូនទៅជើងឯកត្រង់តែម្តង?

**ឆ៖** បាទ, ខ្ញុំសូមជម្រាបលោក! ការចាប់ខ្លួនបង ហ៊ុយ ស្រែ គឺគេចាប់ហើយ គេយកដាក់ឡានយកភ្នំពេញ ។

**ស៖** ចុះប្រពន្ធកូនរបស់គាត់ត្រូវគេចាប់ខ្លួនដែរទេ?

**ឆ៖** បាទ, ខ្ញុំសូមជម្រាបលោក គឺគេចាប់ទាំងប្រពន្ធ ទាំងប្អូន បងហ៊ុយ ទាំងអស់ ។

**ស៖** ឥឡូវត្រឡប់មកបកក្រោយមកវិញ មកការចាប់ខ្លួន និងការបញ្ជូនមនុស្សចូលទៅមន្ទីរ ស-២១ ។ សំណួរមុននេះលោកបានឆ្លើយរួចហើយ ក្នុងការចាប់ករណីចាប់ ការបញ្ជូនមនុស្ស ដែលចាប់ខ្លួនបញ្ជូនមកពីខាងភូមិភាគបូព៌ា ដែលមានចំនួនច្រើនរយនាក់ក្នុងមួយលើកនោះ គឺរបៀបក្នុងការបញ្ជូនចូល ទទួល និងការបញ្ជូនចូលដោយសុំផ្ទេរ ដោយអ្នកបើកបរក្រុមមន្ទីរស-២១ របស់លោក ហើយបើករថយន្តដែលមានមនុស្សផ្ទុក អ្នកដែលចាប់ខ្លួននៅក្នុងនោះ ចូលទៅមន្ទីរសន្តិសុខស-២១ ផ្ទាល់ ទៅផ្ទេរផ្ទេរនៅទីនោះ ។ សំណួរថា តើការផ្ទេរផ្ទេរមនុស្សដ៏ច្រើនដូច្នេះហ្នឹង គេប្រព្រឹត្តទៅយ៉ាងដូចម្តេច? ពីព្រោះ

បែបបទដែលលោកបាននិយាយអំមិញ គឺចូលទៅត្រូវដកស្រង់នូវប្រវត្តិរូប ហើយបន្ទាប់មកទៀត គឺថតរូប ដែលមានដាក់ឈ្មោះ ដាក់ពាក់ផ្លាក ដាក់ឈ្មោះ ដាក់លេខសម្គាល់អីផ្សេងៗអ៊ីចឹង ។ ចុះករណីដែលដឹកមករថយន្តច្រើន ហើយរាប់រយនាក់ហ្នឹង ការប្រព្រឹត្តិទៅយ៉ាងដូចម្តេច ក្នុងការថតរូប នៅក្នុងការដកស្រង់នូវសាវតារ ប្រវត្តិរូបអ្នកទាំងនោះ ហើយនិងការបញ្ជូនទៅដាក់ឃុំឃាំងនោះ តើគេប្រព្រឹត្តទៅយ៉ាងដូចម្តេចលោកដឹងទេ?

**ឆ៖** បាទ, ខ្ញុំសូមជម្រាប! ពេលដែលគេដឹកពីខាងភូមិភាគបូព៌ាមកទាំងឡានៗហ្នឹង គឺសុំផ្ទេរកម្លាំងទាំងអ្នកបើកបរ ទាំងកម្លាំងកងការពារគេពីណោះមក គឺពួកខ្ញុំនិងកងការពារនៅស-២១ហ្នឹង គឺប្រមូលកម្លាំងមកជាច្រើន នាំគ្នាឡើងជិះឡានហ្នឹង ហើយអ្នកការពារនៅការពារច្រកទ្វារចូលហ្នឹងទៀត ។ ដល់ពេលទៅដល់ហ្នឹងគឺ គេខ្ទប់ឲ្យចេញតែម្នាក់ម្តងៗចូលទៅក្នុងកន្លែងគុកហ្នឹង ដើម្បីចាប់ខ្លួនម្នាក់ម្តងៗ ហើយបញ្ជូនទៅដាក់អគារខាងត្បូង ព្រោះអគារខាងត្បូងក៏មាន កន្លែងដែល បងធី នោះក៏មាន គឺគេធ្វើម៉េចកុំឲ្យអ្នកដែលចេញមកបន្តទៀតដឹងឃើញ គឺគេដាក់ទៅកន្លែងបន្ទប់បិទទ្វារជិត បញ្ចូលទៅម្តងមួយៗ ។

[១០:៥៨:០៣]

**ស៖** អ៊ីចឹង ករណីដែលមនុស្សបញ្ជូនមកច្រើនរបៀបនេះ មិនទាន់បានថតរូបភ្លាមទេ ថតរូប ឬក៏ដកស្រង់យកប្រវត្តិរូបនៃអ្នកដែលត្រូវចាប់ខ្លួនទាំងអស់នោះភ្លាមទេ មែនទេ?

**ឆ៖** បាទ, មនុស្សដែលគេចាប់មកច្រើនហ្នឹង គឺគេក៏មិនទាន់ធ្វើឈ្មោះទាន់ដែរ គឺគេចាប់ធ្វើម៉េចឲ្យខាងបានឲ្យអស់សិន ហើយគេនឹងចាំសួរម្តងមួយៗ កត់ឈ្មោះ និងធ្វើការថតរូបនៅពេលនោះ?

**ស៖** អរគុណ ។ នៅក្នុងការទទួលមនុស្ស ក្រុមរបស់លោកដែលមានភារកិច្ចក្នុងការទទួលមនុស្សដែលបញ្ជូនមកពីអង្គភាពផ្សេងៗនៅចំណុចមួយ ដែលយើងកំពុងតែនាំគ្នាថាស្គាល់ជាទូទៅគឺ បច្ចុប្បន្ននេះគឺស្ថានីយ៍វិទ្យុសំបុកឃ្មុំនោះ ។ សំណួរសួរថា តើមានមនុស្សដែលគេបញ្ជូនមកទីនេះសុទ្ធតែត្រូវបានបញ្ជូនបន្តចូលទៅឃុំឃាំងនៅមន្ទីរសន្តិសុខស-២១ ឬក៏មានការបញ្ជូនបែងចែកទៅទីកន្លែងណាផ្សេងខ្លះដែរឬទេ?

**ឆ៖** បាទ, ខ្ញុំសូមជម្រាបលោក! ដែលពេលគេបញ្ជូនអ្នកទោសយកមកចូលកន្លែងទួលស្លែងហ្នឹង គឺអ្នកដែលសំខាន់បានគេយកចូលគុក អ្នកដែលមិនសំខាន់គឺគេបញ្ជូនទៅព្រៃស ទៅខាង បងហ៊ុយស្រែ។

**ស៖** អ៊ីចឹងមានន័យថា មកដល់ចំណុចនេះ គឺមានការបែងចែកនៅមុខសញ្ញានៃមនុស្សដែលត្រូវចាប់ខ្លួនមកនោះ ថាមនុស្សសំខាន់ មនុស្សដែលត្រូវឃុំឃាំងនៅមន្ទីរសន្តិសុខស-២១ ភ្នំពេញ ទើបចាប់បញ្ចូល ។ ចំណែកឯ មុខសញ្ញាមួយចំនួនទៀតដែលមិនសំខាន់ គឺគេឲ្យចាប់បញ្ជូនទៅកន្លែងអប់រំកែប្រែសាជាថ្មីព្រៃស អ៊ីចឹងមែនទេ?

**ឆ៖** បាទ, អ៊ីចឹងមែនលោក ។

**ស៖** ការចាប់បញ្ជូនមនុស្សដែលមួយចំនួនទៅពីកន្លែងលោក ទៅកាន់មន្ទីរអប់រំកែប្រែព្រៃសហ្នឹងអ្នកណាជាអ្នកបញ្ជាឲ្យធ្វើដូច្នេះ?

**ឆ៖** បាទ, ខ្ញុំអត់បានដឹងច្បាស់ដែរទេ ព្រោះអ្នកដែលមានកំហុសល្មមៗ គឺនៅក្នុងស-២១ហ្នឹងមានតែ តាហ៊ី និង តាឌុច ហ្នឹងទេ ដែលជាអ្នកបញ្ជាឲ្យមានកម្លាំងឡាន ពួកឡានដឹកជញ្ជូនយកទៅព្រៃសហ្នឹង ដែលអ្នកមិនសំខាន់ ។

**ស៖** ក្នុងប្រតិបត្តិការនៃការដឹកជញ្ជូនមនុស្ស ពីចំណុចដែលទទួលមនុស្សអង្គភាពនានា ចំណុចដែលក្រុមលោកធ្វើការងារនោះទៅព្រៃស តើលោកខ្លួនឯងបានដែលទៅជាមួយការដឹកជញ្ជូនមនុស្សទៅកាន់ព្រៃសដែរឬទេ?

**ឆ៖** បាទ ខ្ញុំអត់បានទៅជាមួយទេ ពីព្រោះកម្លាំងពេលនោះ មិនដឹងជាកម្លាំងខាងណាទេ ខ្ញុំភ្លេចហើយ ប៉ុន្តែពួកផ្នែកការពារ ហើយនិងពួកអ្នកបើកឡាន ពួកខ្ញុំហ្នឹងជាអ្នកជូនយកទៅ ។

**ស៖** ក្នុងអំឡុងពេលដែលលោកប្រតិបត្តិការ លោកធ្វើការនៅក្រុមជាមួយក្នុងក្រុមទទួលមនុស្សដើម្បីបញ្ជូនចូលទៅក្នុងមន្ទីរសន្តិសុខស-២១ មជ្ឈមណ្ឌលភ្នំពេញ ក៏ដូចជាមួយចំនួនដែលត្រូវបំបែកបញ្ជូនទៅកន្លែងអប់រំកែប្រែសាជាថ្មីព្រៃស តើលោកដែលបានជួបកុមារដែរឬទេ?

**ឆ៖** បាទ, គឺដែលគេបញ្ជូនមកហ្នឹង គឺមានទាំងប្តីប្រពន្ធ មានទាំងកូនអីយកមក ។ តែពេលបញ្ជូនមានទាំងប្តី ទាំងកូនអីហ្នឹង ដែលអ្នកគេបញ្ជូនយកទៅព្រៃសហ្នឹង គឺនៅផ្ទះក្បែរផ្លូវជាតិខាងកើតគឺទុកនៅកន្លែងផ្ទះហ្នឹង ព្រោះមានកម្លាំងមួយក្រុមកាលណោះនៅកន្លែងហ្នឹងដែរ គេចាំមកជិះឡាននៅត្រង់ហ្នឹង យកឡានមកដាក់ត្រង់ហ្នឹង យកទៅព្រៃស ។

**ស៖** ចុះមនុស្សដែលចាប់បញ្ជូនចូលទៅក្នុងមន្ទីរសន្តិសុខស-២១ដើម្បីឃុំឃាំង សួរថាកូនរបស់គេដែលចាប់មកជាមួយហ្នឹង បញ្ជូនទៅក្នុងមន្ទីរសន្តិសុខស-២១ ដែរឬទេ? ឬក៏ត្រូវបំបែកយកទៅព្រៃសនិយាយពីរឿងកូនៗរបស់គេ កុមារតូចហ្នឹងណា?

**ឆ៖** បាទ, ខ្ញុំសូមជម្រាបថា កុមារហើយនិងម្តាយគេដែលអ្នកមិនសំខាន់ គឺគេយកទៅព្រៃស អ្នកណាដែលសំខាន់ ដូចជាឪពុកអីដែលមានការងារសំខាន់ គឺចូលគុក ។

**ស៖** អ៊ីចឹងបានន័យថា កុមារដែលជាកូនៗហ្នឹង ក៏គេបញ្ជូនទៅតាមភាពសំខាន់នៃ ឬក៏មិនសំខាន់នៃឪពុកម្តាយគេដែរ បើឪពុកម្តាយគេសំខាន់បញ្ជូនចូលទៅមន្ទីរសន្តិសុខ ស-២១ ឃុំឃាំងទីនោះ កូនក៏ត្រូវបញ្ចូលទៅកាន់ទីនោះជាមួយឪពុកម្តាយដែរ អ៊ីចឹងមែនទេ?

**ឆ៖** បាទ, អ៊ីចឹងមែនលោក ។

[១១:០៤:០៩]

**ស៖** ក្នុងអំឡុងពេលលោកធ្វើការងារនៅទីនោះ តើលោកដែលបានទទួលការបញ្ជូនមកដល់នៃជនជាតិបរទេសដែរឬទេ ក្រៅពីឈ្លើយសឹកវៀតណាម ដែលលោកបាននិយាយរួចហើយ សួរថាតើមានជនបរទេសផ្សេងទៀត ដែលបញ្ជូនមកដល់ទីនោះដែរឬទេ?

**ឆ៖** បាទ, ជនជាតិបរទេសនោះមិនដឹងជាចាប់មកពីខាងណាទេ គេយកមកចូលគុកហ្នឹងដែរ។

**ស៖** ការបញ្ជូនជនបរទេសហ្នឹងមក ឆ្លងកាត់តាមច្រកកន្លែងក្រុមរបស់លោកទទួលភារកិច្ចក្នុងការបញ្ជូនមនុស្សបញ្ចូលមកខាងក្នុងដែរឬទេ? ឬក៏គេបញ្ជូនផ្ទាល់ចូលទៅខាងក្នុងគុកដាក់ឃុំឃាំងតែម្តងដោយមិនឆ្លងកាត់ក្រុមរបស់លោកទេ?

**ឆ៖** បាទ, ពេលដែលជនជាតិបរទេសនោះ គឺខ្ញុំអត់បានដឹងទេ ព្រោះមានក្រុមផ្សេងទៀត ដែលគេទៅចាប់យកមក គេទទួលពីណាពីណើមក ខ្ញុំអត់បានដឹង ព្រោះពួកនោះគេទៅផ្សេង គេទៅយកមក ។

**ស៖** លោកស្គាល់ពួក “ហ្វុលរ៉ូ”ទេ ថាក្នុងអំឡុងពេលដែលលោកធ្វើការងារនៅក្នុងមន្ទីរស-២១ នោះ តើលោកដែលបានជួប ឬក៏បានទទួលពួកហ្វុលរ៉ូទេ?

**ឆ៖** បាទ, ខ្ញុំសុំជម្រាបលោក! ឃើញមាឌធំៗខ្ញុំថាបរទេស ប៉ុន្តែមិនដឹងជនជាតិអីៗ ក៏ខ្ញុំអត់ស្គាល់ដែរ ។

**ស៖** មាឌធំៗហ្នឹងមានគ្នាច្រើននាក់ទេ ហេតុម៉េចបានជាលោកដឹងថា មាឌធំៗមាឌ មនុស្សធំៗនៅទីនោះ បើលោកអត់បាននៅទទួលប្រតិបត្តិការក្នុងការទទួល និងបញ្ជូនចូលទៅក្នុងគុកផងនោះ ? ម៉េចបានលោកដឹងថា មានមនុស្សមាឌធំៗមកដល់ស-២១?

**ឆ៖** បាទ, ពេលនោះគឺខ្ញុំបានចូលទៅ ដូចថា តាហ៊ី ឲ្យចខ្ញុំចូលជួយម្តងម្កាលពេលដែលគេចាប់កម្លាំងមកច្រើនហ្នឹង អ្នកទោសមកច្រើនអ៊ីចឹង គឺខ្ញុំបានចូលទៅឃើញ ។ ឲ្យខ្ញុំចូលទៅជួយមើលគេម្តង

ម្កាលហ្នឹងខ្ញុំទៅ ទៅឃើញមាឌធំៗ ប៉ុន្តែ មិនដឹងជនជាតិអីខ្លះ ខ្ញុំអត់បានដឹងទេ ។

**សៈ** ស្បែកយ៉ាងម៉េចទៅស្បែក ស្បែកស សក់ខ្មៅ ឬក៏សក់ទង់ដែង ដែលលោកឃើញហ្នឹង ហើយមានគ្នាច្រើនទេ ចំនួនច្រើនទេ?

**ឆៈ** បាទ, កាលខ្ញុំឃើញហ្នឹង គឺបីបួននាក់ សុទ្ធតែសក់ស ហើយរោមដុះពេញខ្លួនទាំងអស់ ។

**សៈ** ពួកហ្វុលរ៉ូៗ ហ្នឹងមិនមែនពួកខាងហ្នឹងទេន៎ ពួកហ្វុលរ៉ូ ហ្នឹងពួកព្រៃភ្នំនៃខ្ពង់រាបខ្ពស់ ហើយជាប់ព្រំដែនកម្ពុជាវៀតណាម អ៊ីចឹងពួកហ្នឹងពួកអាស៊ីទេ ជាជនជាតិភាគតិច ជនជាតិភាគតិច មួយចំនួនឬក៏ខ្លះដែលនៅតាមដងព្រៃភ្នំ ដែលគេចាប់បញ្ជូនមក សួរថាមានទេ មានលោកដែលស្គាល់ទេ ស្គាល់ពួក ហ្វុលរ៉ូ ដែលជួបទេពួកហ្នឹង?

**ឆៈ** បាទ, ខ្ញុំមិនដឹងជាពួកណាៗទេ ប៉ុនបើខ្ញុំច្បាស់ជាងគេ គឺមានឧធំៗប៉ុន្មាននាក់ហ្នឹងគឺខ្ញុំ ស្គាល់ ។

**សៈ** បកក្រោយបន្តិច និយាយពីរឿងពួកវៀតណាម អំមិញលោកបាននិយាយហើយអំពីឈ្លើយ សឹកវៀតណាម លោកទៅទទួលពីខេត្តស្វាយរៀងមក ។ សំណួរទីមួយ ថាតើលោកទទួលនៅកន្លែងណា ខេត្តស្វាយរៀងក្នុងការទៅទទួលមនុស្ស ដែលលោកអះអាងថា ទៅយកពីរជើងនោះ? ទទួលត្រឹមត្រង់ ណាទៅដល់ណា? ត្រឹមស្វាយរៀង ឬក៏ទទួលទៅដល់សមរភូមិនៅព្រំដែនកម្ពុជាវៀតណាម?

[១១:០៨:៣៧]

**ឆៈ** បាទ, ពេលខ្ញុំទៅហ្នឹង គឺគុកគេនៅខាងត្បូងខេត្តហ្នឹង ប្រហែលជាបួនប្រាំរយម៉ែត្រហ្នឹង ។

**សៈ** កាលពីលោកទៅទទួលយកពួកឈ្លើយសឹកវៀតណាមពីខេត្តស្វាយរៀង ដែលគេឃុំឃាំង រួចហើយនោះមកកាន់មន្ទីរសន្តិសុខស-២១ហ្នឹង តើសម្លៀកបំពាក់ឯកសណ្ឋានរបស់ឈ្លើយសឹកនុ៎ង គេ ស្លៀកពាក់យ៉ាងម៉េចដែរ?

**ឆៈ** បាទ, ខ្ញុំសូមជម្រាបលោក! ឈ្លើយសឹកវៀតណាមដែលគេចាប់បាន គឺស្លៀកពាក់ខោអាវ ទាហាន និងមានសក្តិមានអីពាក់ទាំងអស់ ។

**សៈ** ក្រៅពីឈ្លើយសឹកវៀតណាម ដែលលោកបានទៅទទួលបញ្ជាពីជនជាប់ចោទឈ្មោះ ឌុច ទៅទទួលយកនៅខេត្តស្វាយរៀងមកកាន់មន្ទីរសន្តិសុខស-២១ ។ សំណួរសួរថា តើមានការមកដល់នៃ ឈ្លើយសឹកផ្សេងទៀតមកដល់ប៉ុស្តិ៍ដែលលោកអះអាងលោកនិយាយថា ក្រុមរបស់លោកដែលទទួល ភារកិច្ចនៅក្នុងការទទួលមនុស្សនៅកន្លែងប៉ុស្តិ៍មួយ ដែលបច្ចុប្បន្នជាស្ថានីយវិទ្យុសំបុកឃ្មុំហ្នឹង ចូលមក

មន្ទីរស-២១ ដែរឬទេ? ហើយបើមានតើមានតែជាកងទ័ព ស្លៀកពាក់ជាឯកសណ្ឋានកងទ័ព ឬក៏មានជនស៊ីវិលវៀតណាមដែរ?

**ឆ៖** បាទ, ខ្ញុំសូមជម្រាបថា ពេលដែលខ្ញុំបញ្ជូនយកមកទៅទទួលយកមកចូលគុកស-២១ នេះ គឺជាកងទ័ពរបស់វៀតណាម ស្លៀកពាក់ខោអាវជាទាហានទាំងអស់ ។

**ស៖** សំណួរហ្នឹងយើងសួរហើយ ។ សំណួរមួយទៀតហ្នឹងគឺថា ក្រៅពីមនុស្សហ្នឹងមនុស្សដែលលោកទទួលបញ្ជាទៅដឹកមកនេះ សួរថា នៅក្នុងអំឡុងពេលដែលលោកនៅប្រចាំការ ក្រុមលោកនៅប្រចាំការនៅបច្ចុប្បន្នដែលជាស្ថានីយវិទ្យុសំបុកឃ្មុំនេះ ដែលទទួលបន្ទុកទទួលភារកិច្ចក្នុងការទទួលមនុស្សពីអង្គភាពនានាដែលបញ្ជូនមកបញ្ជូលទៅក្នុងមន្ទីរសន្តិសុខស-២១ ដើម្បីឃុំឃាំង ឬក៏បញ្ជូនទៅព្រៃស ។

សំណួរសួរថា តើលោកមានដែលបានទទួលមនុស្សអង្គភាពផ្សេងទៀត ប្រគល់ឲ្យជាឈ្លើយសឹកវៀតណាម ឬក៏ជនស៊ីវិលវៀតណាមដែរឬទេ?

[១១:១១:៣០]

**ឆ៖** បាទ, ដែលខ្ញុំទទួលយកមកហ្នឹងគឺអត់មានបញ្ជូនទៅព្រៃសទេ គឺចូលគុកទាំងអស់តែម្តង។

**ស៖** ក្រៅពីលោកទៅទទួលនៅខេត្តស្វាយរៀងពីជើងហ្នឹង តើលោកមានបានទទួលមនុស្សផ្សេងឈ្លើយសឹកវៀតណាមផ្សេងទៀតទេ ដែលគេអង្គភាពផ្សេងៗបញ្ជូនមកដល់នៅភ្នំពេញនេះ?

**ឆ៖** បាទ, ខ្ញុំស្តាប់សំណួរមុនមិនបាន ។ គេបញ្ជូនមកផ្ទាល់ខ្លួនកេតែម្តងពីខាងភូមិភាគបូព៌ា គឺកងទ័ពវៀតណាម គេចាប់បានមក គេយកសេកយកមកប្រគល់ឲ្យត្រឹមកន្លែងខ្ញុំ ខ្ញុំនឹងបញ្ជូនចូលទៅកន្លែងគុក ។

**ស៖** មានចំនួនច្រើនទេ?

**ឆ៖** បាទ, ខ្ញុំសូមជម្រាបលោក គឺមានចំនួនច្រើន ។

**ស៖** ប៉ាន់ប្រមាណទៅ ប្រហែលជាប៉ុន្មានដែរបូកទាំងលោកទៅយកផង ហើយនិងគេបញ្ជូនមកដល់កន្លែងលោក? ហើយលោកបញ្ជូនបន្តទៅដាក់ឃុំឃាំងផង មានប្រហែលចំនួនប្រហែលប៉ុន្មាននាក់?

**ឆ៖** បាទ ការប៉ាន់ស្មានរបស់ខ្ញុំ គឺចំនួនពីប្រហែលហុកសិបនាក់ ដែលគេបញ្ជូនយកមក ។

**ប្រធានអង្គជំនុំ៖**

លោកមេធាវីមានបញ្ហាអីទៅ?

**លោក ហ្វ្រង់ស្វ័រ រូ៖**

ខ្ញុំសុំអភ័យទោសលោកប្រធាន ។ ខ្ញុំចង់ជម្រាបលោកប្រធានថា ជួនកាលការបកប្រែយើងមិនទទួលបានការបកប្រែទាំងស្រុងទេ នៅពេលដែលនិយាយ ដូច្នេះ សូមរង់ចាំឲ្យចប់ការបកប្រែសិនក្នុងភាសាខ្មែរ ទើបបន្តទៅទៀត ។ សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

អរគុណលោកមេធាវី ហ្វ្រង់ស្វ័រ រូ ដែលបានរំឭកពីបញ្ហានេះ យើងនឹងព្យាយាម ដើម្បីធ្វើឲ្យបានល្អប្រសើរ ។

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** ក្នុងអំឡុងពេលដែលលោក ក្រុមលោកទទួលភារបញ្ជូនមនុស្សពីខាងក្រៅចូលទៅខាងក្នុង សំណួរសួរថា តើមានមនុស្សស្ត្រីដែលមានវ័យចំណាស់ត្រូវគេចាប់ខ្លួន បញ្ជូនមកជាមួយនឹងក្រុមគ្រួសាររបស់គេដែរឬទេ?

**ឆ៖** បាទ, ខ្ញុំសុំជម្រាបលោក គឺមាន យកមកចូលគុកស-២១ ហ្នឹង ។

**ស៖** លោកគិតថា គាត់ជាយ៉ាងម៉េចទៅ? ជាម្ដាយរបស់ ឬក៏ជីដូនរបស់អ្នកដែលត្រូវចាប់ខ្លួនសំខាន់ ឬក៏គាត់មានកំហុសផ្ទាល់របស់គាត់ របស់ខ្លួនគាត់?

**ឆ៖** បាទ, នៅក្នុងបញ្ហាហ្នឹង ខ្ញុំសូមជម្រាបថា ខ្ញុំមិនយកចិត្តទុកដាក់ក្នុងការដឹងរឿងរបស់គេដែលមានកំហុសអីៗ គឺខ្ញុំអត់ដឹងទេ ដឹងតែថាគេបញ្ជូនយកមក គឺខ្ញុំបញ្ជូនបន្តគេតែម្ដង ។

**ស៖** ដោយសារគាត់វ័យចំណាស់ អ៊ីចឹងបានន័យថា វ័យចំណាស់ហើយ អាចថាការបញ្ជូនគាត់មកហ្នឹងគឺគាត់មកដល់មន្ទីរស-២១ កន្លែងលោកហ្នឹងមកជាក្រុម របៀបថាមានស្រីមានប្រុសមានកូនក្មេងមានយាយចាស់អីអ៊ីចឹង ឬក៏គាត់ការបញ្ជូនគាត់មកដល់ហ្នឹងតែជាបុគ្គលគាត់ម្នាក់ ឧទាហរណ៍អ៊ីចឹងទេ? ឬគាត់មកជាក្រុមៗមានប្រុសមានស្រី យើងមើលទៅទំនងជាគ្រួសារតែមួយ ដែលមានការពាក់ព័ន្ធញាតិលោហិត ឬក៏ញាតិពន្ធនៃអ្នកដែលត្រូវគេចាប់ខ្លួន ដែលមានតួនាទីចម្បងនោះ?

**ឆ៖** បាទ, ខ្ញុំសុំជម្រាបលោក គឺមានប្រុស មានស្រីចំណាស់ ហើយនិងនារីចំណាស់អាយុប្រហែលជា៣០ ឬ៤០ ដែលមកជាមួយគ្នាហ្នឹង ។ ខ្ញុំក៏មិនបានសួរមិនបានអីដែរ គឺតែគេបញ្ជូនមដល់ គឺខ្ញុំបញ្ជូនបន្តទៅខាងបង សួស ធី នោះ ។

**ស៖** លោកដែលបានទទួលមនុស្សដែលស្ត្រីដែលមានផ្ទៃពោះមកដល់កន្លែងលោក ហើយលោកបញ្ជូនបន្តចូលទៅមន្ទីរខាងក្នុងនៃមន្ទីរសន្តិសុខស-២១ ដែរឬទេ? ស្ត្រីដែលមានផ្ទៃពោះ?

**ឆ៖** បាទ, ពេលការងារអស់ហ្នឹង ខ្ញុំវាភ្លេចនឹងចាំហ្នឹង ថាបានបញ្ជូនចូលក៏មិនដឹងដែរ ព្រោះវាយូរពេកហើយ ។ ហើយមួយទៀត ក៏មិនយកចិត្តទុកដាក់ពីការបញ្ជូន ដឹងអ្នកណាពោះធំ អ្នកណាមិនពោះធំទេ គឺតែមកដល់រូតបញ្ជូនចូលទៅឲ្យគេ ។

**ស៖** ឥឡូវនេះ និយាយចូលដល់ទៅការចាប់ខ្លួននៃបុគ្គលិកមន្ទីរសន្តិសុខស-២១ ខ្លួនឯងវិញ ទាំងមន្ទីរសន្តិសុខស-២១ មជ្ឈមណ្ឌលភ្នំពេញ ទាំងព្រៃស ។ សំណួរសួរថា ក្នុងអំឡុងពេលដែលលោកធ្វើការងារនៅមន្ទីរសន្តិសុខស-២១ ភ្នំពេញនោះ តើលោកបានដឹងអំពីហេតុការណ៍នានានៃការចាប់ខ្លួនកម្មាភិបាលបុគ្គលិកនៃមន្ទីរសន្តិសុខស-២១ និងព្រៃស យកមកដាក់ឃុំឃាំងនៅក្នុងមន្ទីរសន្តិសុខស-២១ ដែរឬទេ?

**ឆ៖** បាទ, ខ្ញុំសុំជម្រាបលោក! ក្នុងឆ្នាំ១៩៧៧ កម្មាភិបាលធ្វើការនៅស-២១ ទាំងយុទ្ធជន គឺបានចាប់ខ្លួនដោយសារយកចម្លើយពីអ្នកពីកងទ័ពដែលចាប់ខ្លួនពី៧០៣ យកមកសួរចម្លើយៗ រួចហើយឆ្លើយដាក់ពួកអ្នកធ្វើការនៅក្នុងហ្នឹង មានការទាក់ទិនគ្នា ក៏គេធ្វើការចាប់ខ្លួនកម្មាភិបាលដែលធ្វើការធ្លាប់នៅអង្គភាពជាមួយគ្នានោះទៀត ចាប់បន្តកន្ទុយគ្នាទាំងនៅព្រៃស ក៏ចាប់បន្តគ្នារហូតទាំងអស់ទាំងពីរកន្លែងហ្នឹង ។

[១១:១៩:00]

**ស៖** លោកគិតឡើងវិញមើលថា ចំនួនសរុបដែលជាបុគ្គលិក ឬក៏កម្មាភិបាលនៃមន្ទីរស-២១ ហើយត្រូវកម្លាំងមន្ទីរស-២១ ចាប់យកឃុំឃាំងយកដាក់គុកនៅមន្ទីរស-២១នោះ សរុបប្រហែលជាប៉ុន្មានទៅតាំងពីពេលផ្តើមស្រាវជ្រាវ សម្រិតសម្រាំងដំបូង រហូតដល់ពេលចប់ប្រតិបត្តិការនោះប្រហែលជាប៉ុន្មាននាក់ដែរ? ដោយមិនបាច់និយាយពីរឿង នុន ហ៊ុយ ហៅ ហ៊ុយ ស្រែ ទេ និយាយពីតែអ្នកផ្សេងទៀត ។

**ឆ៖** បាទ, ខ្ញុំសូមជម្រាបលោក! កម្លាំងដែលធ្វើការនៅទួលស្លែងនៅស-២១ហ្នឹង គឺបុគ្គលិកទាំងអស់ចំនួនជិតបួនរយនាក់ ផ្នែកការពារប្រហែលជាបីរយនាក់ ។ ក្រោយមក គេចាប់បន្តបន្ទាប់មកយូរៗនៅសល់ប្រហែលជា ហា-ហុកសិបនាក់ ។ អ្នកខ្លះក៏បានបែងចែកថាទោសស្រាលបញ្ជូនឲ្យទៅស្រែដូចប៉េង គ្រី, សោម ម៉េត ហើយដូចនៃ ចិកនេះ ចិកដែលនៅក្រុមជាមួយខ្ញុំក៏ តាហ៊ី បញ្ជូនទៅព្រៃសដែរ ។

តែខ្ញុំសុំគាត់ទុកថា ខ្ញុំសូមកសាងពីរបីថ្ងៃសិនបង តែការពិតគឺខ្ញុំទុកកុំឲ្យគ្នាទៅព្រៃស វៗទៅព្រៃសបកមកវិញបញ្ចូលគុក ។ ថាកម្លាំងដូចកម្មាភិបាល កាលមុនគ្នាកងរយការពារចំនួនគ្នាជិតដប់នាក់ ចាប់អស់នៅសល់រយតែពីរនាក់ទេ ។ បានគេឲ្យខ្ញុំឡើងកងរយបណ្ដោះអាសន្នហ្នឹង គឺតាហ៊ី ជាអ្នកចាត់តាំងខ្ញុំឡើងកងរយបណ្ដោះអាសន្ន ។

**ស៖** ដូចលោកនិយាយថាម៉េច? កងរយប៉ុន្មាន? ហើយចាប់អស់នៅសល់តែពីរចាប់អស់ប៉ុន្មាននាក់ទៅ? កងរយមានប៉ុន្មាននាក់? ហើយលោកចាំទេថា អ្នកណាខ្លះនៅអាចរៀបរាប់ឈ្មោះបានទេអ្នកដែលត្រូវបានចាប់ខ្លួនជាបុគ្គលិក ឬជាកម្មាភិបាលមន្ទីរស-២១ ត្រូវបានចាប់ខ្លួនដាក់ឃុំឃាំងនៅក្នុងមន្ទីរដាក់គុកនៅក្នុងមន្ទីរស-២១នោះ?

**ឆ៖** បាទ, ខ្ញុំរៀបរាប់មិនអស់ទេ ព្រោះភ្លេចច្រើនណាស់ឈ្មោះ យូរឆ្នាំហើយ ។ ដូចអ្នកដែលត្រូវចាប់ខ្លួនដែលខ្ញុំនៅចាំបានគឺ ចែម ស្ងួន មួយ ហើយ ម៉ានៗ ជនជាតិចាម ហើយ បងប៉ូច ហើយអីទៀតគ្នាច្រើនណាស់ ខ្ញុំចាំមិនបានភ្លេចអស់ហើយ ។ ហើយនិងកម្មាភិបាលសួរចម្លើយឈ្មោះ ហាក់ឈ្មោះអីខ្លះទៀតមួយគំនរគ្នា ទាំងយុទ្ធជនការពារ គេចាប់ខ្ទេចអស់ហើយ ។

**ស៖** សរុបអស់ទៅអស់ច្រើនរយនាក់ទេ អាចនិយាយថាប៉ុន្មានរយអ៊ីចឹង អាចប្រហែលបានហើយ យើងដឹងថាពិបាកក្នុងការធ្វើឲ្យបានជាក់លាក់ ប៉ុន្តែវាអាចត្រឹមសិបនាក់ បានន័យថា ចិបសិបប៉ែតសិប កៅសិបនាក់ បានន័យថាក្រោមមួយរយ ឬក៏រយនាក់ បានន័យថាវាមិនដល់មួយពាន់ទេ ប៉ុន្តែវាអាចច្រើនលើសពីមួយរយអ៊ីចឹង រហូតដល់ជិតពាន់អ៊ីចឹង ប្រហែលជាប៉ុន្មាននាក់ទៅដែលការចាប់ខ្លួននៃបុគ្គលិកដែលធ្វើការនៅមន្ទីរស-២១ ដាក់ឃុំឃាំងនៅទីនោះ?

**ឆ៖** បាទ, វារាប់រយនាក់ចាប់នៅហ្នឹង ជាងរយនាក់ ចូលពីររយនាក់ ។

**ស៖** កម្រិតនៃកំហុសរបស់គេ ពួកគេដែលត្រូវបានចាប់ខ្លួនហ្នឹង កំហុសកម្រិតណាដែរ?

**ឆ៖** បាទ, ខ្ញុំសូមជម្រាបលោក ខ្ញុំអត់ដឹងថា អ្នកណាមានទោសកម្រិតណា ហើយមានបញ្ហាអីយ៉ាងម៉េចទេ គឺខ្ញុំអត់ដឹងទេ ។ ហូបបាយជាមួយគ្នាពេលល្ងាចគឺ គេចាប់បាត់ ស្អែកអត់ឃើញគ្នា យូរៗចេះតែបាត់គ្នាទៅៗ ។

**ស៖** លោកដឹងថាអ្នកណាជាអ្នកបញ្ជាឲ្យចាប់បុគ្គលិកមន្ទីរស-២១ ដាក់ឃុំឃាំងហើយប្រតិបត្តិការក្នុងការចាប់ហ្នឹង ក្រុមខាងណាជាអ្នកទទួលបន្ទុកទទួលបញ្ជាក្នុងកិច្ចប្រតិបត្តិការក្នុងការចាប់បុគ្គលិកនៃមន្ទីរសន្តិសុខស-២១ ដាក់ឃុំឃាំង?

**ឆ៖** បាទ, ខ្ញុំអត់បានដឹងថាអ្នកណា គឺអ្នកដែលចាប់ទេ តែតាមការប៉ាន់ស្មានរបស់ខ្ញុំគឺមានតែ ប៉េង ទេ ។

**ស៖** ចុះអ្នកបញ្ជា? អ្នកណាជាអ្នកបញ្ជា? លោកដឹងទេអ្នកណាបញ្ជាឲ្យចាប់? ចំពោះ ប៉េង អាចប្រតិបត្តិការអនុវត្តបទបញ្ជាឲ្យចាប់ខ្លួន? ចុះអ្នកណាជាបញ្ជាលោកដឹងទេ?

**ឆ៖** បាទ, ខ្ញុំសូមជម្រាបថានៅស-២១ នេះ គឺអ្នកធំជាងគេគឺ តាឌុច អ៊ីចឹងមានតែងគាត់ទេអ្នក បញ្ជាចាប់ខ្លួនបាន ។

**ស៖** ចុះ ហ៊ី មានសិទ្ធិៗក្នុងការចាប់អ្នកណាដាក់ឃុំឃាំង ឬក៏សម្លាប់អ្នកណាបានទេ? អនុៗ ប្រធាន តើមានសិទ្ធិហ្នឹងដែរទេ?

**ឆ៖** តាហ៊ី អត់មានសិទ្ធិនឹងធ្វើការចាប់ខ្លួនទេ បើចង់ចាប់អ្នកណាមួយក៏សេចក្ដីសម្រេចពីតាឌុច ដែរ ។

**ស៖** បញ្ជាផ្សេងពីសេចក្ដីសម្រេច ។ សេចក្ដីសម្រេចឲ្យចាប់ខ្លួនលោកដឹងថា មានការសម្រេច ឲ្យចាប់ខ្លួនបុគ្គលណាម្នាក់នៅក្នុងមន្ទីរស-២១ អ្នកណាជាអ្នកបញ្ជា? អ្នកណាជាអ្នកសម្រេច?

**ឆ៖** ខ្ញុំសូមជម្រាបថាមានតែ តាឌុច ទេអ្នកសម្រេច ព្រោះគាត់ជាប្រធានធំជាងគេទាំងអស់នៅ ក្នុងស-២១ នេះ ។

**ស៖** ក្រៅពីគាត់មានឋានៈធំជាងគេទាំងអស់នៅមន្ទីរស-២១ ក្នុងន័យជាប្រធាននេះ តើមាន ហេតុផលយ៉ាងម៉េចទៀតទេដែលលោកគិតថា ជនជាប់ចោទឈ្មោះ ឌុច ហ្នឹងជាអ្នកសម្រេចក្នុងការ ចាប់ខ្លួនបុគ្គលិកនៃមន្ទីរស-២១? មានហេតុផលអីផ្សេងទៀតទេ?

**ឆ៖** ខ្ញុំសូមជម្រាបថា ខ្ញុំអត់មាន-- កាលនោះមិនគិតពីរឿងហេតុផលអ្វីទេ ព្រោះគាត់ប្រធាន នៅកន្លែងហ្នឹង ហើយអ្នកណាដែលមានឈ្មោះក្នុងចម្លើយរបស់គេ គឺមានតែគាត់អ្នកសម្រេចចាប់ ។

[១១:២៦:១៣]

**ស៖** ចុះបុគ្គលិកនៅព្រៃស តើមានការបញ្ជាឲ្យចាប់ខ្លួនពីព្រៃសយកមកឃុំឃាំងនៅស-២១ ដែរ ឬទេ?

**ឆ៖** ខ្ញុំជម្រាបថា នៅព្រៃសនោះ អ្នកដែលមានកំហុស ដែលមានឈ្មោះឆ្លើយដាក់អីក៏សម្រេច ចេញស-២១ នេះទៅដែរ ។ គឺមានតែ តាឌុច ទេដែលអ្នកបញ្ជាយកពីណោះមក ឲ្យយក-- ធ្វើការចាប់ ខ្លួន ។

**ស៖** ក្រុមខាងណាដែលទទួលអនុវត្តបទបញ្ជាចាប់ខ្លួន? ក្នុងការប្រតិបត្តិទៅចាប់មន្ត្រីបុគ្គលិក ឬកម្មាភិបាលនៃព្រៃសយកមកដាក់ឃុំឃាំងនៅមន្ទីរសន្តិសុខស-២១ មជ្ឈមណ្ឌលភ្នំពេញ?

**ឆ៖** ការចាប់ខ្លួនអ្នកដែលនៅព្រៃសហ្នឹង គឺមិនដឹងក្រុមណាជាអ្នកទៅយកមកទេ ព្រោះថ្ងៃមួយ គេឲ្យខ្ញុំទៅពីរនាក់ គ្រី ទទួលថ្ងៃហ្នឹងក្រឡាប់ឡានទៅ ក៏ខ្ញុំអត់បានទៅយក ។ ហើយក្រោយមកដឹង ពួកណាអ្នកទៅយកទៀតទេ ។ ព្រោះមានពួក ផល ដែលជាប្រធានរបស់ខ្ញុំ ហើយនិង ប៉េង ជាប្រធាន របស់ពួកខ្ញុំ ។

**ស៖** លោករកនឹកមើលថាគ្រប់ករណីនៃបុគ្គលិក ឬក៏កម្មាភិបាលនៃមន្ទីរសន្តិសុខស-២១ ក្តី នៃ មន្ទីរអប់រំកែប្រែសាជាថ្មីព្រៃសក្តីដែលមានការចាប់ខ្លួនបុគ្គលិកយកមកឃុំឃាំងនៅមន្ទីរសន្តិសុខស-២១ ភ្នំពេញ ។ សំណួរសួរថា តើការចាប់ខ្លួននោះ ដូចថា ទាំងគ្រួសារទាំងប្តីទាំងប្រពន្ធទាំងកូនរបស់គេ ឬក៏ គេចាប់តែអ្នកណាដែលគេយល់ថាមានបញ្ហាពាក់ព័ន្ធ មានកំហុសគេចាប់ហើយប្តី ឬប្រពន្ធរបស់គេគឺ មិនចាប់ទេ?

**ឆ៖** ខ្ញុំសូមជម្រាបថា គេចាប់តែអ្នកណាដែលមានចម្លើយឆ្លើយដាក់គឺគេត្រូវចាប់ខ្លួនយកមក។ ហើយខ្ញុំក៏មិនដឹងថាចាប់ប្តី ឬក៏ប្រពន្ធដែរ ព្រោះតែគេចាប់ហើយគេបញ្ជូនយកមក ។ ហើយមិនដឹងជា មានការទាក់ទិនជាមួយខាងអ្នកណាម្នាក់ក៏ខ្ញុំអត់បានដឹងដែរ ។

**ស៖** ដូចជាលោកបានលើកឧទាហរណ៍ ចាប់ស្ងួន, ចាប់ម៉ាន, ចាប់ប៉ូច, ចាប់ហាក់ ជាដើម ដែលជាក្រុមភាគច្រើនគឺក្រុមខាងសួរចម្លើយ ។ សំណួរសួរថាប្រពន្ធរបស់គេ អ្នកទាំងអស់នោះអ្នកទាំង អស់ហ្នឹងត្រូវគេចាប់ខ្លួនដែរ ឬទេ?

**ឆ៖** ខ្ញុំសូមជម្រាបថា កម្មាភិបាលដែលមានប្រពន្ធមានគ្រួសារហ្នឹង គឺគេទៅចាប់ប្តី ឬចាប់ ប្រពន្ធចាប់យកមកទាំងអស់តែម្តង ។

[១១:៣០:២០]

**ស៖** រកនឹកឡើងវិញមើលថា នៅក្នុងអំឡុងពេលដែលលោកធ្វើការងារនៅទីនោះ នៅមន្ទីរសន្តិ-សុខស-២១ ក្នុងក្រុមនៃកងការពារ តើលោកកត់សម្គាល់ឃើញថា មានមនុស្សប៉ុន្មាននាក់ដែលត្រូវបានគេ ដោះលែងឲ្យត្រឡប់ទៅចេញពីមន្ទីរស-២១ ភ្នំពេញត្រលប់ទៅខាង-- ត្រលប់ទៅអង្គភាពដើម ឬក៏ទៅ មូលដ្ឋានរបស់គេវិញ?

**ឆ៖** បាទ, ខ្ញុំសូមទោស សុំសំណួរម្តងទៀត ។

**ស៖** តាមដែលលោកធ្វើការនៅទីនោះ តើលោកដែលកត់សម្គាល់ឃើញមានមនុស្សដែលត្រូវគេចាប់ខ្លួនយកទៅឃុំឃាំងនៅក្នុងមន្ទីរសន្តិសុខស-២១ ត្រូវបានគេដោះលែងវិញដែរទេ ហើយបើដោះលែងៗមានប៉ុន្មាននាក់? ហើយករណីណាខ្លះតាមដែលលោកដឹង?

**ឆ៖** ខ្ញុំសូមជម្រាប អ្នកដែលចាប់ខ្លួនចូលស-២១នេះ គឺដូចមិនដែលឃើញថាព្រលែងទេ ឃើញតែចូលមកគឺចប់ហើយ ។

**ស៖** លោកបាននិយាយអម្បាញ់មិញ ពាក់ព័ន្ធជាមួយនឹងកិច្ចការដែលលោកត្រូវបានចាត់ឲ្យទៅជួយនៅក្នុងជាមួយនឹងក្រុមការពារផ្ទៃក្នុង ។ ឧបមាថា ការងារផ្នែកខាងក្នុងអគារម្តងម្កាលមិនមែនជាញឹកញាប់ទេ ។ សំណួរសួរថា តើលោកដែលបានចូលទៅឃើញនូវទិដ្ឋភាពនៃការសួរចម្លើយដែរឬទេ? ការសួរចម្លើយជនដែលត្រូវចាប់ខ្លួន? ដែលឃើញគេ-- ស្ថានភាព ឬទិដ្ឋភាពនៃការសួរចម្លើយដែរឬទេ?

**ឆ៖** ខ្ញុំសូមជម្រាបថា ផ្នែកខាងសួរចម្លើយគឺខ្ញុំអត់បានទៅជិតគេ ទៅឃើញគេសួរចម្លើយទេព្រោះផ្នែកខ្ញុំដោយឡែកពីខាងសួរចម្លើយ ។

**ស៖** ចុះការជួយរបស់លោក តើលោកឃើញអ្នកដែលត្រូវគេឃុំឃាំងនៅទីនោះយ៉ាងម៉េចដែរ? នៅក្នុងអំឡុងពេលដែលលោកចូលជួយគេនោះ តើលោកឃើញទិដ្ឋភាពនៃមនុស្សដែលកំពុងតែជាប់ឃុំឃាំងហ្នឹង ទិដ្ឋភាពជាទូទៅដែលលោកបានឃើញនោះយ៉ាងម៉េចដែរ? លោកអាចនិយាយប្រាប់ដល់អង្គសវនាការបានយល់ បានដឹងអំពីទិដ្ឋភាពនោះដែរឬទេ?

**ឆ៖** បាទ, ខ្ញុំសូមជម្រាបលោក ពេលដែលខ្ញុំចូលទៅឃើញ គឺអ្នកទោសជាប់ឃុំឃាំងនោះគឺធុំក្លិនស្អុយតាមបន្ទប់នីមួយៗហ្នឹងគឺមិនបានសម្អាតឲ្យទេ ហើយអ្នកយាមទៀត គឺខ្ញុំដើរមើលអ្នកយាមគឺធ្វើយ៉ាងម៉េចតែកុំឲ្យអ្នកយាមងោក ។ ហើយឃើញអ្នកទោសដែលគេយកទៅសួរចម្លើយមកវិញ ឃើញស្នាមខ្លួនស្នាមអី គេវ៉ៃ គេសួរចម្លើយ ធ្វើទារុណកម្មហ្នឹង ។ ការដើរមើលហ្នឹង ក៏ខ្ញុំនៅចាប់អារម្មណ៍តែមួយកន្លែងៗទេ គឺខ្ញុំដើរមើល សំខាន់ជាងគេគឺការពារ អ្នកការពារហ្នឹងធ្វើម៉េចកុំឲ្យងោក ។ មើលសព្វគ្រប់អស់ហើយបានខ្ញុំមកកន្លែងរបស់ខ្ញុំវិញ ។

**ស៖** លោកដឹងថា អ្នកទោសហ្នឹងត្រូវបានគេឲ្យងូតទឹកដែរឬទេ? ហើយបើងូតទឹកៗយ៉ាងម៉េចទៅ?

**ឆ៖** ខ្ញុំសូមជម្រាប អ្នកទោសគឺគេឲ្យងូតទឹកនោះគឺ គេដាក់ទុយោបាញ់ឲ្យងូតតែម្តង គេអត់មានដោះប្រលែងឲ្យងូតទេ ព្រោះគេខ្លាចអ្នកទោសធ្វើសកម្មភាពចំពោះអ្នកការពារ ។

**សៈ** ចុះរបបហូបវិញ អាហារដែលផ្ដល់ឲ្យអ្នកទោសហូបវិញ លោកដឹងទេតើស្ថានភាពយ៉ាងម៉េចទៅ? របបអាហារមួយថ្ងៃប៉ុន្មានពេល? ហើយមួយពេលៗហ្នឹងគេផ្ដល់ឲ្យយ៉ាងម៉េចខ្លះ?

**ឆៈ** បាទ, អ្នកទោសដែលហូបគឺមួយថ្ងៃហូបពីរពេល ។ ពេលហូបនោះគឺហូបបបរ ។ ហើយសម្លអីគេក៏ខ្ញុំមិនចាប់អារម្មណ៍ដែរ ព្រោះជួនកាលខ្ញុំទៅឃើញស្លដើមចេកស្លអី ។

**សៈ** បបរនោះប្រហែលជាប៉ុន្មានទៅ ចែកមួយដងៗក្នុងមួយពេលមួយនាក់បានទទួលប្រហែលប៉ុន្មានទៅ? ប្រហែលជាប៉ុន្មានចានទៅ? ហើយចាននោះទំហំប៉ុនណា?

**ឆៈ** ខ្ញុំសូមជម្រាប! អ្នកទោសដែលរបបហូបក្នុងមួយពេលៗគឺឲ្យតែមួយវែកកន្លះអីទេ ហើយចានៗដែកហ្នឹង អាចានដែកចានទាបហ្នឹងឲ្យហូបទៅ ។

**សៈ** កាលដែលលោកទៅជួយពិនិត្យគេក្នុងការបំពេញភារកិច្ចតាមបញ្ជារបស់ថ្នាក់លើអ៊ីចឹង តើលោកឃើញជនជាតិបរទេសដែលថា មាឌធំៗដែលថាលោកអះអាងអំមិញថា សក់ទង់ដែងអ៊ីចឹង តើគេដាក់ឃុំឃាំងនៅកន្លែងណា? នៅអគារណា? ដាក់ដោយឡែក ឬក៏ដាក់ជាមួយហ្នឹងអ្នកជាប់ឃុំឃាំងជាពលរដ្ឋខ្មែរដែរ?

**ឆៈ** ជនជាតិបរទេសនោះគឺគេដាក់នៅអគារចំហៀងខាងត្បូង ។

**សៈ** អគារ "A" បច្ចុប្បន្នហ្នឹងដែលយើងស្គាល់ជាទូទៅបានន័យថាយើងចូលពីខាងកើតទៅវានៅខាងឆ្វេងដៃ អគារបណ្ដោយថ្ងៃហ្នឹង ឬក៏អគារនៅខាងក្រៅ ខាងត្បូងហ្នឹងរំលងផ្លូវមួយទៀត?

**ឆៈ** ខ្ញុំសូមជម្រាបថា អគារចំហៀងខាងត្បូងហ្នឹងហើយ ។

**សៈ** បច្ចុប្បន្នអគារ "A" ហ្នឹង អគារបណ្ដោយថ្ងៃមួយហ្នឹងមែនទេ?

**ឆៈ** បាទ, គឺអគារមួយបណ្ដោយថ្ងៃហ្នឹង ។

**សៈ** ចុះអគារណាដែលគេឃុំឃាំងមនុស្សស្រី? តើលោកដែលបានទៅត្រួតពិនិត្យ ឬក៏ទៅមើលអ្នកយាមនៅបន្ទប់ឃុំឃាំងមនុស្សស្រីដែរឬទេ? តើគេឃុំឃាំងមនុស្សស្រីនៅកន្លែងណា? តើស្ថានភាពឃុំឃាំងមនុស្សស្រីហ្នឹងយ៉ាងម៉េចដែរតាមដែលលោកឃើញ?

[១១:៣៨:៤៤]

**ឆៈ** ខ្ញុំសូមជម្រាប! គេឃុំឃាំងស្ត្រី គឺនៅអគារទីបីជាន់លើ ហើយគេដាក់ៗគ្នាច្រើនៗនៅហ្នឹងព្រោះនារីមិនអាចធ្វើសកម្មភាពអីបែកបានទេ គេដាក់នៅទាំងអស់គ្នាអ៊ីចឹងទៅ ។

**សៈ** ដាក់តែមួយបន្ទប់ទេ ឬក៏ដាក់នៅច្រើនបន្ទប់?

**ឆ៖** ខ្ញុំភ្លេចភ្លាំងដែរព្រោះកាលនោះគឺ យ៉ាងតិចណាស់ក៏បានដាក់បីបន្ទប់អីដែរ ។

**ស៖** ស្ត្រីទាំងអស់ដែលដាក់ឃុំឃាំងនៅទីនោះមានជាប់ខ្នោះ គេដាក់ខ្នោះជើងអីដែរទេ? ឬគេគ្រាន់តែដាក់នៅក្នុងបន្ទប់ហើយបិទទ្វារចាក់សោពីខាងក្រៅ?

**ឆ៖** ខ្ញុំសូមជម្រាបថា នារីៗទាំងអស់នោះគឺគេដាក់នៅក្នុងបន្ទប់ធំជាមួយគ្នា អត់មានដាក់ខ្នោះជើង ខ្នោះដៃអីទេ ។

**ស៖** លោកឃើញកូនៗរបស់គេនៅជាមួយគេដែរទេ? កូនៗអំមិញលោកនិយាយថា ដែលបានចាប់បញ្ជូនមកជាមួយឪពុកម្តាយរបស់វាថាក្នុងអំឡុងពេលឃុំខ្លួននោះតើលោកឃើញ លោកនៅដើរធ្វើការនោះ លោកមានដែលបានឃើញកូនៗរបស់គេនៅជាមួយម្តាយរបស់គេដែរទេ?

**ឆ៖** ខ្ញុំសូមជម្រាបថា ពេលដែលខ្ញុំឡើងទៅឃើញមើលហ្នឹងគឺនៅជាមួយម្តាយ ។ ក្មេងៗគឺនៅជាមួយម្តាយទាំងអស់ ។

**ស៖** អគារដែលលោកនិយាយអំមិញហ្នឹងគឺអគារ លោកថាអគារទីបីអ៊ីចឹង? អគារទទឹងថ្ងៃ ឬក៏អគារបណ្តោយថ្ងៃ?ហើយបើចូលពីខាងកើតទៅអគារហ្នឹងនៅត្រង់កន្លែងណា? លោកអាចនិយាយរៀបរាប់ដើម្បីបង្ហាញពីអគារដែលឃុំឃាំងមនុស្សស្រីហ្នឹងបានដែរទេ?

**ឆ៖** ខ្ញុំសូមជម្រាបថា អគារទីបីបន្ទាប់ពីអាមួយខាងជើងបណ្តោយថ្ងៃហ្នឹង ជាន់លើ ។

**ស៖** អគារទាំងអស់មានបួន បណ្តោយថ្ងៃមានពីរមែនទេ? យើងចូលមកពីខាងកើតមកមួយនៅខាងស្តាំដៃ មួយនៅខាងឆ្វេងដៃ អគារបណ្តោយថ្ងៃ ហើយចំណែកឯអគារពីរទៀតគឺអគារទទឹងថ្ងៃនៅទន្ទឹមគ្នា ។ ក្នុងចំណោមអគារពីរហ្នឹង តើអគារទន្ទឹមគ្នានៅខាងក្រោយហ្នឹងអគារមួយណា? នៅខាងជើង ឬក៏អគារនៅខាងត្បូងដែលដាក់ឃុំស្ត្រីនោះ?

**ឆ៖** ខ្ញុំសូមជម្រាបថា អគារទីបីចំហៀងអាទទឹងថ្ងៃខាងជើង ។

**ស៖** តាមកាលដែលលោកកត់សម្គាល់ទីមួយ សួរថាលោកដែលជួបស្ថានភាពនៃករណីណាមួយដែលមានស្ត្រីហ្នឹងត្រូវបានបំបែកយកទៅដាក់ឃុំឃាំងនៅអគារបន្ទប់តូចៗដាច់ដោយឡែកតែម្នាក់ឯងដែលមិនដាក់នៅក្នុងអគារឃុំឃាំងរួមស្ត្រី? តើមានករណីនេះដែរឬទេ?

**ឆ៖** ខ្ញុំសូមជម្រាបថា ពេលនោះគឺខ្ញុំមិនបាននៅចាប់អារម្មណ៍មើលថា នារីនៅបន្ទប់តូចៗមួយណាទេ ព្រោះខ្ញុំចាប់អារម្មណ៍ថាឃើញនៅច្រើនៗអាហ្នឹងខ្ញុំចាប់អារម្មណ៍ ព្រោះពេលដើរម្តងៗ ខ្ញុំមិនសូវបានចូលមើលឲ្យច្បាស់ថា អ្នកទោសនៅក្នុងគុកហ្នឹងរបៀបយ៉ាងម៉េចៗក៏ខ្ញុំអត់បានទេ គេបញ្ជាខ្ញុំឲ្យ

ដើរមើលអ្នកយាមព្រោះខ្លាចអ្នកយាមងោក ។

**ស៖** តាមកាលដែលលោកដឹង សំណួរសួរថា តើអ្នកទោសស្ត្រីគេមានដែលនាំយកទៅដាក់ឃុំឃាំងនៅអគារបណ្តោយថ្ងៃគឺអគារខាងជើងដែរឬទេ?

**ឆ៖** ខ្ញុំសូមជម្រាប! អគារខាងជើងហ្នឹងក៏អាចមានដាក់ដែរ ។

**ស៖** នៅក្នុងអំឡុងពេលដែលលោកប្រតិបត្តិការ ដើរមើលកម្លាំងយាមផ្សេងៗតាមបញ្ជារបស់ថ្នាក់លើនោះ សួរថាតើលោកបានទៅពិនិត្យមើលនូវអគារដែលឃុំឃាំងឈ្លើយសឹកវៀតណាមដែរឬទេ? ហើយបើទៅមើល តើឈ្លើយសឹកវៀតណាមនោះគេដាក់នៅក្នុងអគារណា? ហើយទិដ្ឋភាពនៃអ្នកទាំងនោះដែលលោកឃើញនោះតើយ៉ាងម៉េចដែរ?

**ឆ៖** ខ្ញុំសូមជម្រាបថា ឈ្លើយសឹកវៀតណាមដែលគេយកមកដាក់គុកនៅស-២១ គឺនៅអគារបណ្តោយថ្ងៃខាងត្បូងជាន់ទីពីរហ្នឹង ហើយទិដ្ឋភាពនៅកន្លែងហ្នឹងគឺដូចគ្នាទាំងអស់ គឺបន្ទប់តូចៗ ។

**ស៖** ឈ្លើយសឹកវៀតណាមទាំងអស់ហ្នឹង ត្រូវបាននៅទាំងសម្លៀកបំពាក់ជាកងទ័ពដដែលឬក៏គេដោះចេញដូចដែលលោកបាននិយាយថា ចូលទៅដល់គេដោះខោអាវវែងចេញ ហើយទុកតែខោខ្លី នៅពេលដែលទៅដល់កន្លែងឈ្មោះ ធី អ៊ីចឹង ។ តើដែលលោកឃើញនោះពួកឈ្លើយសឹកវៀតណាមទាំងអស់ហ្នឹងស្លៀកខោវែង ខោអាវកងទ័ពដដែល ឬក៏គេស្លៀកពាក់តែខោខ្លីទេ?

**ឆ៖** ខ្ញុំសូមជម្រាបថា ទៅដល់ហ្នឹងគឺសម្លៀកបំពាក់ហ្នឹងគេដោះចេញអស់ហើយ។ គេឲ្យស្លៀកខោខ្លី។

**ស៖** លោកសង្កេតមើលរូបរាងកាយអ្នកទាំងអស់ហ្នឹងស្គមខ្លាំងទេ ពេលដែលលោកទៅឃើញ? ពួកឈ្លើយសឹកវៀតណាម?

[១១:៤៥:៥៨]

**ឆ៖** ខ្ញុំសូមជម្រាបថា ឈ្លើយសឹកវៀតណាមក៏ដូចជនជាតិខ្មែរយើងគឺអ្នកទោសដែលចូលមកស្គមដូចតែគ្នាទាំងអស់ ។

**ស៖** របបហូបចុកសម្រាប់ផ្តល់ឲ្យទៅឈ្លើយសឹកវៀតណាមដែលជាប់ឃុំឃាំង និងរបបហូបចុករបស់ប្រជាពលរដ្ឋខ្មែរដែលជាប់ឃុំឃាំងទីនោះដូចគ្នា ឬក៏ខុសគ្នា?

**ឆ៖** ខ្ញុំសូមជម្រាបលោក! ខ្ញុំអត់បានដឹងទេ អារឿងរបបដែលឲ្យខាងឈ្លើយសឹកវៀតណាមហូបនោះ ។

**ស៖** លោកបានឃើញទិដ្ឋភាពនៃរាងកាយរបស់ឈ្លើយសឹកវៀតណាមហ្នឹង មានកន្ទួល មានដំបៅ ឬក៏មានស្លាកស្នាមនៃការទទួលរងនូវ និងប៉ះទង្គិចនូវវត្ថុរឹងអីដូចជាស្នាមរបួសអ៊ីចឹងដែរទេ? ឬក៏មិនមានទេ?

**ឆ៖** កងទ័ពវៀតណាមហ្នឹង កាលនោះពេលដែលខ្ញុំចូលទៅមើលហ្នឹងក៏អត់ទាន់មានរបួសស្នាមអីដែរទេ គឺនៅសាច់ស្អាតទេ ។

**ស៖** ចុះអគារដែលឃុំឃាំងមនុស្សសំខាន់ បានន័យថា មនុស្សដែលមានឋានៈខ្ពស់នៅក្នុងរដ្ឋកម្ពុជាប្រជាធិបតេយ្យ ក៏ដូចជានៅក្នុងជួរបក្សនៃកម្ពុជាប្រជាធិបតេយ្យដែរថា តើគេដាក់គាត់ឃុំឃាំងពួកគេនោះនៅកន្លែងណា? នៅជាមួយគ្នាពលរដ្ឋទូទៅក្នុងអគារទាំងបួន ឬក៏គេដាក់នៅកន្លែងណា?

**ឆ៖** ខ្ញុំសូមជម្រាបថា គឺនៅអគារចំហៀងខាងត្បូងហ្នឹង តែមិនដឹងកន្លែងណាខ្លះទេ ព្រោះខ្ញុំអត់បានចូលទៅមើលឲ្យបានច្បាស់។

**ស៖** អគារខាងត្បូង បានន័យថា អគារបណ្ដោយថ្ងៃរាល់ថ្ងៃហ្នឹង អគារខាងឆ្វេងដៃដែលយើងចូលទៅពីកើតទៅ អគារឆ្វេងដៃ ឬក៏អគារក្រៅពីហ្នឹងទៀត? បានន័យថារំលងផ្លូវទៅខាងត្បូង ឬទៅខាងកើតទៀត?

**ឆ៖** ខ្ញុំសូមជម្រាបថា អគារមួយចំហៀងខាងត្បូងបណ្ដោយថ្ងៃហ្នឹង ។

**ស៖** លោកឧស្សាហ៍ដើរធ្វើការពិនិត្យស្ថានការណ៍នៅទីនោះ ។ សួរថាតើមានកន្លែងសម្រាប់ដាក់កូនក្មេងដោយឡែកដែរឬទេ?

[១១:៤៩:២០]

**ឆ៖** ខ្ញុំសូមជម្រាបថា ពេលដែលខ្ញុំទៅហ្នឹងឃើញនៅជាមួយម្ដាយគេហ្នឹងទាំងអស់ទេ អាកន្លែងដែលគេដាក់នៅដោយខ្លួនក៏ខ្ញុំអត់បានដឹងដែរ ។

**ស៖** លោកបាននិយាយពីខាងដើម យើងសួរលោកហើយថា មនុស្សទាំងឡាយដែលកាលបើចាប់បញ្ជូនយកទៅដាក់ឃុំឃាំងនៅក្នុងមន្ទីរស-២១ ហើយនោះ គឺគ្មានការដោះលែងទេ ។ សំណួរសួរថាតើជោគវាសនារបស់មនុស្សដែលចាប់ខ្លួនបញ្ជូនយកទៅដាក់គុក ឬក៏ហៅថាឃុំឃាំងនៅមន្ទីរស-២១ នោះគេទទួលជោគវាសនាយ៉ាងម៉េច បើគ្មានការដោះលែងនោះ?

**ឆ៖** បាទ, ខ្ញុំសូមជម្រាបថា អ្នកទោស មនុស្សទាំងអស់ដែលចាប់ចូលក្នុងគុកស-២១ គឺគ្មានការដោះលែងទេ គឺរង់ចាំតែថ្ងៃសួរចម្លើយ ហើយនិងស្លាប់ជីវិតតែម្ដង ។

**ស៖** រង់ចាំតែស្លាប់ហ្នឹង ស្លាប់យ៉ាងម៉េចទៅ ដោយការមិនឲ្យអាហារ ហើយស្លាប់នៅទីនោះតែម្តង ឬក៏ដោយ ស្លាប់ដោយវិធីផ្សេងៗ តាមដែលលោកបានដឹង?

**ឆ៖** ខ្ញុំសូមជម្រាបថា ការស្លាប់នោះ ជួនកាលអ្នកខ្លះគេយកទៅសួរចម្លើយទៅ ទារុណកម្មបែកខ្នងទៅជាឈឺ ទៅអីទៅ ទុកយូរអាចស្លាប់នៅក្នុងគុកតែម្តង ។ អ្នកខ្លះ គឺសួរចម្លើយហើយ គេនឹងដឹកយកទៅសម្លាប់ចោល ។

**ស៖** ករណីដែលសួរចម្លើយហើយ គេដឹកយកទៅសម្លាប់ចោលនោះ តាមលោកដឹង តើគេយកអ្នកទោសទាំងអស់នោះទៅសម្លាប់ចោលនៅទីណាខ្លះទៅ? ហើយជាធម្មតាគេបញ្ជូនទៅកន្លែងសម្លាប់ចោលនោះ គេនៅពេលយប់ ឬក៏ពេលថ្ងៃ?

**ឆ៖** បាទ, ខ្ញុំសូមជម្រាបលោក អ្នកដែលគេសួរចម្លើយហើយ គឺគេពេលយប់ម៉ោងប្រាំបី ប្រាំបួន គេនឹងយកទៅ បណ្តើរយកចេញទៅ យកទៅសម្លាប់ចោលនៅចំហៀងខាងត្បូងទួលស្លែងហ្នឹង ។

**ស៖** មានយកទៅសម្លាប់ គេនាំអ្នកទោសយកទៅសម្លាប់កន្លែងណាផ្សេងទៀត ក្រៅពីខាងត្បូងទួលស្លែង ដូចជាខាងលិចសារមន្ទីរទួលស្លែង ខាងជើងសារមន្ទីរទួលស្លែង ឬខាងក្នុង ក្នុងបរិវេណនៃមន្ទីរទួលស្លែង តើមានការសម្លាប់ដែរឬទេ?

**ឆ៖** បាទ, ក្នុងគុកគឺមានតែអ្នកដែលស្លាប់ទេ ដែលគេកប់នៅក្បែរគុកហ្នឹង ខាងក្រោយគុកហ្នឹង ហើយអ្នកដែលគេយកចេញទៅសម្លាប់ គឺនៅខាងត្បូង ហើយនិងខាងលិច ខាងលិចគុក។

**ស៖** តាមធម្មតាការដែលលោកដឹង តាមលោកដឹង ដែលគេនាំមនុស្សអ្នកទោសយកទៅសម្លាប់ហ្នឹង គេយកទៅជាបុគ្គល បានន័យថា ជាមនុស្សម្នាក់ៗ ឬក៏មានករណីដែលគេនាំទៅជាក្រុមដែរ នៅក្នុងការសម្លាប់នៅខាងត្បូងនៃមន្ទីរសន្តិសុខស-២១ មជ្ឈមណ្ឌលទួលស្លែងបច្ចុប្បន្ននោះ គឺគេ ហៅថាសារមន្ទីរគុកទួលស្លែង ឬក៏ខាងលិចនោះ តើគេមានការសម្លាប់ជាបុគ្គល ឬក៏មានការសម្លាប់ជាក្រុម បានន័យថា នាំមនុស្សច្រើននាក់ទៅសម្លាប់ក្នុងពេលតែមួយ មានករណីហ្នឹងអ៊ីចឹងទេ?

[១១:៥៤:០៤]

**ឆ៖** បាទ, ខ្ញុំសូមជម្រាបថា ពេលដែលគេយកទៅនោះ គឺគេបណ្តើរចេញម្តងមួយៗពីគុកហ្នឹង។

**ស៖** តាមឯកសារមានបានកត់ត្រាថា បានគាស់អដ្ឋិធាតុក្រោយឆ្នាំ១៩៧៩ មានរណ្តៅកប់សពរួមជាច្រើននៅម្តុំខាងលិចនៃសារមន្ទីរទួលស្លែងបច្ចុប្បន្ននេះ ហើយចំនួននោះ គឺមានចាប់ពីប្រហែលដប់នាក់រហូតដល់ចំនួនច្រើនជាងគេ គឺសាមសិបពីរនាក់ ។ បានន័យថា ក្នុងមួយរណ្តៅនោះរហូតដល់

សាមសិបពីរនាក់ឯណោះ ។ តាមដែលលោកដឹងបើសិនជាការសម្លាប់រហូតដល់សាមសិបពីរនាក់អ៊ីចឹង នាំម្នាក់ម្តងៗទៅហ្នឹង អាចទីមួយ គឺយូរសាមសិបពីរនាក់ ។ ហើយទីពីរ វាទាក់ទិនជាមួយនឹងកប់ បានន័យថាទាល់តែសម្លាប់គ្រប់ទាំង សាមសិបពីរនាក់ហ្នឹង រួចរាល់ហើយ ជិតតែចូលក្នុងរណ្តៅអស់ ហើយទើបកប់ជាក្រោយ តើរបៀបក្នុងការចាត់ចែងគេ-- តាមលោកដឹងគេចាត់ចែងក្នុងការនាំមនុស្ស ទៅសម្លាប់ហ្នឹងយ៉ាងដូចម្តេច? ហើយគេប្រើវិធី ឬក៏ប្រើល្បិចកុហកអ្នកទោសហ្នឹងថាយ៉ាងម៉េចដែរ? ឬក៏មានករណីដែលអ្នកទោសមានប្រតិកម្មចំពោះអ្នកដែលនាំទៅ-- ចំពោះកងសន្តិសុខ ឬក៏កងកម្លាំងនៃមន្ទីរសន្តិសុខ ស-២១ ដែលនាំពួកគេទៅសម្លាប់ដែរឬទេ?

**ឆ៖** ខ្ញុំសូមជម្រាបថា ការសម្លាប់នៅក្រោយទួលស្លែងហ្នឹងស-២១ ហ្នឹង តាំងពីឆ្នាំ១៩៧៧ គឺ តាំងពីកម្មាភិបាលមុននៅរហូតជាមួយពួក ប៉េង ដែលយកទៅសម្លាប់ ។ ពេលដែលគេយកទៅហ្នឹង គឺ គេមិនមែនបណ្តើរម្តងមួយៗទេ គឺក្នុងម្នាក់ គឺបណ្តើរម្នាក់ ក្នុងម្នាក់បណ្តើរម្នាក់ ។ ក្នុងពេលសម្លាប់ហ្នឹង គឺគេយកទៅសម្លាប់ជាមួយគ្នាទាំងអស់ ក្នុងពេលតែមួយ ហើយនិងម៉ោងឆាប់ ។

**ស៖** អ៊ីចឹងក្នុងការនាំចេញទៅហ្នឹង ដូចជា លោកដឹងទេថាតើមានការប្រើពាក្យពេចន៍យ៉ាងម៉េច ដូចជានិយាយសម្តីយ៉ាងម៉េច? ដើម្បីឲ្យអ្នកដែលត្រូវគេសម្លាប់ហ្នឹង គឺមានការស្ងប់អារម្មណ៍ អត់មាន ការតតាំងអីទេ តើគេប្រើល្បិចយ៉ាងម៉េចខ្លះអានេះទីមួយ? ទីពីរចុះការដែលប្រគល់ទទួលដកយកចេញ ពីកន្លែងឃុំឃាំងហ្នឹង គេប្រគល់ទទួលគ្នាយ៉ាងម៉េច រវាងអ្នកដែលនាំយកទៅសម្លាប់ និងអ្នកដែលយាម ការពារនៅក្នុងតាមបន្ទប់នីមួយៗ?

**ឆ៖** បើតាមខ្ញុំយល់ ការងារដែលយកទៅសម្លាប់ហ្នឹង គឺគេដកក្រុមណាដែលមិនទាន់យាម គឺ យកទៅ ជួយយកទៅសម្លាប់ ហើយតាមការសន្និដ្ឋានរបស់ខ្ញុំ ដូចដឹកយកទៅជើងឯកអ៊ីចឹង គេនឹងប្រាប់ ថា ដូរផ្ទះថ្មី អ៊ីចឹងទៅ ធ្វើយ៉ាងម៉េចកុំឲ្យអ្នកទោសដឹងខ្លួន ។

[១១:៥៧:៥៨]

**ស៖** ពេល ខណៈពេលដែលគេនាំអ្នកទោសយកទៅ ចេញទៅសម្លាប់ហ្នឹង គេមានការដាក់ខ្នោះ ដៃ ហើយ ឬក៏ចងដៃ ហើយមានរុំមុខដោយក្រណាត់ដូចអង្កាល់គេបញ្ជូនចូលដែរឬទេ? ឬក៏គេអត់មានរុំ មុខអីទេ ដោយសារពេលវេលាយប់?

**ឆ៖** បាទ, អ្នកទោសដែលគេយកទៅសម្លាប់ហ្នឹង គឺគេចងសេកដូចអង្កាល់នៃដឹកពីគេនោះមក ដែរ ហើយនិងចងមុខឲ្យជិត ធ្វើម៉េចកុំឲ្យស្គាល់ផ្លូវ កុំឲ្យដឹងថាយកទៅកន្លែងណាៗ ។ បើលែងមុខ

ហ្នឹងអ្នកទោសដឹងស្រែក អ៊ីចឹងគេឲ្យចងមុខឲ្យជិត ហើយជួនកាលដាក់ខ្នោះដៃ ជួនកាលគេចងសេក ដោយខ្សែអង្រឹង ។

**ស៖** ករណីដាក់ខ្នោះដៃ ដល់ពេលកន្លែងសម្លាប់ហ្នឹង សម្លាប់រួចទម្លាក់ចូលរណ្ដៅហើយ គេចុះដោះយកខ្នោះវិញ ឬក៏យ៉ាងម៉េច ឬក៏កប់ទាំងខ្នោះដៃ?

**ឆ៖** បាទ,ខ្ញុំសូមជម្រាប ពេលដែលគេយកទៅសម្លាប់ហ្នឹង គេឲ្យទៅអង្គុយនៅមាត់រណ្ដៅហ្នឹង ហើយលត់ជង្គង់ទៅ ហើយគេវ៉ៃ វ៉ៃហើយគេអារ-ក ។ អារ-កហើយគេដោះខោអាវ ដោះសម្លៀកបំពាក់ហ្នឹង ហើយគេដោះខ្នោះដៃ ។ ដោះខ្នោះដៃហើយបានដោះសម្លៀកបំពាក់ហ្នឹង ។

**ស៖** លោកបានដឹងទេ អំពីក្រុមអ្នកដែលនាំមនុស្សទៅសម្លាប់ ហើយនិងក្រុមដែលជីករណ្ដៅសម្រាប់កប់សពដែលគេនឹងនាំទៅសម្លាប់នោះ ។ សំណួរសួរថា តើគេបែងចែករវាងក្រុមជីករណ្ដៅ រង់ចាំតែជីករណ្ដៅហ្នឹង ដោយឡែកពីអ្នកដែលទទួលភារៈនាំអ្នកទោសទៅសម្លាប់ ឬក៏គឺអ្នកណាដែលមានភារកិច្ចក្នុងការនាំអ្នកទោសទៅសម្លាប់ នោះគឺអ្នកនុំងមានភារកិច្ចជីករណ្ដៅដោយខ្លួនឯង រួចកប់សាកសពដោយខ្លួនឯង?

**ឆ៖** បាទ,ខ្ញុំសូមជម្រាបថា កាលពីមុននោះ គឺអង្គភាពកងការពារនៅច្រើន មិនដឹងជាក្រុមណា ឬមួយអ្នកណាខ្លះទេ ដែលទៅជីកហ្នឹង ហើយនិងយកទៅសម្លាប់ហ្នឹង ។ ប៉ុន្តែ ប្រធាននៅកន្លែងហ្នឹង គឺតាំង ពីបង ប៊ូច ហើយនិង ប៉េង ហើយកម្មាភិបាលមួយគំនរគ្នាទៀត ទាំងមេក្រុម មេអីហ្នឹង ក៏ខ្ញុំមិនដឹងថា ក្រុមរបស់អ្នកណាម្នាក់ដែរកាលនោះ ព្រោះខ្ញុំនៅខាងក្រៅ នៅខាងចាំទទួលអ្នកទោសហ្នឹង ។

**ស៖** លោកកាលពីលោកនៅទីនោះ លោកហូបបាយនៅកន្លែងណា ហូបបាយរួមនៅកន្លែងណា រោងបាយ?

[១២:០១:២៤]

**ឆ៖** ខ្ញុំសូមជម្រាប អង្កាល់មុនខ្ញុំហូបបាយនៅក្បែរដាក់ផ្លាកឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ នៅខាងកើតជាប់ផ្លូវហ្នឹង កាលមុនគេធ្វើរោងនៅកន្លែងហ្នឹង ។ ក្រុមផ្នែកការពារ គឺហូបបាយកន្លែងហ្នឹង។

**ស៖** បើសម្លាប់មនុស្សច្រើនដូច្នេះ តើដែលមានធុំក្លិនទេ ក្លិនសពពេលដែលអាចកប់មិនជ្រៅ អាចមានធុំក្លិនទេ នៅក្នុងអំឡុងពេលលោកប្រតិបត្តិការធ្វើការងារនៅទីនោះ ឬក៏ហូបបាយអ៊ីចឹង តើមានធុំក្លិនដែរឬទេ ដែលធុំក្លិនទេ?

**ឆ៖** បាទ, ខ្ញុំសូមជម្រាបថា កាលនោះកន្លែងសម្លាប់ហ្នឹងនៅឆ្ងាយកន្លែងរោងបាយហូបហ្នឹង ហើយការធ្វើដំណើរការពារហ្នឹង ក៏ខ្ញុំមិនបានទៅដើរទៅដល់អីកន្លែងគេសម្លាប់នុំងដែរ គឺពីត្រឹមខាង មិនដល់ បេប្លែហឹម ផង ខ្ញុំបកមកវិញ មកដល់ផ្លូវឯកើតនេះ មកដល់ផ្លូវកើតផុតលូរទឹកស្អុយមក ដល់អាផ្លូវតូចមួយកាត់ទទឹងជើងត្បូងហ្នឹង បាទ ។

**ស៖** អរគុណលោក ហ៊ឹម ហ៊ុយ ឥឡូវនេះដល់ម៉ោងត្រូវសម្រាកពិសារអាហារថ្ងៃត្រង់ហើយ អង្គជំនុំជម្រះសូមជម្រាបលោក ហ៊ឹម ហ៊ុយ ថាលោកនៅត្រូវផ្តល់សក្ខីកម្មជាបន្តទៀត ដោយសារការផ្តល់សក្ខីកម្មនេះ គឺនៅសល់នូវបញ្ហាជាច្រើនដែលត្រូវសាកសួរលោក ដើម្បីឲ្យលោកជួយបំភ្លឺ ហើយឥឡូវនេះដល់ម៉ោងសម្រាកពិសារអាហារថ្ងៃត្រង់ អ៊ីចឹងអង្គជំនុំជម្រះប្រកាសសម្រាក ។

មន្ត្រី-- ហើយសវនាការនឹងលើកទៅបន្តនៅរសៀលនេះ ចាប់ពីវេលាម៉ោងមួយ និងសាមសិបនាទី ។ មន្ត្រីតុលាការ សម្របសម្រួលលោក ហ៊ឹម ហ៊ុយ ជាមួយនឹងអង្គភាពគាំពារសាក្សី និងអ្នកជំនាញ ដើម្បីគាត់បានទទួលនូវទីកន្លែងសម្រាក ឬក៏ទទួលម្ហូបអាហារសមរម្យនៅក្នុងអំឡុងពេលរង់ចាំនេះ ។

អនុរក្សមន្ទីរឃុំឃាំង នាំជនជាប់ចោទទៅកាន់បន្ទប់រង់ចាំ ហើយនាំគាត់មកកាន់បន្ទប់សវនាការនៅរសៀលនេះឲ្យបានមុនម៉ោងមួយកន្លះ ។

*[សវនាការសម្រាកពីម៉ោង ១២:០៤នាទី ដល់ម៉ោង ១៣:៣៥នាទី]*

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយចុះ ។ អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការស្តាប់សក្ខីកម្មសាក្សីឈ្មោះ ហ៊ឹម ហ៊ុយ ។

អញ្ជើញតំណាងសហព្រះរាជអាជ្ញា ។

**លោក វីលៀម ស្មីត៖**

សូមអរគុណលោកប្រធាន សូមសួស្តី ។ ខ្ញុំសូមលើកឡើងដោយសង្ខេប ព្រឹកមិញនេះសាក្សីហាក់ដូចជាមានអារម្មណ៍រំជើបរំជួលទាក់ទៅនឹងចំណុចមួយចំពោះសក្ខីកម្មរបស់គាត់ ខ្ញុំមិនដឹងថាតើជាការល្អដែរឬទេដែលថា ខ្ញុំសូមស្នើសុំថាឲ្យមានជំនួយទៅដល់សាក្សីក្នុងពេលដែលគាត់ផ្តល់សក្ខីកម្មដើម្បីឲ្យគាត់នឹងទទួលបានការជំនួយផ្សេងៗ នៅពេលដែលគាត់ផ្តល់សក្ខីកម្ម ប្រសិនបើគាត់មានអារម្មណ៍

រំដើបរំជួលនោះ ។

**ប្រធានអង្គជំនុំ៖**

អរគុណតំណាងសហព្រះរាជអាជ្ញាអន្តរជាតិដែលបានកត់សម្គាល់បញ្ហានេះ ។

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** លោក ហ៊ីម ហ៊ុយ នាពេលដែលលោកផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះនាពេលនេះ លោកមានមេធាវីជំនួយម្នាក់ហើយ ដែលខាងអង្គភាពគាំពារសាក្សី អ្នកជំនាញ បានផ្តល់ជូនលោក ហើយគាត់នៅទីនេះ គឺនៅខាងស្តាំដៃលោកនេះហើយ ។ ហើយអម្បាញ់មិញនេះ ខាងតំណាងសហព្រះរាជអាជ្ញាអន្តរជាតិបានលើកឡើងអំពីស្ថានភាពនៃការរំជួលចិត្តរបស់លោក ដែលគាត់បានកត់សម្គាល់ឃើញកាលពីព្រឹកមិញក្នុងការផ្តល់សក្ខីកម្មនេះ ។ ហើយគាត់ឲ្យយោបល់ថា គួរតែមានអ្នកជំនួយបន្ថែមផ្សេងទៀត តើលោកសុំឲ្យមានជំនួយបន្ថែមផ្សេងទៀត ក្រៅពីមេធាវីដែលអង្គភាពគាំពារសាក្សី និងអ្នកជំនាញបានផ្តល់ឲ្យលោកហើយដែរទេ ឬក៏មិនចាំបាច់ទេ?

**ឆ៖** បាទ, ខ្ញុំសុំឲ្យគាត់ជួយខ្ញុំខ្លះសិនទៅ ។

**ស៖** ការជួយនេះគ្រាន់តែអាចមកអង្គុយក្បែរលោកប៉ុណ្ណោះ គាត់មិនអាចប្រឹក្សាយោបល់អ្វីជាមួយលោកបានទេ គ្រាន់តែអាចមកអង្គុយឲ្យបានជាគ្នាប៉ុណ្ណោះ ។ ដោយឡែក មេធាវីជំនួយរបស់លោកក្នុងករណីលោកស្តាប់នូវសំណួរឯណាដែលលោកយល់ថា ពិបាកឆ្លើយ ឬក៏ការឆ្លើយទៅអាចជាលទ្ធផលនាំឲ្យមានពិរុទ្ធភាពដាក់បន្ទុកលើខ្លួនលោក ឬក៏ភាគីឲ្យធ្វើសេចក្តីអះអាង ឬអង្គជំនុំជម្រះឲ្យលោកធ្វើសេចក្តីអះអាងណាមួយ ដែលលទ្ធផលនៃសេចក្តីអះអាងរបស់លោកនោះអាចដាក់បន្ទុកលើលោក ។ ខណៈនោះទើបលោកសុំ-- អាចសុំដើម្បីធ្វើការប្រឹក្សាយោបល់ជាមួយមេធាវីរបស់លោក ។ ចំណែកឯសំណួរធម្មតាមិនមានស្ថានភាពដែលនាំឲ្យមានពិរុទ្ធភាពលើលោកទេនោះ គឺមិនមានទេ ។ ចំណែកឯថាមានជំនួយផ្សេងទៀត ដែលបំណងល្អរបស់ខាងតំណាងសហព្រះរាជអាជ្ញាអន្តរជាតិអំមិញហ្នឹង គឺជារឿងមួយដោយឡែក ។ បានន័យថា មានជំនួយមនុស្សម្នាក់គ្រាន់តែអង្គុយជិតក្បែរលោកប៉ុណ្ណោះ មិនមានសិទ្ធិទៅពិគ្រោះយោបល់ទៅ ពីរឿងថាឆ្លើយថា មិនឆ្លើយថា ឆ្លើយថាម៉េចនោះទេ ។ ការឆ្លើយ គឺជារឿងរបស់លោក តើលោកបានសម្គាល់ឃើញទេព្រឹកមិញ សូម្បីតែលោកបានមើលនូវកំណត់ហេតុដែលបានសុំពីអង្គជំនុំជម្រះអនុញ្ញាតឲ្យលោកបានពិនិត្យមើលពីម្សិលមិញ ក៏មានការកត់សម្គាល់ពីមេធាវីអំពីបញ្ហានេះដែរ ។ បានន័យថា គឺការសួរដេញដោលដោយផ្ទាល់មាត់ សួរដោយផ្ទាល់មាត់ ឆ្លើយ

ដោយផ្ទាល់មាត់ មិនមានការអាន មិនមានការជំនួយក្នុងការឆ្លើយនោះទេ ជំនួយនៅក្នុងករណីដែលជួបប្រទះនឹងបញ្ហាតែប៉ុណ្ណោះ ។ លោកយល់ទេ?

**ឆ៖** បាទ, ខ្ញុំយល់ ។

**ស៖** ឥឡូវហ្នឹង លោកអាចឆ្លើយនឹងសំណួររបស់យើងបានដូចពីព្រឹកមិញដែរទេ?

**ឆ៖** បាទ, បាន ។

**ស៖** ឥឡូវនេះ លោកចាំស្តាប់នូវសំណួរជាបន្តទៀត ។ លោកបាននិយាយប្រាប់ដល់អង្គសវនាការរួចហើយ អំពីទិដ្ឋភាពនានានៃការដែលបុគ្គលិកនៃមន្ទីរសន្តិសុខស-២១បាននាំអ្នកទោសដែលចាប់ឃុំឃាំងនៅមន្ទីរសន្តិសុខស-២១ ចេញក្រៅ ដើម្បីយកទៅសម្លាប់នោះ ។

សំណួរបន្តនេះ គឺយើងសួរថា ចុះកុមារដែលត្រូវបានចាប់ឪពុកម្តាយ ហើយយកកុមារទៅដាក់ឃុំឃាំងជាមួយម្តាយរបស់ពួកគេ ដែលលោកបាននិយាយប្រាប់ដល់អង្គជំនុំជម្រះកាលពីព្រឹកមិញ ។ ហើយបើមនុស្សទាំងអស់ដែលចូលទៅចាប់ខ្លួន ចូលទៅដាក់ឃុំឃាំងនៅទីនោះសុទ្ធតែត្រូវបានសម្លាប់ដោយមិនមានការលើកលែងបុគ្គលណាមួយទេ សួរថា ជោគវាសនានៃកូនៗរបស់ពួកគេ ដែលចាប់ទៅជាមួយនោះ តើគេទៅជាយ៉ាងណា?

**ឆ៖** បាទ,ខ្ញុំសូមជម្រាបថា ចំពោះកូនៗរបស់ម្តាយដែលចាប់យកមកនៅទួលស្លែង គឺខ្ញុំអត់បានដឹងថា គេយកទៅសម្លាប់របៀបយ៉ាងម៉េច ប៉ុន្តែខ្ញុំដឹងថា ក្រុមរបស់ ប៉េង ដែលជាអ្នកយកទៅសម្លាប់នៅកន្លែងទួលស្លែងតែម្តង ។

[១៣:៤៤:០៧]

**ស៖** តើគេនាំយកទៅសម្លាប់កុមារទាំងអស់នុ៎ង នៅម្តុំណាទៅ? សម្លាប់រួចកប់នៅម្តុំខាងណានៃសារមន្ទីរទួលស្លែងបច្ចុប្បន្ន តាមដែលលោកដឹង?

**ឆ៖** បាទ, តាមខ្ញុំនឹកឃើញពីរឿងអស់ហ្នឹង ប្រហែលជានៅខាងក្រោយគុកទួលស្លែង ។

**ស៖** តាមលោកដែលបានដឹងហ្នឹង លោកប៉ាន់ស្មានមើលកុមារដែលត្រូវបានចាប់ខ្លួនបញ្ជូនទៅទីនោះជាមួយនឹងឪពុកម្តាយរបស់គេហ្នឹង ចាប់តាំងពីលោកទៅធ្វើការរហូតដល់ថ្ងៃ៧ ខែមករា ឆ្នាំ១៩៧៩ ដែលជាថ្ងៃរំដោះទីក្រុងភ្នំពេញពីរបបកម្ពុជាប្រជាធិបតេយ្យនោះ តើមានកុមារប្រហែលប៉ុន្មាននាក់ដែលត្រូវបានចាប់ខ្លួន ហើយនិងបាននាំយកទៅសម្លាប់នៅមន្ទីរស-២១ នោះ? ប្រហែលសរុប ប្រហែលប៉ុន្មានដែរ តាមដែលលោកកត់សម្គាល់?

**ឆ៖** បាទ, ខ្ញុំអត់បានចំណាំមើលថា ចំនួនប៉ុន្មានទេ តែយ៉ាងតិចណាស់ក៏ ហាសិបទៅ មួយរយនាក់ដែរ ចំពោះកុមារ ។

**ស៖** លោកកត់សម្គាល់ឃើញថា កុមារដែលមានអាយុតិចជាងគេប្រហែលជាប៉ុន្មានដែរ? តាមដែលលោកបានមើលឃើញ ដែលកុមារនៅជាមួយម្តាយរបស់ពួកគេនោះ?

**ឆ៖** បាទ, តាមខ្ញុំយល់ គឺកុមារមានអាយុតាំងពីមួយឆ្នាំឡើង ទៅដល់៧-៨ឆ្នាំ ។

**ស៖** ចុះជោគវាសនានៃជនបរទេស ដែលលោកអះអាងថា លោកបានឃើញមាឌធំៗ ហើយមានសក់ទង់ដែងនោះ តើជោគវាសនារបស់គេយ៉ាងម៉េចដែរ?

**ឆ៖** បាទ, តាមខ្ញុំឃើញ គឺគេសួរចម្លើយហើយ ប្រហែលគ្នាបួននាក់ ដែលគេយកមកសម្លាប់នៅចំហៀងខាងត្បូងគុក ខាងលិចគុក ។ ចំហៀងខាងត្បូង ចំហៀងខាងលិច ដូចចំកន្លែង *បេប្លេហ៊ីម* ឬមួយក៏ខាងលិច *បេប្លេហ៊ីម* មិនដឹងទេកាលហ្នឹង ព្រោះពេលយប់ដែលគេដឹកយកមកកន្លែងហ្នឹង ។

**ស៖** លោកដឹងថា វិធីសម្លាប់ជនបរទេសទាំងបួននាក់ ដែលលោកអះអាងថាមានបួននាក់ហ្នឹងគេសម្លាប់វិធីណាដែរ លោកដឹងទេ?

**ឆ៖** បាទ, ខ្ញុំអត់បានដឹងថា គេសម្លាប់របៀបយ៉ាងម៉េចទេ ប៉ុន្តែ ឃើញគេដាក់កង់ឡានដុតនៅលើផ្លូវជាតិហ្នឹងតែម្តង ។

[១៣:៤៧:៣៦]

**ស៖** តើគេដុតទាំងរស់ ឬក៏សម្លាប់រួចហើយបានដាក់កង់ឡានគរពីលើ ឬក៏ដាក់លើគំនរកង់ឡានដុត? អាចខុសគ្នា មួយសម្លាប់រួចបានយកទៅដាក់លើគំនរកង់ឡានរួចដុត ឬក៏នៅរស់ដាក់ទៅហ្នឹងគំនរកង់ឡានហ្នឹងទាំងរស់ហើយដុត ដើម្បីធ្វើឲ្យជនបរទេសនោះស្លាប់ ។

**ឆ៖** តាមខ្ញុំយល់ គឺគេសម្លាប់ហើយបានគេយកទៅដាក់លើកង់ឡាននោះ បានគេដុត ។

**ស៖** អរគុណ ហើយជម្រាបលោក ហ៊ីម ហ៊ុយ ថា លោកក្នុងនាមជាសាក្សី បើលោកបានដឹងគឺលោកនិយាយថាបានដឹង ហើយមិនគប្បីនៃប្រើពាក្យថា តាមការសន្និដ្ឋានរបស់ខ្ញុំទេ ពីព្រោះសាក្សីមិនមានសិទ្ធិនៅក្នុងការធ្វើសន្និដ្ឋានអំពីហេតុការណ៍ណាមួយនោះឡើយ គឺបើបានឃើញ បានដឹង បានឮដោយផ្ទាល់ ដោយខ្លួនឯង នោះគឺលោកនិយាយការពិតនូវអ្វី ដែលលោកបានដឹង បានឮ បានឃើញយើងបានប្រាប់អំពីភារកិច្ចរបស់លោកក្នុងនាមជាសាក្សីរួចមកហើយតាំងពីពេលដំបូង លោកនៅចាំដែរទេ?

**ឆ៖** បាទ, ខ្ញុំនៅចាំ ។ ខ្ញុំសូមជម្រាបថា ពេលដែលគេយកទៅដុតហ្នឹង ទម្លាប់ការងារនៅស-២១ គឺគេសម្លាប់ហើយបានគេយកទៅដាក់ដុត ។ ហ្នឹងជនជាតិបរទេស តែចំពោះជនជាតិខ្មែរ និងជនជាតិដទៃទៀត គឺសម្លាប់ហើយ គឺកប់ចោល ។

**ស៖** ចុះចំណែកឯឈ្លើយសឹកវៀតណាមវិញ ដែលលោកបានអះអាងកាលពីព្រឹកមិញថា មានចំនួនប្រហែលជាហុកសិបនាក់ ដោយមានចំនួនដែលលោកបានទទួលបញ្ជាពីជនជាប់ចោទ ទៅដឹកយកពីខេត្តស្វាយរៀងមកកាន់មន្ទីរសន្តិសុខស-២១ ហើយមួយចំនួនទៀត គឺអង្គភាពកងទ័ព គេបានដឹកខ្លួនគេមកប្រគល់ឱ្យលោកដើម្បីនាំបញ្ចូលទៅអ្នកឃុំគ្រង ដើម្បីឃុំឃាំងអ្នកទាំងអស់នោះនៅក្នុងមន្ទីរស-២១។ សំណួរថាតើជោគវាសនារបស់ឈ្លើយសឹកវៀតណាមទាំងអស់នោះ វាយ៉ាងណាដែរ?

**ឆ៖** បាទ, ខ្ញុំសូមជម្រាបលោក! ចំពោះឈ្លើយសឹកវៀតណាម ដែលបានចាប់យកមកដាក់គុកស-២១នេះ ក្រោយពីសួរចម្លើយហើយ គឺយកទៅសម្លាប់ចោលនៅខាងត្បូង ចំហៀងខាងលិចនៃគុកទួលស្លែង ។

**ស៖** សម្លាប់ក្នុងពេលតែមួយ បានន័យថា ក្នុងយប់ ឬក៏ថ្ងៃតែមួយ ឬក៏សម្លាប់ពេលវេលាខុសៗគ្នា?

**ឆ៖** បាទ, ខ្ញុំសូមជម្រាប! ការសម្លាប់នេះ គឺវាអត់មានពេលវេលាតែមួយទេ ព្រោះការសួរចម្លើយហើយ ដឹងថាអ្នកណាសួរហើយ អ្នកណាសួរមិនហើយ យកតែអ្នកណាសួរហើយ យកទៅសម្លាប់ ។

**ស៖** ឥឡូវនេះ ខាងអង្គភាពគាំពារសាក្សីអ្នកជំនាញ អាចរកបានបុគ្គលិកផ្នែកខាងសុខភាពផ្លូវចិត្ត តើលោកទទួលយកគាត់ដើម្បីឱ្យទៅអង្គុយជិតលោកទេ ដើម្បីឱ្យមានភាពកក់ក្តៅក្នុងការផ្តល់សក្ខីកម្មនេះលោក ហ៊ឹម ហ៊ុយ?

**ឆ៖** បាទ, ខ្ញុំសូមជម្រាប មិនបាច់ទេ ។

**ស៖** អរគុណ ។ អ៊ីចឹងឆ្លើយបន្តទៀត មន្ត្រីតុលាការឱ្យគាត់រង់ចាំនៅខាងក្រោមសិនទៅក្នុងករណីចាំបាច់នៅពេលណាដែលជួបនឹងបញ្ហាតប់ប្រមល់ខ្លាំង អាហ្នឹងចាំយើងចាត់ចែងសាជាថ្មីម្តងទៀត ឥឡូវនេះគាត់មានអារម្មណ៍ល្អ មិនមានអីទេ ។

ឥឡូវនេះ ដល់ទៅក្នុងប្រតិបត្តិការ នៃការនាំមនុស្សយកទៅសម្លាប់នៅបឹងជើងឯង ។ សំណួរទីមួយសួរថា តើលោកដឹងទេថា តើការសម្រេចយកបឹងជើងឯងធ្វើជាកន្លែងសម្លាប់មនុស្ស អ្នកទោស

ដែលឃុំឃាំងនៅមន្ទីរស-២១ នោះ គេសម្រេចយកទីនោះនៅថ្ងៃខែឆ្នាំណា? លោកចាំដែរទេ?

**ឆ៖** បាទ, ខ្ញុំអត់បានចាំថ្ងៃខែ ដែលគេសម្រេចយកកន្លែងជើងឯងហ្នឹង ធ្វើជាកន្លែងការសម្លាប់មនុស្សនៅថ្ងៃណាទេ ។

[១៣:៥៤:១៥]

**ស៖** តាមលោកចាំ ប្រហែលជាឆ្នាំណាដែរ? ហើយមូលហេតុអី បានជាគេសម្រេចយកជ្រើសរើសយកបឹងជើងឯកធ្វើជាកន្លែងសម្លាប់មនុស្ស?

**ឆ៖** បាទ, ខ្ញុំជម្រាបថា បឹងជើងឯកគឺនៅក្នុងឆ្នាំ៧៧ តែការសម្រេចនោះគឺខ្ញុំអត់ដឹងថា គាត់ទាំងពីរនាក់នេះសម្រេចតាមរបៀបណា គឺខ្ញុំអត់ដឹងទេ ។

**ស៖** អរគុណ ។ លោករកនឹកមើល៍ថា ហេតុការណ៍ទាំងឡាយនៃការចាប់បញ្ជូនអ្នកទោសចេញពីមន្ទីរសន្តិសុខស-២១ភ្នំពេញ ទៅជើងឯក តើការចាត់ចែងបញ្ជូនទៅហ្នឹងតាមរបៀបណា? ដោយមធ្យោបាយអ្វី ហើយប្រព្រឹត្តទៅនៅពេលយប់ ឬក៏ពេលថ្ងៃ?

**ឆ៖** ខ្ញុំសូមជម្រាប! ពេលដែលដឹកជញ្ជូនយកទៅសម្លាប់នៅជើងឯកហ្នឹង គឺនៅពេលយប់ តែសំណុំរឿងឈ្មោះ គឺគេរៀបចំតាំងពីថ្ងៃណោះ ពួកតាហ៊ី ពួកអីហ្នឹង អ្នករៀបចំជាមួយ បងធី ហើយនិងប៉េង គ្នាចំនួនប៉ុន្មាននាក់ៗ គឺខាងគាត់រៀបចំពីថ្ងៃហើយ ។

**ស៖** ចុះការដឹកជញ្ជូននេះ គេដឹកជញ្ជូនដោយមធ្យោបាយអ្វីទៅ គេបណ្តើរទៅ ឬក៏ដឹកជញ្ជូនតាមមធ្យោបាយអ្វី?

**ឆ៖** បាទ, ខ្ញុំសូមជម្រាប! ពេលដែលគេរៀបចំឈ្មោះហើយ អ្នកណានៅបន្ទប់ណាៗ គេដឹងហើយដល់ពេលយប់ ម៉ោងប្រាំមួយពេលងងឹត ប្រាំមួយ ឬក៏ប្រាំមួយកន្លះហ្នឹង គេចាប់ផ្តើមយកចេញមក គេដាក់ខ្នោះ ចងមុខ ចងអីហើយ ដល់ហើយគេបណ្តើរចេញពីគុកមក គឺពួកខ្ញុំយកឡានទៅនៅចាំមាត់ទ្វារច្រកដែលចូលគុកហ្នឹង ហើយដាក់កៅអីមួយនៅពីក្រោយកន្ទុយឡានហ្នឹង ដល់ហើយពីរនាក់អ្នកចាប់លើកអ្នកទោសឲ្យឡើងជាន់លោកកៅអីហ្នឹង ហើយអ្នកនៅលើឡានពីរនាក់ទៀត ដែលក្រៀកអ្នកទោសហ្នឹងចូលទៅក្នុងឡានរៀបចំឲ្យអង្គុយនៅក្នុងឡានហ្នឹង ។

**ស៖** ហើយបន្ទាប់មកធ្វើម៉េចទៀត? មានការតប្រតិកម្មអីតវ៉ាពីពួកអ្នកទោសដែរឬទេការដែលយើងធ្វើដូច្នេះ ឬក៏មានការប្រើពាក្យពេចន៍កុហក់គាត់ថាម៉េច នៅក្នុងអំឡុងពេលដែលរៀបចំបញ្ជូនគាត់ពីកន្លែងឃុំឃាំងឡើងឡានដើម្បីនាំយកទៅជើងឯកនោះ?

**ឆ៖** ខ្ញុំសូមជម្រាប! ពេលដែលគេរៀបចំអ្នកទោសដែលដាក់ខ្នោះចងមុខហ្នឹង គឺមានយុទ្ធវិធីដែលតាហ៊ អ្នកណែនាំពួកកម្លាំងនៅខាងក្នុងហ្នឹង គឺប្រាប់ថា ពេលដែលដោះយកចេញហ្នឹងប្រាប់ថាឲ្យចេញពីគុកនេះដើម្បីទៅនៅផ្ទះថ្មី ។ ធ្វើយ៉ាងម៉េចកុំឲ្យអ្នកទោសដឹងខ្លួនថា យកគេយកទៅសម្លាប់ចោល ហើយពេលដែលយកឡើងហ្នឹងទៀត ក៏ថាគ្មានយកទៅណាទេ គឺយកទៅឲ្យនៅផ្ទះថ្មីទេ ។ ចេះតែនាំគ្នាលើកឡើងឡានទៅ ហើយប្រាប់ថាអ៊ីចឹងទៅ។

[១៣:៥៨:៣៩]

**ស៖** អ៊ីចឹងពាក្យថា "យកទៅនៅឲ្យផ្ទះថ្មីហ្នឹង" គឺប្រើប្រាស់ជាទូទៅ គ្រប់ពេលវេលា ឬក៏គ្រប់ករណីនៃការនាំមនុស្សចេញពីកន្លែងឃុំឃាំងយកទៅសម្លាប់ហ្នឹង គឺប្រើពាក្យភូតកុហកថា "នាំទៅនៅផ្ទះថ្មី" គ្រប់ករណីទាំងអស់ អ៊ីចឹងមែនទេ?

**ឆ៖** បាទ, គ្រប់ករណីទាំងអស់ ដែលគាត់ណែនាំពួកផ្នែកការពារ និងដឹកជញ្ជូន គឺឲ្យធ្វើរបៀបហ្នឹងរាល់ពេល ។

**ស៖** ក្នុងការដឹកជញ្ជូនទៅមួយយប់ៗហ្នឹង មួយលើកៗហ្នឹងតើដឹកប៉ុន្មានរថយន្ត? ហើយក្នុងមួយរថយន្តហ្នឹងជាមធ្យមដាក់អ្នកទោសប៉ុន្មាននាក់ដែរ?

**ឆ៖** បាទ, ខ្ញុំសូមជម្រាប! ពេលដឹកជញ្ជូនហ្នឹង គឺវាមានរថយន្តតូច រថយន្តធំ ជួនកាលមាន*ឡង់រ៉ូវែ* ផងជួនកាលមាន*កាត់កាត់* របស់ចិនដឹកទៅ ។ ក្នុងឡានមួយគឺ*កាត់កាត់* ពីរហ្នឹងបេប៉ុន្មានចូលហុបសិបនាក់ ។ បាទដូចឡង់រ៉ូវែ មួយទៀតប៉ុន្មាន វាប្រហែលជាជាងដប់នាក់ទៀត ។ ជួនកាលដាក់បានទៅដល់ទៅចិតសិបនាក់ ប៉ែតសិបនាក់ ឬក៏មួយរយនាក់ឯណេះក្នុងពេលម្តង ។

**ស៖** ចុះការធ្វើដំណើរទៅតាមផ្លូវ មានដែលជួបឧបសគ្គអ្វីទេ? ហើយធ្វើដំណើរចេញពីមន្ទីរសន្តិសុខស-២១មជ្ឈមណ្ឌលភ្នំពេញ ដោយរថយន្តដឹកដូច្នេះ ទៅដល់កន្លែងបឹងជើងឯកហ្នឹង ចំណាយពេលវេលាប្រហែលប៉ុន្មានដែរ ទើបទៅដល់ទីនោះ?

**ឆ៖** ខ្ញុំអត់បានសន្និដ្ឋានថា ពេលវេលាប្រហែលជាប៉ុន្មានទេ ។ ប៉ុន្តែ តាមការប៉ាន់ស្មានមើលប្រហែលជាកន្លះម៉ោងទៅដល់ហើយ ជើងឯក ។

**ស៖** ចុះពេលទៅដល់ទីនោះ ពេលដែលបើករថយន្តជូនអ្នកទោសទៅដល់កន្លែងបឹងជើងឯក តើប្រតិបត្តិការនៃកម្លាំងបុគ្គលិកសន្តិសុខស-២១ហ្នឹង គេចាត់ចែងយ៉ាងដូចម្តេច ពេលដែលទៅដល់?

**ឆ៖** បាទ, ពេលដែលទៅដល់ហ្នឹង គឺអង្គភាពមួយក្រុមដែលនៅចាំទទួលការសម្លាប់ហ្នឹង គឺគេបញ្ឆេះម៉ាស៊ីនភ្លើងមួយ មានអំពូលម៉ែត្រក្នុងផ្ទះ លើផ្ទះ ហើយនិងអត់ទាន់ដាក់ទៅកន្លែងរណ្តៅទេ ដល់ពេលឡានទៅដល់ គេចាប់ផ្តើម ពួកខ្ញុំចាប់ទ្វារឡានទៅ បើកអាកំណាត់ឡានពីក្រោយ ហើយទម្លាក់អាសន្ទះឡានពីក្រោយហ្នឹង ហើយដាក់កៅអីមួយ នាំគ្នាយកអ្នកទោសចុះម្តងមួយៗបញ្ចូលទៅក្នុងផ្ទះខាងក្រោមផ្ទះហ្នឹង គឺមានបន្ទប់មួយធំខាងក្រោយហ្នឹង រួចហើយបានគេ ពួកក្រុមគេយកកម្លាំងរបស់គេទៅហើយយកភ្លើង យកអីទៅដាក់កន្លែងរណ្តៅ ដើម្បីធ្វើការសម្លាប់ ។

[១៤:០២:១៤]

**ស៖** ចុះប្រតិបត្តិការម៉េចទៀត នៅពេលដែលសម្លាប់គេប្រតិបត្តិការយ៉ាងដូចម្តេច?

**ឆ៖** បាទ,ដល់ពេលសម្លាប់ហ្នឹង គឺទៅដល់ហ្នឹង កម្លាំងពួកខ្ញុំដែលទៅដល់ប៉ុន្មានជួយការពារគ្នាហើយកម្លាំងដែលនៅណេះ គឺទៅនៅមាត់រណ្តៅចាំធ្វើការសម្លាប់ ហើយនិងកម្លាំងណាដែលរៀបចំនៅការពារមាត់ច្រកទ្វារផង ហើយនិងបណ្តើរម្នាក់ម្តងៗយកទៅឲ្យគេសម្លាប់នៅកន្លែងរណ្តៅ ។

**ស៖** មានការត្រួតពិនិត្យបញ្ជីអីទេ ឧបមាថា អំមិញលោកនិយាយថា ការរៀបចំក្នុងការដឹកជញ្ជូនចេញម្តងៗ មានការរៀបចំបញ្ជីរវាងឈ្មោះ ហ៊ា ជាមួយនិងឈ្មោះ ធី ដែលជាអ្នកកាន់កាប់បញ្ជីក្នុងការបញ្ចេញអ្នកទោសពីកន្លែងមន្ទីរឃុំឃាំងដាក់រថយន្តហ្នឹងទៅសម្លាប់។ ទីមួយសួរថា ពេលដែលនាំបញ្ជូនគាត់ឡើង ពួកអ្នកទោសដែលជាជនរងគ្រោះនៅក្នុងអំពើហ្នឹង គេដាក់ទៅត្រួតពិនិត្យ មានការត្រួតពិនិត្យផ្ទៀងទាត់ទេ ឧទាហរណ៍ថា ឈ្មោះ “ក” “ខ” “គ” អីចឹងដូចថា ម្តៃនាក់ ឬក៏ដប់នាក់ហ្នឹង មានការផ្ទៀងផ្ទាត់បញ្ជីអីចឹងដែរទេ មុននឹងរុញឲ្យឡើងរថយន្តនោះ?

**ឆ៖** បាទ, ខ្ញុំសូមជម្រាបថា ពេលដែលគេបញ្ជូនចេញពីគុកមក គឺគេធ្វើឈ្មោះ ធ្វើអីហើយហើយគេដឹងមានចំនួនថាមានប៉ុន្មានហើយ ។ ដល់អីចឹងពួកខ្ញុំទៅ ពួកខ្ញុំដឹងថាចំនួនប៉ុន្មាន ខ្ញុំយកទៅ ទៅដល់នោះខ្ញុំកត់ឈ្មោះ គេឲ្យខ្ញុំកត់ឈ្មោះ ដើម្បីឈ្មោះហ្នឹងដើម្បីទូរទាត់ក្នុងបញ្ជីរបស់គេ ដែលយកទៅចំនួនប៉ុន្មាននាក់ ហើយឈ្មោះអីខ្លះ ធ្វើយ៉ាងម៉េចកុំឲ្យបាត់ បើបាត់ត្រូវតែទទួលខុសត្រូវ អ្នកដែលដឹកយកទៅ ។

**ស៖** អ៊ីចឹងបានន័យថា ជារបៀបនៃការអនុវត្តនោះ ពេលដែលទៅដល់ហើយ ហើយការដែលនាំមនុស្សចេញពីកន្លែងដែលស្តុក យើងថាស្តុកទុកដាក់ក្រោមផ្ទះនោះ ហើយមានការបញ្ឆេះម៉ាស៊ីភ្លើងមានអំពូលភ្លើង និងសំឡេងម៉ាស៊ីនផងនោះ ពេលដែលនាំម្នាក់ម្តងៗទៅ ក៏យើងធ្វើការត្រួតពិនិត្យពីបញ្ជី

ដែរថា ក, ខ, គ ឬក៏មនុស្សទីមួយ ទីពីរ ទីបី ដែលបាននាំចេញទៅយើងគូស ដើម្បីត្រួតពិនិត្យថាគ្រប់ចំនួនដើម្បីផ្ទៀងផ្ទាត់ថាតើមានការរត់គេច ឬក៏គ្រប់ចំនួនត្រឹមត្រូវ ដែលផ្ទៀបជាមួយនិងបញ្ជីដែលបានបញ្ចេញពីគុកទៅនោះ ធ្វើអ៊ីចឹងដែរទេ?

**ឆ៖** បាទ, គឺធ្វើអ៊ីចឹង ទៅដល់នោះ គឺកត់ឈ្មោះទៀត ឈ្មោះអី ឈ្មោះ “ក” កត់ឈ្មោះ “ក” អ៊ីចឹងទៅ ដាក់លេខមួយ គ្រប់ដល់ប៉ុន្មានចំនួនថា ប៉ែតសិបនាក់ ឬក៏មួយរយនាក់ឲ្យគ្រប់ចំនួនអ៊ីចឹង បានយកបញ្ជីហ្នឹងទៅឲ្យទូទាត់នៅភ្នំពេញវិញ ។

**ស៖** ពេលដែលការដឹកជញ្ជូនមនុស្សទៅដល់កន្លែងវាលពិឃាតនៅជើងឯកហ្នឹង មានការដឹកដោយការដឹកដោយរថយន្តហ្នឹងទៅដល់ក្បែរផ្ទះ ដែលនៅទីនោះ ដែលថាមានមនុស្សមួយក្រុមនៅរង់ចាំនៅទីនោះ ឬក៏យើងមានការឈប់ឲ្យឆ្ងាយ ឈប់រថយន្តហ្នឹងនៅឆ្ងាយ ដែលអាចធ្វើដំណើរដល់ទៅប្រាំមីនុត ឬក៏ដប់មីនុត ទើបទៅដល់ទីនោះដែរឬទេ? ឬក៏រថយន្តដឹកជញ្ជូនដល់កន្លែងផ្ទះនោះតែម្តង?

**ឆ៖** បាទ, ខ្ញុំសូមជម្រាបថា ការដឹកជញ្ជូននោះគឺទៅដល់អែបនឹងមាត់ច្រកផ្ទះហ្នឹងតែម្តង ។

**ស៖** ហើយមួយទៀតគឺច្បាស់លាស់ទេថា អ្នកទោសទាំងអស់ដែលយកទៅដល់ទីនោះ គឺដាក់ចុះពីរថយន្តយកទៅឲ្យអង្គុយនៅខាងផ្នែកក្រោមផ្ទះដែលមានបិទជិតជញ្ជាំងជិតបន្ទប់ធំដែលនៅក្រោមផ្ទះដែលបិទជញ្ជាំងជិតនោះ ។ ជាការអ៊ីចឹងមែនទេ ឬក៏ដាក់ទៅខាងលើផ្ទះ?

**ឆ៖** បាទ, ខ្ញុំសូមជម្រាបថា លើផ្ទះអត់មានអ្នកទោសនៅទេ អ្នកទោសគឺគេឲ្យដាក់ខាងក្រោមផ្ទះទាំងអស់ ព្រោះគេវាយបន្ទប់ធំនៅក្នុងហ្នឹង ក្រោមផ្ទះហ្នឹង ។

**ស៖** តាមធម្មតាលោកបានកត់សម្គាល់ឃើញថា អំពូលភ្លើងដែលគេប្រើប្រាស់ហ្នឹងច្រើនទេ មានចំនួនច្រើនទេ? ហើយម៉ាស៊ីនដែលគេបញ្ឆេះសម្រាប់ធ្វើការនៅទីនោះ មានដល់ធំទេ កម្លាំងសេសប៉ុន្មានសេសទៅ?

**ឆ៖** បាទ, ខ្ញុំអត់បានចាំថា ម៉ាស៊ីននោះប៉ុន្មានសេសទេ ប៉ុន្តែម៉ាស៊ីននោះអាចដាក់អំពូលភ្លើងបានជិតដប់ អំពូលម៉ែត្រខ្លីៗ ប្រហែលជាកន្លះម៉ែត្រអីហ្នឹង ប្រាំមួយតឹកអីហ្នឹង ។

**ស៖** ចម្ងាយនៃទីកន្លែងដែលពីផ្ទះ ដែលលោកបាននិយាយអំមិញពេលកន្លែងទៅដល់ដាក់នៅផ្ទះសិន ហើយមុននឹងបញ្ជូនទៅសម្លាប់ហ្នឹង ពីកន្លែងហ្នឹងទៅចំណុចរណ្តៅដែលត្រូវសម្លាប់ហ្នឹងជាមធ្យមចម្ងាយប្រហែលប៉ុន្មានដែរ?

**ឆ៖** បាទ, ខ្ញុំសូមជម្រាបប្រហែលជាហាសិបម៉ែត្រ ឬក៏ហាសិបម៉ែត្រជាងកន្លែងនោះ ។

**ស៖** មនុស្សច្រើនចិតសិប ប៉ែតសិបនាក់ ឬក៏មួយរយនាក់ អ៊ីចឹងនៅក្នុងប្រតិបត្តិការនៅក្នុងការសម្លាប់ម្តងតាំងពី-- ចំនួនច្រើនសន្ធឹកសន្ធាប់ដូចប៉ុណ្ណេះ ប្រហែលជារយៈពេលប៉ុន្មានទៅបានអស់?

[១៤:០៧:៥១]

**ឆ៖** បាទ, រយៈពេលយូរមក តាំងពីម៉ោងចេញពីភ្នំពេញ ប្រហែលជាម៉ោងប្រាំបី ទៅដល់ណោះវាចូលម៉ោងប្រាំបី កន្លះរៀបចំហើយវាចូលម៉ោងប្រាំបួន ប្រហែលជាម៉ោងមួយ ម៉ោងពីរ បានហើយ ។

**ស៖** ចុះរណ្តៅសម្រាប់កប់សពវិញ តើមានការត្រៀមលក្ខណៈយ៉ាងម៉េចដែរ? អ្នកណាខាងណាក្រុមណាទទួលបន្ទុកក្នុងការជីករណ្តៅ? ហើយក្រុមណាជាអ្នកទទួលបន្ទុកក្នុងការកប់សព ក្រោយពេលសម្លាប់រួច?

**ឆ៖** ខ្ញុំសូមជម្រាប គឺក្រុមបង តេង ដែលជាអ្នកទទួលបន្ទុកនៅក្នុងនោះមួយក្រុម កន្លែងជើងឯកហ្នឹង គាត់ទទួលបន្ទុកខាងជីករណ្តៅ និងចាំសម្លាប់ ហើយនិងកប់ គឺក្រុមរបស់គាត់តែម្តង ។

**ស៖** ហើយលោកដឹងទេថា ការសម្លាប់ឬក៏របៀបសម្លាប់មនុស្ស នៅបឹងជើងឯកនោះវា គេប្រព្រឹត្តទៅរបៀបយ៉ាងដូចម្តេច? ជាការបាញ់ កាប់ចាក់ ឬក៏វាយ ឬក៏គេធ្វើយ៉ាងម៉េច? មានលោកដឹងទេអំពីរបៀបនៃការសម្លាប់មនុស្សនៅទីនោះ ។

**ឆ៖** បាទ, គឺគេណែនាំឲ្យសម្លាប់មនុស្ស តាមរបៀបឲ្យលុតជង្គង់នៅមាត់រណ្តៅ ហើយគេនឹងយកដែក អាដែកភ្លៅរទេះនោះ គេវ៉ៃកញ្ចឹងកទៅ ដល់ហើយអ្នកទោសនោះក៏សន្លប់ សន្លប់ហើយគេមានកាំបិតមួយទៀត គឺកាំបិតចិតត្នោតអ៊ីចឹង គេអារ-ក អារ-កហើយ បានគេដោះខ្នោះដៃ ឬមួយក៏ខ្សែដែលចងសេកហ្នឹង ហើយបានគេបោះចូលទៅក្នុងរណ្តៅ ។

**ស៖** អ៊ីចឹងបានសេចក្តីថា ការសម្លាប់ហ្នឹង គឺមិនមែនវ៉ៃទម្លាក់រណ្តៅទេ គឺការសម្លាប់នៅមាត់រណ្តៅទេ ទាល់តែសម្លាប់រួច អារ-ករួចហើយបានដោះខ្នោះចេញ បានគេលើក ឬក៏គេរុញសពនោះទម្លាក់ទៅក្នុងរណ្តៅ អ៊ីចឹងមែនទេ?

**ឆ៖** បាទ, គឺអ៊ីចឹងមែន ។

**ស៖** តាមដែលលោកដឹង ការសម្លាប់ដោយដឹកនឹងរថយន្តដែលមានចំនួនច្រើនៗហ្នឹង តាមធម្មតាវាមានក្នុងអំឡុងពេលប្រហែលប៉ុន្មានថ្ងៃមានម្តង ឬក៏មានញឹកញាប់ប៉ុនណា? លោកអាចដឹងបានទេជាមធ្យមយើងមិនអាចផ្ទៀងផ្ទាត់ទេ ជាមធ្យមប្រហែលជាប៉ុន្មានថ្ងៃដឹករបៀបនេះម្តង?

**ឆ៖** បាទ, តាមខ្ញុំដឹង គឺពីមួយអាទិត្យទៅកន្លះខែ គឺដឹកទៅម្ដង ពេលដែលគេសួរចម្លើយសរុបបានច្រើន ។

[១៤:០៧:៥២]

**ស៖** លោកដឹងទេថា ក្រោយពេលសម្លាប់រួចហ្នឹង គេអ្នកដែលទទួលភារនៅក្នុងការកប់សពហ្នឹងគេកប់ភ្លាមទេ ឬក៏គេទុកចាំព្រលឹមឡើងបាន ថ្ងៃបន្ទាប់បានគេលប់ កាយដីលប់ ឬក៏មានផែនការត្រូវលប់ភ្លាមៗ?

**ឆ៖** បាទ, ខ្ញុំសូមជម្រាបថា ពេលដែលដឹកយកទៅសម្លាប់ហើយហ្នឹង គឺគេឲ្យកប់ភ្លាមឲ្យជិតភ្លាមគឺអត់មានឲ្យពេលទុកដល់ស្អែកទេ ។

**ស៖** តាមលោកដឹងតើនៅទីនោះ មានការបញ្ជូនកុមារទៅសម្លាប់នៅទីនោះដែរឬទេ?

**ឆ៖** បាទ, កាលពួកខ្ញុំដឹកទៅនឹងក៏គ្មានបានយកកុមារអីទៅទេ ព្រោះកុមារដឹកឡានទៅវារញ៉ៅវញ៉ៅ គេលាក់ការណ៍មិនឲ្យដឹងទេ ព្រោះកុមារគឺនៅលើ ពួកប៉េង សម្លាប់នៅទួលស្លែងតែម្តង ។

**ស៖** នៅជើងឯកហ្នឹង តើមានបញ្ជូនឈ្លើយសឹកវៀតណាម ទៅសម្លាប់នៅជើងឯកដែរទេ?

**ឆ៖** បាទ, ការដឹកជញ្ជូនយកទៅហ្នឹង តាមខ្ញុំដឹង គឺអត់មានយកទៅដល់ជើងឯកទេ ជនជាតិវៀតណាម ។

**ស៖** ក្នុងអំឡុងពេលដែលលោកធ្វើការងារជាបុគ្គលិកនៅក្នុងកងការពារ ហើយបានទៅដល់ជើងឯកហ្នឹង លោកដឹងថា តើមានព្រឹត្តិហេតុនៃអ្នកទោសដែលបានរត់រួចចេញពីការសម្លាប់នៅទីនោះដែរឬទេ?

**ឆ៖** បាទ, ខ្ញុំសូមជម្រាប! ពេលដែលខ្ញុំដឹកយកទៅគ្នាច្រើនហ្នឹង គឺបានរត់រួចម្នាក់ ហើយម្នាក់នោះ គឺខ្ញុំអត់ដឹងទេ ព្រោះខ្ញុំមើលបញ្ជីថាគ្រប់ហើយ បានខ្ញុំ-- ចុះគេថា ពីនេះមកថា ថាប៉ុណ្ណេះ ខ្ញុំទៅដល់ណោះ គឺឃើញប៉ុណ្ណឹងដែរ ហើយដល់ពេលដែលមកវិញព្រលឹមឡើង គឺមានកាលនោះកងពល៧០៣ នៅក្បែរហ្នឹងដែរ គេចាប់បានអ្នកទោសម្នាក់ដែលចងសេកហើយហ្នឹង គឺគេ*តេឡេហ្វូន* រាយ-ការណ៍មក តាឌុច នេះមក តាឌុច ហ្នឹងបាននាំគ្នាឆោឡោ តាហ៊ី ឆោឡោ ថាពួកខ្ញុំព្រលែងមនុស្សព្រលែងអ្នកទោស ហើយក៏គេយកមក យកមកហើយក៏គាត់ តាហ៊ី ឲ្យពួកខ្ញុំទៅទាំងអស់គ្នា ទាំងអ្នកដឹកទៅ ទាំងអ្នកនៅជើងឯកហ្នឹង ហៅគ្នាប្រជុំទាំងអស់ រកមុខមាត់រកអ្នកណាដែលថា ព្រលែង គេឲ្យរកឲ្យឃើញ ហៅគ្នាប្រជុំមួយថ្ងៃត្រង់ រកអត់ឃើញមិនដឹងអ្នកណាព្រលែង ហើយព្រលែងហ្នឹង គឺទៅ

ទាំងសេក ទាំងចំណាងទាំងអស់ហ្នឹង ដល់ហើយខាង៧០៣ ចាប់មក បានអ៊ីចឹងបាននាំគ្នាភ័យ ។

[១៤:១៥:៣៦]

**ស៖** ចុះមនុស្សដែលអ្នកទោសថារត់រួចខ្លួន ហើយកងពល៧០៣ចាប់បានវិញហ្នឹង តើគេយកទៅទីណា?

**ឆ៖** បាទ, គេបញ្ជូនមកគុកវិញទៀត ។

**ស៖** ឥឡូវបកក្រោយបន្តិច និយាយពីរឿងអ្នកទោសសំខាន់ៗ ដែលមានឋានៈក្នុងជួរអាជ្ញាធរនៃរបបកម្ពុជាប្រជាធិបតេយ្យ និងកម្មាភិបាលនៅក្នុងជួរបក្សនៃរបបកម្ពុជាប្រជាធិបតេយ្យនោះ តើគេយកទៅសម្លាប់នៅកន្លែងណា? យកមកបឹងជើងឯកដែរ ឬក៏សម្លាប់នៅកន្លែងណា?

**ឆ៖** បាទ, អ្នកធំៗដែលជាកម្មាភិបាលសំខាន់ៗ គឺគេមិនអាចយកទៅជើងឯកទេ គឺគេសម្លាប់នៅក្បែរទួលស្លែងហ្នឹងតែម្តង ។

**ស៖** ក្បែរទួលស្លែងហ្នឹង តាមលោកដឹងប្រហែលជានៅខាងណា ខាងជើង ខាងត្បូង ខាងលិច ឬក៏ខាងកើតនៃទួលស្លែង?

**ឆ៖** បាទ, មានតែខាងត្បូង ហើយនិងខាងលិចទេ ដែលគេយកទៅសម្លាប់ ។

**ស៖** ខាងលិចហ្នឹង អាចឆ្ងាយផុតពីដែលលោកថា ឆ្ងាយមិនធំក្លិនហ្នឹង អាចឆ្ងាយផុតពីផ្លូវពីទួលទំពូងមកវត្ត មកខាងកើតពហុកីឡដ្ឋានជាតិ អាផ្លូវវត្តពីទួលទំពូងហ្នឹងមក ពីស្តុបទួលទំពូង ខាងលិចផ្សារទួលទំពូងរហូតមកដល់យើងបុកមកខាងកើតស្ពាតអូរឡាំពិក គឺវត្តមហាមន្ត្រី តើតអាចហួសហ្នឹងទៅលិចទេ ឬក៏ក្របខ័ណ្ឌត្រឹមតែផ្លូវហ្នឹងមកខាងកើតទេ នៅទីន្លែងដែលសម្លាប់នោះ?

**ឆ៖** បាទ, ចំហៀងខាងត្បូងគឺមានក្បែរៗនៃអូរហ្នឹង ចំហៀងខាងត្បូងក្បែរអូរ ហើយបើចំហៀងខាងលិច ខាងលិចផ្លូវ *បេឡេហ៊ីម* ខាងលិចផ្លូវជាតិមួយកាត់ទទឹងក្រោយ ស-២១ ហ្នឹង ។

**ស៖** ចុះបុគ្គលិកនៃមន្ទីរស-២១ ដែលគេចាប់ខ្លួន ត្រូវបានសួរចម្លើយដូចបុគ្គលដទៃទៀតដែរឬទេ?

**ឆ៖** បាទ, ខ្ញុំសូមជម្រាបថា បុគ្គលិកដែលនៅស-២១ហ្នឹង ក៏គេសួរដូចអ្នកដទៃទៀតទាំងអស់ដូចគ្នា ហើយនិងយកទៅសម្លាប់ចោល នៅក្បែរគុកហ្នឹងទាំងអស់ដូចគ្នាអ៊ីចឹង ។

**ស៖** ឥឡូវត្រឡប់ទៅព្រៃសវិញ តើបុគ្គលិកនៃមន្ទីរអប់រំកែប្រែព្រៃស មានករណីដែលចាប់ខ្លួនហើយបញ្ជូនត្រង់ទៅសម្លាប់នៅជើងឯកដែរឬទេ?

[១៤:១៩:៤៤]

**ឆ៖** បាទ, ខ្ញុំសូមជម្រាបថា ខ្ញុំអត់សូវបានដឹងពីចាប់មកពីព្រៃស យកមកសម្លាប់ចោលនៅជើងឯកទេ បើចាប់យកមកគឺគេយកមកដាក់គុកហើយ បានគេសួរចម្លើយ ហើយបានយកទៅសម្លាប់ចោល ។

**ស៖** លោកបាននិយាយកាលពីព្រឹកមិញមានការពាក់ព័ន្ធទៅនឹងទីកន្លែងមួយគឺផ្ទះ លន់ ណុន នៅបាគូ ឬអ្នកខ្លះហៅថា ស្លាគូ ដោយទីកន្លែងនោះគឺជាទីកន្លែងប្រតិបត្តិការចាប់ខ្លួន នុន ហ៊ុយ ហៅ ហ៊ុយ ស្រែ ដែលជាប្រធានមើលការខុសត្រូវ-- ជាសមាជិកនៃគណៈកម្មាធិការស-២១ ហើយជាទទួលបន្ទុកមើលការខុសត្រូវនៅមន្ទីរអប់រំកែប្រែសាជាថ្មីព្រៃស ។ តើលោកដឹងទេអំពីហេតុការណ៍នៃទីនោះថា កន្លែងស្លាគូនោះ គេប្រើប្រាស់ចម្បងគេធ្វើអ្វីទៅកន្លែងស្លាគូនោះ?

**ឆ៖** បាទ, ខ្ញុំសូមជម្រាបលោក កន្លែងស្លាគូហ្នឹងមិនមែនកន្លែងចាប់អ្នកទោសចាប់អីទេ ។ កន្លែងហ្នឹងគឺពួកខ្ញុំធ្វើស្រូវហើយផ្ទះហ្នឹងក៏ពួកខ្ញុំអត់នៅដែរ ពួកខ្ញុំនៅអាភូមិអីខាងកើតផ្ទះលោក លន់ ណុន ហ្នឹង ហើយទៅធ្វើស្រែទៅធ្វើអីទៅធ្វើដល់ហ្នឹង ។

**ស៖** ចុះមានទីកន្លែងណាដែលមានកងនៃក្រុមអ្នកទោសដែលធ្វើការងារនៅចំណុះឲ្យព្រៃសរស់នៅ ហើយមានកុមារជាច្រើនដែលនៅទីនោះ ។ មានទេៗកន្លែងកងណាដែលគេទទួលបន្ទុកមើលកុមារទេ នៅក្បែរៗម្ដុំយើងស្លាគូនោះ?

**ឆ៖** ខ្ញុំសូមជម្រាបថា នៅកន្លែងស្លាគូអត់មានទេ មានៗនៅឯព្រៃសនោះ ។ ព្រោះកន្លែងនោះកាលដែលខ្ញុំដឹងគឺកាល បងហ៊ុយ នៅគឺមានបងហ៊ុយ និងផល ដែលទៅជួយធ្វើការងារគ្នាហ្នឹងទាំងពីរនាក់នៅហ្នឹង ។ ក្រោយគេឈប់ឲ្យ បងផល នៅភ្នំពេញនេះឲ្យទៅនៅជាមួយ បងហ៊ុយ ។

**ស៖** លោកមានដឹងរឿងហេតុការណ៍មួយនៃការប្រមូលកុមារនៅព្រៃស នៅអង្គភាពមួយចំណុះឲ្យកន្លែងមន្ទីរអប់រំកែប្រែព្រៃសយកមកសម្លាប់នៅបឹងជើងឯកដែរទេ ពួកកុមារៗ?

**ឆ៖** ខ្ញុំសូមជម្រាបថា ខ្ញុំអត់បានដឹងទេ ។

**ស៖** ឥឡូវត្រឡប់ចូលមកក្រោយវិញ ទីមួយលោកអាចដឹងទេនៅក្នុងការបែងចែកក្រុមប្រតិបត្តិការដែលលោកប្រើថាកង តើកងឈ្មោះ ក្រុមឈ្មោះ ប៉េង? អំមិញដែលលោកនិយាយញឹកញាប់ថា ឈ្មោះប៉េង គាត់មានឋានៈអីទៅ? ហើយគាត់ទទួលបន្ទុកផ្នែកខាងណាដែរឈ្មោះប៉េងហ្នឹង?

[១៤:២៣:៤០]

**ឆ៖** ខ្ញុំសូមជម្រាបលោកឈ្មោះប៉េង គឺប្រធានរួមទាំងអស់ផ្នែកកងការពារនៅសន្តិសុខគុកនោះទាំងមូល ហើយនិងឈ្មោះ ផល ក៏ប្រធានសន្តិសុខនៅកន្លែងហ្នឹងដែរ បន្ទាប់មកគឺ ស្រ៊ី សមាជិក ។ ហើយខ្ញុំឲ្យឡើងជាអនុកងរយបណ្ដោះអាសន្នទទួលនូវខាងផ្នែកចាំទទួលអ្នកទោសនៅខាងក្រៅហ្នឹង ។

**ស៖** ក្នុងកងការពារហ្នឹង គេបែងចែកកម្លាំងប៉ុន្មានអង្គភាពដែរកងការពារ? ចែកជាប៉ុន្មានកង? កងរយ?

**ឆ៖** ខ្ញុំសូមជម្រាបមុន ផ្នែកកងការពារគឺ មួយផ្នែកគេហៅថាកងនីរសារ១នោះ ហ្នឹងមួយអង្គភាពទៅ ហើយផ្នែកការពារនោះមួយអង្គភាព ដល់ពេលសម្លាប់អស់គ្នាទៅនៅសល់គ្នាតិចបានរួមទាំងអស់នៅតែមួយកងការពារហ្នឹង ។

**ស៖** អ៊ីចឹង ចុងក្រោយត្រូវគេសម្លាប់អស់ទៅនៅសល់តែមួយកងការពារទេ និយាយរួមទាំងការពារទាំងខាងក្នុងទាំងខាងក្រៅគឺនៅតែមួយកងទេ អ៊ីចឹងមែនទេ?

**ឆ៖** ខ្ញុំសូមជម្រាបថា គឺចាប់ទាំងកងការពារ ទាំងនីរសារ ដែលកងគេហៅថាកងនីរសារក៏ចាប់អ្នកដាំបាយដាំអីក៏ចាប់ អ្នកខាងអី១ក៏ចាប់ដល់យូរទៅនៅសល់តែមួយកង១ការពារ បញ្ចូលគ្នាទាំងអស់តែម្ដង ។

**ស៖** ចុះក្រុមខាងអ្នកសួរចម្លើយ មានត្រូវដែលចាប់ខ្លួនដែរទេ?

**ឆ៖** ខ្ញុំសូមជម្រាប! ទាំងកងការពារ ទាំងសួរចម្លើយ ទាំងអីទាំងអស់រួមគឺចាប់ទាំងអស់គ្នាតែម្ដង ។

**ស៖** រឿងហេតុផ្សេងទៀត ដូចជាខាងផ្នែកពេទ្យ តើលោកបានស្គាល់ទេផ្នែកពេទ្យនៅអង្គភាព ស-២១ ហ្នឹងមានផ្នែកពេទ្យ ឬក៏ក្រុមពេទ្យដែរទេ? ហើយបើមានមានគ្នាប៉ុន្មាននាក់? ហើយប្រធានក្រុមឈ្មោះអ្វី? ហើយជោគវាសនារបស់គេយ៉ាងម៉េចដែរ?

**ឆ៖** ខ្ញុំសូមជម្រាបទាំងកងការពារ ទាំងសួរចម្លើយ ទាំងសេដ្ឋកិច្ច អ្នកដាំបាយដាំអី ទាំងពេទ្យគឺជោគវាសនារបស់ពេទ្យនិងពួកទាំងអស់គ្នាហ្នឹងគឺសុទ្ធតែបានចាប់ខ្លួនទាំងអស់ ។ កាលមុនពេទ្យគ្នាច្រើនដល់យូរសល់ពេទ្យប៉ុន្មាននាក់ ។

**ស៖** លោកស្គាល់ទេ? ស្គាល់ពេទ្យដែលគេធ្វើប្រធានហើយគេចាប់ខ្លួននោះ? ឈ្មោះអីទៅ?

**ឆ៖** ខ្ញុំសូមជម្រាប ខ្ញុំនៅចាំឈ្មោះបានគឺពេទ្យ រិន គឺបានចាប់ខ្លួន ។ ហើយគាត់ជាមេក្រុមពេទ្យនៅកន្លែងទួលស្លែងអ្នកមើលជំងឺទូទៅទាំងអ្នកទោស ទាំងអ្នកធ្វើការនៅកន្លែងហ្នឹង ។

[១៤:២៨:១៥]

**ស៖** មានពេទ្យឈ្មោះ ទ្រី ទេនៅទីនោះ?

**ឆ៖** បាទៗ បងទ្រី គឺគាត់រត់ទៅជាមួយទាំងអស់គ្នាទៅព្រៃហ្នឹងក៏គាត់មិនដឹងជាស្លាប់រស់ទេ ។

**ស៖** បុគ្គលិកពេទ្យនៅទីនោះមានបុរសប៉ុន្មាន? ស្ត្រីប៉ុន្មាននាក់ដែរ?

**ឆ៖** តាមខ្ញុំដឹងគឺសុទ្ធតែពេទ្យប្រុសៗទាំងអស់ មានគ្នាប្រហែលជាប្រាំមួយប្រាំពីរនាក់ពេទ្យហ្នឹង ទាំងពេទ្យបង្កើតថ្មីទៀត ។

**ស៖** កន្លែងធ្វើការរបស់ពេទ្យហ្នឹង គេមាននៅកន្លែងណានៃមន្ទីរស-២១? ក្រុមពេទ្យគេមានការិយាល័យធ្វើការនៅកន្លែងណា?

**ឆ៖** ខ្ញុំអត់បានចាំដែរ មិនដឹងជាគាត់នៅកន្លែងជាមួយ បងធី ហ្នឹង ឬមួយក៏គាត់នៅផ្ទះខាងក្រៅនេះក៏មិនដឹង នៅចំមុខគុកហ្នឹងក៏មិនដឹង ។

**ស៖** ឥឡូវត្រឡប់មកវិញ លោកបាននិយាយច្រើនហើយ សំណួរសួរថា កាលដែលសម្រេចយកអ្នកទោសបញ្ចេញពីគុក ឬក៏បញ្ចេញពីកន្លែងឃុំឃាំងយកទៅសម្លាប់ ដែលលោកបានរៀបរាប់ប្រាប់ដល់អង្គសវនាការរួចហើយនោះ សួរថា តើអ្នកណាជាបញ្ជាឲ្យយកអ្នកទោសនោះចេញពីអគារឃុំខ្លួនយកទៅសម្លាប់? ហើយការបញ្ជាហ្នឹងបញ្ជាដោយផ្ទាល់មាត់ ឬក៏បញ្ជាមានលាយលក្ខណ៍អក្សរ?

**ឆ៖** ខ្ញុំអត់បានដឹងដែរ ព្រោះខ្ញុំដឹងតាមរយៈ តាហ៊ី តាមរយៈបង សួស ធីហ្នឹង តាមច្បាស់ជាងគេគឺតាម តាហ៊ី មិនដឹងអ្នកណាអ្នកសម្រេច ប៉ុន្តែតាមខ្ញុំដឹងគឺសម្រេចពី តាឌុច មកបាន តាហ៊ី ប៊ានសម្រេច ហើយនិង បងធី ប៊ានដើរប្រមូលឈ្មោះតាមគុកហ្នឹង ។

**ស៖** កម្លាំងនៅក្នុងមន្ទីរសន្តិសុខស-២១ សរុបដែលលោកបានដឹងទាំងអស់ហ្នឹងចេញមកប្រភពណា? ដែលបង្កើតបានជាអង្គភាពមន្ទីរស-២១ ឡើង កម្លាំងនៃបុគ្គលិកកម្មាភិបាលទាំងអស់ហ្នឹងមកពីប្រភពណាខ្លះ?

**ឆ៖** តាមខ្ញុំដឹងគឺចេញមកពីខាង៧០៣ ហើយនិងតាមបស្ចិម ខាងកំពង់ឆ្នាំង ។

**ស៖** មកកម្លាំងប្រហាក់ប្រហែលគ្នា ឬក៏កម្លាំងខាងណាច្រើនជាងខាងណា? ខាងបស្ចិមច្រើនទេ?

**ឆ៖** ខាងបស្ចិមតាមខ្ញុំចំណាំមើលគឺប្រហែលជាពីរក្រុម ហើយខាង៧០៣ គឺច្រើនៗជាងគេ ៧០៣ ។ គ្រាន់៧០៣ ចូលជិតមួយកងរយ ។

**ស៖** មួយកងរយនោះ សរុបមកប៉ុន្មាននាក់មួយកងរយ?

**ឆ៖** ខ្ញុំសូមជម្រាបមួយកងរយគឺគ្នាចូលជិតបីរយនាក់ ។

**ស៖** ចុះមុខសញ្ញាដែលត្រូវចាប់ខ្លួន មនុស្សដែលត្រូវចាប់ខ្លួនជាបុគ្គលិកនៃមន្ទីរស-២១ ទាំងព្រៃស ផង ជាកម្លាំងខាងណាដែរ? កម្លាំងមកពី៧០៣ ឬក៏មានកម្លាំងមកខាងបស្ចិមដែរ? ចម្រុះគ្នា?

**ឆ៖** ខ្ញុំសូមជម្រាបថា ខ្ញុំអត់ដឹងទេដែលកម្លាំងណាយកមកចាប់ ។ វាចេះតែឃើញបាត់គ្នា បាត់គ្នាតែរហូតអ៊ីចឹង ។

**ស៖** ខ្ញុំមិនសួរអ៊ីចឹងទេ ខ្ញុំសួរថាបុគ្គលិកមន្ទីរស-២១ សរុបមានកម្លាំងពីប្រភពពីរបង្កើតបានជាកម្លាំងនៅក្នុងមន្ទីរស-២១ គឺមាន៧០៣ ហើយនិងកម្លាំងខាងបស្ចិម យកពីខាងកំពង់ឆ្នាំងមក ។ សំណួរសួរថា កម្លាំងទាំងអស់ហ្នឹងដែលត្រូវចាប់ខ្លួនយកទៅសម្លាប់នោះ ភាគច្រើនកម្លាំងមកពី៧០៣ ឬក៏កម្លាំងមកទាំងសងខាង បស្ចិមក៏គេចាប់ ហើយខាង៧០៣ក៏គេចាប់ដាក់គុកហើយសួរចម្លើយ សម្លាប់ដែរ? យល់សំណួរទេ?

**ឆ៖** ខ្ញុំសូមជម្រាបកម្លាំងដែលយកទៅសម្លាប់ច្រើនជាងគេគឺ៧០៣ ។ បស្ចិមដូចមិនទាន់ឃើញមួយទេដែលយកទៅសម្លាប់ ។

**ស៖** និយាយពីវគ្គរៀនសូត្រផ្សេងៗ តើលោកដែលបានចូលរៀននៅក្នុងវគ្គនយោបាយ ឬក៏វគ្គបណ្តុះបណ្តាលផ្សេងៗទេ ហើយបើបានរៀនៗនៅទីណាដែរក្នុងអំឡុងពេលដែលលោកធ្វើជាបុគ្គលិកនៃមន្ទីរស-២១?

**ឆ៖** ខ្ញុំសូមជម្រាប ការរៀនសូត្រគឺប្រហែលជាកន្លះខែ មួយខែអីហ្នឹងគាត់ហៅទៅរៀនសូត្រកន្លែងរៀនសូត្រ គឺនៅក្បែរគាត់ខាងកើតលូទឹកស្អុយហ្នឹងដែលជិតផ្ទះ តាឌុច ហ្នឹង គាត់ប្រមូលកម្លាំងពីស្រែមក ពីព្រៃសមក ហើយនិងកម្លាំងដែលនៅការពារគុកស-២១ ហ្នឹងទៅរៀនសូត្រនៅកន្លែងសាលារបស់គាត់មួយដែលគាត់រៀបចំជាសាលានយោបាយរបស់គាត់ ។

**ស៖** ខ្លឹមសារដែលលោកធ្លាប់បានឆ្លងកាត់វគ្គរៀនសូត្រកាលពីសម័យនោះ នៅក្នុងអំឡុងពេលដែលលោកធ្វើជាបុគ្គលិកមន្ទីរស-២១ នោះ រៀនសូត្រឯកសារអីខ្លះទៅ? ឬក៏បច្ចេកទេសអីខ្លះទៅ?

**ឆ៖** ខ្ញុំសូមជម្រាប រៀនសូត្រដែលគាត់បានហៅពួកខ្ញុំរៀនសូត្រនេះពីឯកសារមួយរឿង នយោបាយ វណ្ណៈអធនរបស់គាត់ របស់អង្គការហ្នឹងឲ្យយកចិត្តទុកដាក់ គោរពអង្គការវិន័យឲ្យទៅជាវណ្ណៈអធនរបស់អង្គការ ហើយឲ្យដាច់ខាតចំពោះខ្មាំង អ្នកណាដើរតាមកង់ប្រវត្តិសាស្ត្រទាន់មិនទាន់ ដើរទាន់

មិនអីទេ បើដើរមិនទាន់គឺ កង់ប្រវត្តិសាស្ត្រនឹងកម្ទេចចោល ។ ហើយឲ្យការពារខ្មាំងឲ្យជាប់កុំឲ្យ ខ្មាំងរត់រួច សួរចម្លើយខ្មាំងឲ្យច្បាស់ ហើយសួរចម្លើយខ្មាំងធ្វើម៉េចយកតែឲ្យខាងបាន ។

**ស៖** ចុះលោកដែលបានរៀនសូត្រពីគាត់អំពីបច្ចេកទេសនៅក្នុងការសួរចម្លើយ ឬក៏បច្ចេកទេសក្នុងការប្រើប្រព្រឹត្តអំពើដោយហិង្សាផ្សេងៗទៅលើជនរងគ្រោះ ឬទៅលើអ្នកដែលត្រូវចាប់ខ្លួនដែរឬទេ?

**ឆ៖** ខ្ញុំសូមជម្រាបថា ការរៀនសូត្រអំពីបច្ចេកទេសសួរចម្លើយសួរអីគឺខ្ញុំអត់ចេះសួរទេ ហើយក៏ខ្ញុំអត់បានរៀនជាមួយដែរ ។ ហើយការអប់រំខ្ញុំឲ្យធ្វើសកម្មភាពឲ្យធ្វើបាបអ្នកទោសអ្នកអីក៏អត់បានធ្វើដែរ ។

**ស៖** ចុះអំមិញគឺពីរដង យើងស្តាប់លោកនិយាយច្បាស់លាស់គឺពីរដង កាលពីព្រឹកនៃការសម្លាប់ដែលរណ្តៅរួមនៅខាងលិចគុកទួលស្លែងបច្ចុប្បន្ននេះគឺការសម្លាប់នោះដោយវាយនឹងដំបង ហើយបន្ទាប់មកគឺអារ-ក ហើយរួចបានដោះខ្នោះដៃចេញ ហើយមានការដោះសម្លៀកបំពាក់ចេញរួចបានរុញចូលរណ្តៅ ។ ហើយក្រោយមកគឺលោកបាននិយាយ លោកបានដឹងរឿងដូចគ្នានេះដែរ នៅអនុវត្តនៅបឹងជើងឯក ។ របៀបសម្លាប់ ឬក៏វិធីសម្លាប់ដែលដោយការវាយរួចហើយ អារ-កថែមនឹង តើលោកដឹងទេ តើបច្ចេកទេសហ្នឹងបានពីណាមក អ្នកណាជាអ្នកបង្រៀន? ឬក៏បុគ្គលិកនៅមន្ទីរហ្នឹងយល់ដោយខ្លួនឯងហើយអនុវត្តដោយឯងៗអ៊ីចឹងទៅ? ឬក៏មានការរៀនសូត្រ ឬក៏ការណែនាំពីអ្នកណាដែរ?

**ឆ៖** បើតាមខ្ញុំដឹងគឺការរៀនសូត្រដែលពេលសម្លាប់ហ្នឹងគឺរៀនសូត្រពី តាហ៊ី ។ តាហ៊ី ជាអ្នកបង្រៀនទាំងអស់ ។ មុននឹងសម្លាប់ គឺឲ្យវ៉ៃកញ្ជឹងកទៅ ដួលចាំយើងអារ-ក, អារ-កហើយដោះសម្លៀកបំពាក់ ហើយដោះខ្នោះដៃចាំលើកបោះទៅក្នុងរណ្តៅ ។ គឺរៀងរាល់ពេលដែលគាត់បានបង្រៀនពួកអ្នកធ្វើហ្នឹង ។

[១៤:៣៩:១០]

**ស៖** លោកដែលឃើញជនជាប់ចោទផ្ទាល់ គឺជនជាប់ចោទឈ្មោះ ឌុច ហ្នឹងគាត់ដែលបានប្រព្រឹត្តអំពើហិង្សាវាយទៅលើអ្នកដែលត្រូវចាប់ខ្លួនដែរឬទេ? លោកដែលឃើញទេ? ខ្លួនគាត់ផ្ទាល់ដែលបាន ប្រព្រឹត្តហិង្សាទៅលើអ្នកដែលត្រូវបានចាប់ខ្លួនបញ្ជូនទៅស-២១ ដែរឬទេ?

**ឆ៖** ខ្ញុំសូមជម្រាបថា ខ្ញុំអត់បានឃើញគាត់ពេលចាប់អ្នកទោសចូលទៅគាត់វ៉ៃនោះខ្ញុំអត់បានឃើញទេ ។

**ស៖** លោកដែលដឹងថា តើគាត់ដែលសួរចម្លើយអ្នកដែលត្រូវបានចាប់ខ្លួនបញ្ជូនទៅឃុំឃាំងនៅ ស-២១ ដោយផ្ទាល់ខ្លួនឯងដែរទេ? ហើយបើដឹង តើគាត់សួរចម្លើយប៉ុន្មាននាក់ហើយអ្នកណាខ្លះ?

**ឆ៖** ខ្ញុំសូមជម្រាប! ចំពោះ តាឌុច កាលដែលគាត់សួរចម្លើយអ្នកទោសអីហ្នឹងក៏ខ្ញុំអត់បានដឹងដែរព្រោះការងារនេះមិនមែនជាការងាររបស់ខ្ញុំដែលខ្ញុំត្រូវដឹងពីការសួរចម្លើយនោះទេ គឺការងារខ្ញុំនៅខាងក្រៅឯណោះ ។

**ស៖** ក្នុងអំឡុងពេលដែលលោកអះអាងថា លោកបានចូលជួយតាមការចាត់តាំងរបស់ថ្នាក់លើជួយមើលការខុសត្រូវនូវកងការពារនៅក្នុងអគារឃុំខ្លួន ។ តើលោកដែលបានឃើញវត្តមាននៃជនជាប់ចោទឈ្មោះ ឌុច ហ្នឹងនៅតាមអគារនៃកន្លែងឃុំឃាំងឃុំខ្លួនអ្នកទោសនោះដែរឬទេ? ហើយបើឃើញ ឃើញញឹកញាប់ប៉ុនណាដែរ?

**ឆ៖** បើតាមខ្ញុំឃើញ គឺឃើញគាត់ទៅកន្លែងតាៗ ដែលគាត់គូរគំនូរនោះខ្ញុំឃើញទៅ ។ ពេលដែលខ្ញុំបញ្ជូនអ្នកទោសយកចូលទៅឲ្យបង សួស ធី ឃើញគាត់ចូលទៅមើលតាៗដែលជាជនរងគ្រោះហ្នឹងគូរគំនូរហ្នឹងគាត់ចូលទៅហ្នឹង ។

**ស៖** អ៊ីចឹងបានន័យថា លោកឃើញគាត់ទៅត្រឹមតែកន្លែងដែលអ្នកទោសតាៗ ដែលគាត់ឲ្យគូរគំនូរទេ ត្រង់ថា គាត់ទៅតាមអគារឃុំឃាំងអ្នកទោសគឺលោកមិនដែលឃើញទេ អ៊ីចឹងមែនទេ?

**ឆ៖** បាទ ។

[១៤:៤១:៥៧]

**ស៖** គាត់ទៅទីនោះដើម្បីធ្វើអ្វីដែរ តាមដែលលោកឃើញ?

**ឆ៖** តាមខ្ញុំឃើញ គឺគាត់ទៅមើលរូបដែលគាត់ឲ្យតាៗឆ្លាក់រូប ប៉ុល ពត ហ្នឹង ធ្វើយ៉ាងម៉េចឲ្យដូច ធ្វើយ៉ាងម៉េចឲ្យស្អាត អាហ្នឹងឃើញគាត់ទៅប្រាប់អ៊ីចឹងមែន ។

**ស៖** តើលោកដែលឃើញជនជាប់ចោទឈ្មោះ ឌុច ហ្នឹងទៅដល់បឹងជើងឯកដែរឬទេ? ហើយបើឃើញ ឃើញទៅប៉ុន្មានលើក? ហើយគាត់ទៅធ្វើអ្វីដែរ?

**ឆ៖** ខ្ញុំសូមជម្រាបថា តាមខ្ញុំឃើញគាត់គឺគាត់ទៅពីរដង ។

**ស៖** គាត់ទៅធ្វើអី? ហើយទៅរយៈពេលយូរដែរទេ? ឬក៏ទៅឆាប់ត្រឡប់មកវិញទេ?

**ឆ៖** គាត់ទៅទាល់តែគេសម្លាប់អ្នកទោសហើយ បានគាត់មក ។

**ប្រធានអង្គជំនុំ៖**

ឥឡូវនេះ ដល់ម៉ោងឈប់សម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាកដប់ប្រាំបួននាទី គឺឈប់សម្រាកពីពេលនេះទៅរហូតដល់ម៉ោងបី ចាប់ផ្ដើមបន្តកិច្ចស្ដាប់សក្ខីកម្មសាក្សីរូបនេះទៀត ។

មន្ត្រីតុលាការសម្របសម្រួលរកកន្លែងឲ្យសាក្សីបានសម្រាកបានសមរម្យ ហើយឲ្យនាំគាត់មកវិញឲ្យបានមុនម៉ោងបី ។

*[សវនាការសម្រាកពីម៉ោង ១៤:៤៤នាទី ដល់ម៉ោង ១៥:០៣នាទី]*

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយចុះ ។

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីស្ដាប់សក្ខីកម្មសាក្សីឈ្មោះ ហ៊ឹម ហ៊ុយ ។ មុននឹងបន្តនីតិវិធីស្ដាប់សក្ខីកម្មសាក្សីរូបនេះ អង្គជំនុំជម្រះធ្វើការប្រកាសនូវសេចក្ដីសម្រេចលើសំណើសុំវិធានការការពារសម្រាប់សាក្សី KW-10 ដូចខាងក្រោមនេះ៖

នៅថ្ងៃទី៣ ខែមេសា ឆ្នាំ២០០៩ អង្គជំនុំជម្រះបានចេញសេចក្ដីសម្រេចស្ដីពីវិធានការការពារសាក្សី និងអ្នកជំនាញ ដែលមានឯកសារ E40 ដែលនៅក្នុងសេចក្ដីសម្រេចនោះ មិនទាន់បានសម្រេចទៅលើសំណើសុំវិធានការការពារដែលបានស្នើឡើងដោយសាក្សី KW-10នៅឡើយ ។ ពេលនេះអង្គជំនុំជម្រះសូមជម្រាបជូនដំណឹងដល់ភាគីនានា ចំពោះសេចក្ដីសម្រេចរបស់ខ្លួនលើសំណើនេះ អង្គជំនុំជម្រះ បានពិនិត្យឡើងវិញលើសំណើនៃការវាយតម្លៃហានិភ័យ ដែលការវាយតម្លៃនេះត្រូវបានចាត់ថ្នាក់ថាសម្ងាត់បំផុត ដែលបានរៀបចំធ្វើឡើងដោយអង្គភាពគាំពារសាក្សី និងអ្នកជំនាញទៅលើសាក្សី KW-10 ក្នុងការវាយតម្លៃអំពីហានិភ័យ អង្គភាពគាំពារសាក្សីនិងអ្នកជំនាញ បានកត់សម្គាល់ថា សាក្សីរូបនេះត្រូវបានគេស្គាល់ជាសាធារណៈតាមរយៈសារព័ត៌មានជាច្រើនថា គាត់មានតួនាទីជាអ្នកសួរចម្លើយនៅមន្ទីរស-២១ ។

ដូច្នេះ គាត់ត្រូវបានគេស្គាល់ជាសាធារណៈរួចហើយ អត្តសញ្ញាណរបស់គាត់ត្រូវបានគេស្គាល់រួចហើយ បើទោះបីជាវិធានការការពារដូចជាការធ្វើសវនាការជាអសាធារណៈ ត្រូវបានយកមកប្រើប្រាស់ក៏ដោយ ដោយមូលហេតុនេះអង្គភាពគាំពារសាក្សី និងអ្នកជំនាញមិនស្នើឲ្យមានវិធានការការពារ

សម្រាប់សាក្សីរូបនេះទេ ។ អង្គជំនុំជម្រះកត់សម្គាល់ឃើញថា សាក្សីKW-10 បានធ្វើឲ្យមានការស្គាល់អត្តសញ្ញាណរបស់គាត់ជាទូទៅ គាត់គឺជាមនុស្សដែលត្រូវបានគេស្គាល់ច្បាស់ពីតួនាទីដែលនាំឲ្យវិធានការការពារមិនមានប្រសិទ្ធភាព ប្រសិនបើត្រូវបានផ្តល់ឲ្យនោះ ។ បន្ថែមលើនេះទៀត គ្រួសារ និងសាច់ញាតិរបស់គាត់ក៏ដូចជាអ្នកជិតខាងរបស់គាត់ បានដឹងពីប្រវត្តិនិងតួនាទីរបស់គាត់ដូចបានបញ្ជាក់ខាងលើស្ទើរគ្រប់ៗគ្នា ។ អង្គជំនុំជម្រះសាលាដំបូងយល់ស្របទៅនឹងការស្នើឡើងដោយអង្គភាពគាំពារសាក្សី និងអ្នកជំនាញ ដែលថាវិធានការការពារមិនគួរផ្តល់ជូនសាក្សីរូបនេះ ។

ហេតុដូច្នេះ សម្រេច អង្គជំនុំជម្រះសាលាដំបូងបដិសេធសំណើសុំវិធានការការពារសម្រាប់សាក្សី KW-10 ។ សេចក្តីសម្រេចទាក់ទងនឹងវិធានការការពារសាក្សី និងដើមបណ្តឹងរដ្ឋប្បវេណីដែលនៅសេសសល់ អង្គជំនុំជម្រះនឹងសម្រេច នឹងប្រកាសក្នុងពេលសមស្របខាងមុខ ។

យើងបន្តនីតិវិធីនៃការស្តាប់សក្ខីកម្មសាក្សី ហ៊ឹម ហ៊ុយ តទៅទៀត ។

[១៥:០៦:៥២]

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** អម្បាញ់មិញនេះមុននឹង សម្រាកលោកបានឆ្លើយនឹងសំណួររបស់ខ្ញុំ អំពីវត្តមានរបស់ជនជាប់ចោទ នៅជើងឯក វាលពិឃាត ជើងឯកពីរដង ហើយលោកបាននិយាយថា គាត់មានវត្តមាននៅទីនោះរហូតដល់ពេលប្រតិបត្តិការនៃចាប់ សម្លាប់មនុស្សបានចប់ ទើបត្រឡប់មកវិញ ។ សំណួរសួរថា តើលោកដឹងទេថា គាត់មានវត្តមានពីរដងហ្នឹងនៅក្នុងអំឡុងប្រហែលជាក្នុងឆ្នាំណាដែរ?

**ឆ៖** បាទ, ខ្ញុំសូមជម្រាប គឺនៅក្នុងឆ្នាំ៧៧ ។

**ស៖** គាត់ទៅលើកទីមួយ ហើយនិងទៅលើកទីពីរ មានការឃ្លាត ពេលវេលាឃ្លាតគ្នាប្រហែលជាប៉ុន្មានថ្ងៃ ប៉ុន្មានខែដែរ?

**ឆ៖** បាទ, មានពេលឃ្លាតគ្នា មិនទៅជួនគ្នាទេ ។

**ស៖** ឃ្លាតគ្នាពីការគាត់ទៅលើកទីមួយ និងទៅលើកទីពីរហ្នឹង ប្រហែលជាប៉ុន្មាន រយៈពេលប៉ុន្មានខែ ប៉ុន្មានថ្ងៃ ប៉ុន្មានខែដែរ?

**ឆ៖** បាទ, ខ្ញុំវាភ្លេចចាំដែរ ប៉ុន្តែតាមខ្ញុំយល់មើលគឺថាប្រហែលជាកន្លះហើយបានគាត់ទៅទៀត។

**ស៖** លោកគិតបន្តិចមើលថា តើវត្តមានដែលគាត់ទៅដល់បឹងជើងឯកហ្នឹង មុនពេល ឬក្រោយពេលនៃព្រឹត្តិការណ៍មួយកើតឡើង ដែលមានអ្នកទោសម្នាក់រួចៗពីការសម្លាប់ ដែលទាំងជាប់ដៃជាប់

ចំណងត្រូវបានចាប់ដោយកងពល៧០៣ តើគាត់ទៅហ្នឹងមុនពេលកើតហេតុហ្នឹង ឬក៏ក្រោយពេលព្រឹត្តិហេតុនៃការមនុស្សដែលរត់រួចម្នាក់ហ្នឹង?

**ឆ៖** បាទ, ដំបូង គឺគាត់ទៅមុនពេលកើតហេតុដែលអ្នកទោសរត់រួចហ្នឹង ។

**ស៖** ចុះគាត់ទៅលើកក្រោយ?

**ឆ៖** បាទ, លើកក្រោយ គឺទៅក្រោយពីដែលអ្នកទោសរួចហ្នឹងទៅទៀត ។

[១៥:០៩:៤១]

**ស៖** លោករកនឹកឡើងវិញមើលថា អំឡុងពេលដែលគាត់ទៅហ្នឹង តើគាត់ទៅនៅកន្លែងណា? កន្លែងផ្ទះដែលសម្រាប់ស្តុកអ្នកទោស ឬក៏កន្លែងសម្រាប់ពួកធ្វើការនៅទីនោះគេស្នាក់នៅ ហើយខាងក្រោមហ្នឹងដាក់អ្នកទោសបណ្តោះអាសន្នសិន ហើយមុននឹងនាំចេញទៅសម្លាប់ ឬក៏គាត់មានវត្តមាននៅរណ្តៅនៃ ជិតរណ្តៅនៃការសម្លាប់មនុស្សដែរ?

**ឆ៖** បាទ, ពេលដែលគាត់ទៅហ្នឹង ដំបូងគឺគាត់នៅកន្លែងឡានគាត់ នៅអាខាងជើងៗវិមានសាកសពហ្នឹង ។ គាត់នៅកន្លែងហ្នឹង ហើយ តាហ៊ី គាត់ទៅកន្លែងផ្ទះដែលដាក់អ្នកទោសនោះ ។

**ស៖** នៅកន្លែងវិមានសាកសពហ្នឹង លោកចង់និយាយថា មានវិមានសាកសពដែរ ឬក៏លោកប្រៀបធៀបទេ ថាអង្កាល់ដែលគាត់ទៅហ្នឹង គឺបើធៀបជាមួយនឹងកន្លែងដាក់វិមានដាក់សាកសព សព្វថ្ងៃនេះ គឺគាត់ទៅនៅម្តុំហ្នឹង ឬក៏វិមានហ្នឹងមានតាំងពីជំនាន់នុ៎ងម្ល៉េះ?

**ឆ៖** បាទ, កន្លែងគោលដៅមុន គឺនៅខាងជើងវិមានហ្នឹង វិមានទើបតែកសាងឥឡូវទេ ។ ឡានគាត់នៅកន្លែងហ្នឹង គឺខ្ញុំចាំ ។

**ស៖** គាត់ចូលដល់ទៅផ្ទះនុ៎ងទេ ដល់ទៅផ្ទះកន្លែងដែលគេទុកដាក់មនុស្សបង្អង់ទុកសិន ស្តុកទុកមួយរយៈសិន ហើយមុននឹងបញ្ជូនចេញទៅសម្លាប់ហ្នឹងទេ ឬក៏នៅឆ្ងាយពីទីនោះ?

**ឆ៖** បាទ, ខ្ញុំសូមជម្រាបថា ខ្ញុំមិនបានទៅគន់មើលឃើញរូបគាត់ និង តាហ៊ី ទេព្រោះមនុស្សយកទៅច្រើនណាស់ ។ គាត់ តាហ៊ី បញ្ជាឲ្យរូតរះហ្នឹងទៅព្រោះខ្លាចភ្លឺ ។ អ៊ីចឹងពួកខ្ញុំគិតតែការរូតរះអ្នកទោសដែលឲ្យគេយកទៅចេញទៅសម្លាប់ហ្នឹង ។

**ស៖** លោកមានឃើញមានវត្តមានជនជាប់ចោទហ្នឹង នៅកន្លែងក្បែរនឹងកន្លែងដែលគេពិឃាដមនុស្សដែរឬទេ?

**ឆ៖** បាទ, ពេលហ្នឹង គឺអ្នកទោសច្រើនណាស់ មួយយប់ចង់ទល់ភ្លឺ គឺខ្ញុំក៏មិនបានចាប់អារម្មណ៍ថា គាត់ឬមួយអ្នកណាដែរ ព្រោះក្រាលកន្ទេលនៅអង្គុយនៅមាត់រណ្ដៅហ្នឹង ។ កាលនោះ គឺមនុស្សវាច្រើនពេកហើយ ហើយគាត់ តាហ៊ី ហ្នឹង អ្នកបញ្ជាថា រូត១កុំឲ្យភ្លឺ តែភ្លឺបែកការណ៍រឿងឡានចេញទៅវិញហ្នឹង ព្រោះមនុស្សដល់មួយរយនាក់ឯណោះ ។

**ស៖** លោក ខ្លួនលោកផ្ទាល់បានចាកចេញពីមន្ទីរស-២១ មជ្ឈមណ្ឌលភ្នំពេញហ្នឹង នៅថ្ងៃខែឆ្នាំណាដែរ?

[១៥:១២:៤៦]

**ឆ៖** បាទ, ខ្ញុំចេញពីភ្នំពេញនេះ គឺចុង១ឆ្នាំ៧៨ ពាក់កណ្ដាលឆ្នាំ៧៨ ហ្នឹង ឲ្យខ្ញុំទៅធ្វើស្រែនៅខាងត្បូងជើងឯងហ្នឹង ទៅភ្នូរដី ភ្នូរអី ភ្នូរគោទេ ហើយលើកភ្លឺស្រែ ភ្លឺអីហ្នឹង ហើយរៀបចំកន្លែងដាក់ម៉ាស៊ីន ដាក់អីបូមទឹកសាបស្រូវស្ទូង ។ នៅខាងត្បូងហ្នឹងគេហៅ ភូមិអី ភូមិចេក ភូមិអីគេ។

**ស៖** នៅកន្លែងដែលលោកធ្វើស្រែហ្នឹងមានចម្ងាយប៉ុន្មានពីកន្លែងវាលពិឃាតជើងឯក? ហើយលោកទៅធ្វើការងារនៅនោះមានគ្នាប៉ុន្មាននាក់ដែរ?

**ឆ៖** បាទ, ខ្ញុំដំបូងទៅ គឺដកទៅពីរក្រុម ។ ពីរក្រុមទៅនៅធ្វើស្រែជាមួយខ្ញុំហ្នឹង ។

**ស៖** កន្លែងដែលលោកថា អះអាងថា ប្រហែលដូចជាភូមិចេក ហ្នឹងដែលកន្លែងលោកទៅធ្វើស្រែហ្នឹង មានចម្ងាយប៉ុន្មានពីបឹងជើងឯក ពីកន្លែងដែលចំណុចមានផ្ទះមួយសម្រាប់ពិឃាដមនុស្សនោះ?

**ឆ៖** បាទ, ខ្ញុំសូមជម្រាបវាជិតមួយគីឡូដីដែរ ។

**ស៖** លោកបានដឹងទេថា អ្នកដែលជាប់ឃុំឃាំង ចាប់ខ្លួនយកមកឃុំឃាំង យកសួរចម្លើយ ឬក៏មានប្រើអំពើហិង្សា រហូតដល់នាំទៅសម្លាប់ទាំងអស់ហ្នឹង តើលោកដែលឃើញមានសេចក្ដីសម្រេចសាលក្រមតុលាការអីដែរទេ ឬក៏មិនដែលឃើញមានឯកសារដែលជាសាលក្រម ឬសេចក្ដីសម្រេចរបស់តុលាការទេ?

**ឆ៖** បាទ, ខ្ញុំសូមជម្រាប កាលជំនាន់ខ្មែរក្រហមហ្នឹង អត់មានតុលាការអីទេ គឺដឹងតែគេបញ្ជូនយកទៅសម្លាប់១បណ្ដោយ ។

**ស៖** អ៊ីចឹងបានន័យថា លោកផ្ទាល់ហ្នឹង គឺមិនដែលឮគេនិយាយថាមានតុលាការ មានវត្តមានស្ថាប័ន ឬអង្គការតុលាការទេនៅក្នុងរបបនុំង អ៊ីចឹងមែនទេ?

**ឆ៖** បាទ, គឺអ៊ីចឹងមែន ។

[១៥:១៥:១៦]

**ស៖** ចាប់ពីពេលលោកចូលមកបម្រើការងារជាកងការពារនៅមន្ទីរសន្តិសុខស-២១ រហូតដល់ថ្ងៃជ័យជម្នះលើរបបកម្ពុជាប្រជាធិបតេយ្យថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ តើលោកដែលត្រូវបានអនុញ្ញាតឲ្យទៅលេងផ្ទះ ឬក៏ទៅសួរសុខទុក្ខឪពុកម្ដាយ ឬក៏ទៅធ្វើការងារផ្សេងៗចាកចេញពីអង្គភាពដែរឬទេ?

**ឆ៖** បាទ, ខ្ញុំសូមជម្រាប ដែលខ្ញុំនៅស-២១ នេះ គ្មានអ្នកណាឲ្យខ្ញុំទៅលេងផ្ទះទេ មានតែពេលមួយ គឺតាម៉ុន កាលមុនគាត់ឲ្យខ្ញុំជូនគាត់ទៅ ទៅគ្នាបួននាក់ ទៅដោះកម្មាភិបាល ៦នាក់ ដែលជាប់គុកនៅមន្ទីរ១៥ ជិតផ្ទះខ្ញុំ ។ បាទពេលនុ៎ង ដែលខ្ញុំឆ្លៀតឱកាសទៅចង់ដឹងដំណឹងអំពីឪពុកម្ដាយ និងនឹករលឹកម៉ែឪខ្ញុំនៅពេលនោះឯង ។

**ស៖** ចុះបុគ្គលិកស-២១ ផ្សេងទៀត តើមានការអនុញ្ញាតឲ្យទៅលេងផ្ទះដែរឬទេ? ឬក៏ឥតមានការអនុញ្ញាតឲ្យទៅលេងផ្ទះទេ?

**ឆ៖** បាទ, ខ្ញុំសូមជម្រាប គឺខ្ញុំអត់ដឹងដែរ ។

**ស៖** លោកជាអ្នកដឹងរឿងមួយចំនួន ហើយដោយសារលោកនៅយាមខាងក្រៅ សំណួរសួរថាតើនៅមន្ទីរសន្តិសុខស-២១ មានរថយន្តប៉ុន្មានគ្រឿងដែលប្រើប្រាស់ជាប្រចាំ? ហើយរថយន្តហ្នឹងម៉ាកអ្វីដែរ?

**ឆ៖** បាទ, រថយន្តដែលប្រើប្រាស់នៅកន្លែងស-២១ គឺមាន ឡង់រ៉ូវ៉ែ មិនដឹងរបស់ប្រទេសណាទេ ពីរ ហើយ កាត់ៗចិននោះ គឺរបស់ចិនពីរ ហើយឡានតូចហ្នឹងមួយទៀត គឺឡានដែលកង់បួនតូចនោះសម្រាប់ដឹកបន្លែដឹកអីគេហ្នឹងមួយទៀត ។

**ស៖** លោកដែលឃើញមានឡានម៉ាក់ ហ្សេអ៊ឹមសេ កង់១០ របស់ទាហាន របស់ជំនាន់ លន់ នល់ ប្រើ ទាហាន លន់ នល់ ប្រើ អាឡានដែលដឹកទាហាននោះណានៅស-២១ មានទេ?

**ឆ៖** បាទ, ខ្ញុំសូមជម្រាប ឡាននៅ ស-២១ គឺមានឡាន ហ្សេអ៊ឹមសេ របស់អាមេរិកកាំងហ្នឹង គឺឲ្យទៅបង ហ៊ុយ ស្រែ ។

**ស៖** មានប៉ុន្មានគ្រឿង? ហើយឲ្យទៅ ហ៊ុយ ស្រែ នៅឆ្នាំណាដែរ?

**ឆ៖** បាទ, គឺខ្ញុំដឹងពេល មាស ប៉េងគ្រី ចេញពីទួលស្លែងទៅ គឺឲ្យទៅបើកឡាននៅកន្លែងហ្នឹងប្រហែលជាក្នុងឆ្នាំ១៩៧៧ ។

**សៈ** នៅក្នុងកិច្ចប្រតិបត្តិការចាប់មនុស្សនៅក្នុងទីក្រុងភ្នំពេញ តើក្រុមរបស់លោក ឬក៏ដែលដឹកនាំដោយ ហ៊ី ជាអនុប្រធាននោះ មានដែលប្រើប្រាស់រថយន្ត ហ្សេអ៊ីមសេ កង់១០នោះទៅចាប់មនុស្សយកមកឃុំឃាំងនៅមន្ទីរសន្តិសុខស-២១ ដែរទេ?

[១៥:១៩:០៤]

**ឆៈ** បាទ, ខ្ញុំសូមទោសមានឡានមួយទៀត គឺគេហៅឡាន អាខ្វ័រ នោះគឺជញ្ជាំងជិត ឡានមួយហ្នឹង ដែលចេញទៅចាប់ទៅអីនោះ គឺឡានហ្នឹង ហើយឡង់រ៉ូវ៉ែ ។

**សៈ** យើងសួរអំមិញថាតើ ដែលប្រើឡាន ហ្សេអ៊ីមសេ កង់១០ ទាហានចំណាំតែប្រើប្រាស់ជំនាន់ លន់ នល់ ហ្នឹង ដឹកទាហានណា៎ អាកង់១០ ហៅថា ហ្សេអ៊ីមសេ កង់១០ ពណ៌ទាហាន តើដែលប្រើប្រាស់ឡាននេះទៅដឹកនៅក្នុងការចាប់មនុស្ស ដឹកពីកន្លែងនៅនានានៅក្នុងភ្នំពេញយកមក បញ្ចូលមកឃុំឃាំងនៅក្នុងមន្ទីរសន្តិសុខស-២១ ដែរឬក៏អត់? និយាយតែក្របខ័ណ្ឌឡាន ដែលមានលក្ខណៈជាទ្រង់ទ្រាយជា ហ្សេអ៊ីមសេ ដែលមានកង់១០ ប៉ុណ្ណោះ ។

**ឆៈ** បាទ, ខ្ញុំសូមជម្រាប គឺអត់មានទេ ។

**សៈ** លោកមើលគិតមើល៍ ជាទូទៅរបបហូប ដូចជាបបរ ការបែកចែកបបរឲ្យអ្នកទោសឃុំឃាំងហូប លោកបាននិយាយហើយអំមិញ ថាតើមានការប្រើប្រាស់ចានៗដើម្បីឲ្យចែករំលែកបបរឲ្យអ្នកទោសហូប ។ សួរថា តើលោកដែលឃើញនៅស-២១ ហ្នឹង មានការចែកបបរឲ្យអ្នកទោសកាឬទេ? ស្គាល់កាទេ? អាកាអាមេរិកាំង ដែលប្រើប្រាស់សម្រាប់សៀតចង្កេះ ហើយអាចដងទឹកផឹកក៏បានហ្នឹងរាង មានខ្លះ គឺជើងគោ គេហៅជើងគោ មានរាងផតមួយចំហៀង ។ សួរថា របបផ្តល់ផ្គត់ផ្គង់អាហារនៅទីនោះ គេមានផ្គត់ផ្គង់អាហារដោយបែកចែកដោយប្រើកាចែកអាហារបបរអ្នកឃុំខ្លួនដែរទេ?

**ឆៈ** បាទ, ខ្ញុំអត់ដែលបានចូលទៅមើលគេចែកបបរចែកអីនោះទេ ប៉ុន្តែអាកាហ្នឹង គឺគេសម្រាប់ដួសបបរ ដួសបបរដាក់ចានឲ្យអ្នកទោសហូបហ្នឹង ។

**សៈ** ឬក៏ប្រើហ្នឹង គ្រាន់តែជំនួសវែក ដូចវែកអ៊ីចឹង សម្រាប់ចាក់ទៅចានរបស់អ្នកទោស ទទួលបបរហូរ?

**ឆៈ** បាទ គឺកាហ្នឹង សម្រាប់ដួស តំណាងឲ្យវែក ព្រោះវែកតូចដួសអត់ទាន់ទេ ព្រោះតាមបន្ទប់អ្នកទោសច្រើនណាស់ គឺកាហ្នឹងហើយដួសបានច្រើនៗដាក់ឲ្យចានខាងអ្នកទោសហូបហ្នឹង ។ ដួសបានៗតែម្តង ។

**ប្រធានអង្គជំនុំ៖**

អរគុណលោក ហ៊ីម ហ៊ុយ ។ ខ្ញុំអស់សំណួរហើយ សួរអស់លោក លោកស្រីចៅក្រម តើមានសំណួរអ្វីត្រូវសួរដល់សាក្សីរូបនេះដែរឬទេ? មានទេ?

សូមអញ្ជើញលោកស្រីចៅក្រម ។

**សួរដោយចៅក្រម ស៊ីលយ៉ា ខាតវ៉ាយថ៍៖**

**ស៖** សូមអរគុណលោកប្រធាន ។ លោកសាក្សីលោកបានប្រាប់យើងថ្ងៃនេះថា លោកបានដឹងថា ពួកឈ្លើយសឹកវៀតណាមនោះត្រូវបានឃុំខ្លួននៅស-២១ ហើយពួកគេនោះត្រូវបានសម្លាប់ហើយកប់នៅម្តុំជិតៗស-២១ តើអ៊ីចឹងមែនទេ?

**ឆ៖** បាទ, គឺអ៊ីចឹងមែន ។

**ស៖** ហើយខ្ញុំគិតថា លោកបានបញ្ជាក់ពីចំនួនថា ឈ្លើយសឹកវៀតណាមនោះមានចំនួន៦០នាក់ តើអ៊ីចឹងមែនទេ?

**ឆ៖** បាទ, គឺអ៊ីចឹងមែន ។

**ស៖** រួមជាមួយឈ្លើយសឹកនោះ តើលោកបានឃើញពួកវៀតណាមណាផ្សេងទៀត ត្រូវបានគេឃុំខ្លួននៅស-២១ ទេ ដូចជាធម្មតាមកពីវៀតណាម ឬក៏ពួកជនដែលគេហៅថាជាគិញវៀតណាមនោះមានដែរឬទេ?

**ឆ៖** បាទ, ខ្ញុំសូមជម្រាបថា ឃើញតែទាហានហ្នឹងយកមក មិនដឹងអ្នកណាគិញ អ្នកណាអីបើនិយាយតែភាសាវៀតណាមទាំងអស់ ។

**ស៖** កាលពីដំបូងនៅក្នុងការជំនុំជម្រះសវនាការនេះ ជនជាប់ចោទបានឯកភាពថា ថាមានជនជាតិវៀតណាម អ្នកទោសវៀតណាម៣៤៥នាក់ ដែលគេរៀបរាប់ថា ភាគខ្លះអ្នកនោះ គឺជាទាហានអ្នកខ្លះជាគិញ ហើយមានមួយចំនួនខ្លះជាជនស៊ីវិលធម្មតា ដែលត្រូវបានឃុំខ្លួននៅស-២១ ។ តើលោកឯកភាពជាមួយនឹងចំនួននេះដែរឬទេ?

**ឆ៖** បាទ, ខ្ញុំសូមជម្រាប គឺខ្ញុំបើគាត់ថាប៉ុន្មាន ក៏ខ្ញុំឯកភាពជាមួយ ព្រោះខ្ញុំក្តាប់មិនបានជុំទេនៅកន្លែងនោះ ។

**ស៖** ដោយហេតុថា ជនជាប់ចោទបានឯកភាពថា មានអ្នកទោសវៀតណាម ៣៤៥នាក់ តើលោកៗអាចបញ្ជាក់បានដែរឬទេ ថាអ្នកទាំងអស់នោះត្រូវបានគេសម្លាប់នៅ-- ហើយយកទៅកប់នៅជុំ

វិញជិតៗស-២១ នោះ?

**ឆ៖** បាទ, គឺខ្ញុំពិតប្រាកដមែនលោក ។

**ស៖** នៅពេលដែលមានចំនួនមនុស្សច្រើនត្រូវបានសម្លាប់បែបនេះ ហើយកប់នៅជុំវិញនៅជិត ស-២១ តើលោកអាចប្រាប់ខ្ញុំបានទេ ថាតើការសម្លាប់ហ្នឹង សម្លាប់ទៅដោយរបៀបណា? ហើយការកប់ហ្នឹង គឺកប់របៀបណាដែរ?

**ឆ៖** បាទ, ខ្ញុំសូមជម្រាបថា ការសម្លាប់ហ្នឹង ក៏គេឲ្យលុតជង្គង់នៅរណ្ដៅហ្នឹង ហើយគេនឹងវ៉ៃដោយអីហ្នឹង ហើយគេហ្នឹងសម្លាប់ដូចតែគ្នាហ្នឹង ហើយបោះចូលទៅក្នុងរណ្ដៅ ហើយនិងគេកប់ ដូចគ្នាទាំងអស់ ។

**ស៖** ដូច្នេះ ត្រូវតែមានរណ្ដៅធំៗមួយចំនួនដែលគេជីកនៅក្បែរមន្ទីរស-២១ នោះ តើមែនឬទេ?

**ឆ៖** បាទ, គឺមែន ។

**ស៖** តើអង្គភាពរបស់លោកជាអ្នកទទួលខុសត្រូវក្នុងការជីករណ្ដៅហ្នឹងដែរឬទេ? បើមិនមែនតើក្រុមណាជាជីករណ្ដៅទាំងនោះ?

**ឆ៖** បាទ, ខ្ញុំសូមជម្រាប ផ្នែកការពារ គឺពួក ប៉េង ដែលជាអ្នកជីកហ្នឹង អ្នកសម្លាប់ហ្នឹង ។

**ស៖** លោកបាននិយាយអំពីអ្នកទោសល្បើយសឹកវៀតណាម ហើយនិងពួកបស្ចិមប្រទេសខ្លះ ចុះអំពីអ្នកទោសសញ្ជាតិផ្សេង តើលោកបានឃើញពួកអ្នកទោសថៃ ដែលគេយកមកឃុំនៅស-២១ ដែរឬទេ?

**ឆ៖** បាទ, ខ្ញុំសូមជម្រាបលោក គឺបានឃើញយកមកឃុំនៅកន្លែង ស-២១ ហ្នឹង តែហើយគេក៏ឲ្យទៅវិញអស់ទៅ ។

[១៥:២៨:១៤]

**ស៖** ដូច្នេះ លោកប្រាប់យើងថា អ្នកទោសជនជាតិថៃក៏ឃុំខ្លួននៅកន្លែងហ្នឹង ហើយក្រោយមកគេលែងវិញ ។ តើលោកអាចពន្យល់បានទេ ថាតើគេដោះលែងដូចម្ដេច? ហើយដំណើរការនោះយ៉ាងម៉េច?

**ឆ៖** បាទ, ខ្ញុំសូមជម្រាបលោក គឺខ្ញុំអត់ដឹងថា ទំនាក់ទំនងការងារនោះរបៀបយ៉ាងម៉េចទេ ឃើញគេបញ្ជូនយកទៅវិញអស់ទៅ ។

**ស៖** តើការបញ្ជូនចេញនោះ បញ្ជូនដោយឡានទៅជើងឯក ឬក៏គ្រាន់តែជាលែងចេញពីគុកនៃ ស-២១ នោះ?

**ឆ៖** បាទ, គឺបញ្ជូនចេញទៅក៏គេអត់មានដាក់ខ្នោះទេ កាលដែលយកមកក៏គេអត់មានដាក់ខ្នោះ ដាក់អីដែរ គឺបញ្ជូនទៅដោយស្រួល មានខោអាវ មានសម្លៀកបំពាក់របស់គេទៅវិញទាំងអស់ ។

**ស៖** ហើយតើលោកបានដឹងដែរឬទេ ថាតើជោគវាសនារបស់អ្នកទាំងអស់នោះដូចម្ដេចដែរ?

**ឆ៖** បាទ, ខ្ញុំសូមជម្រាបខ្ញុំអត់ដឹងទេ ពេលដែលគេចេញផុតទៅ គឺអត់ដឹងទាំងអស់ ។

[១៥:៣០:០០]

**ចៅក្រម ស៊ីលយ៉ា ខាតវ៉ាយថ៍៖**

ខ្ញុំឃើញថា លោកមេធាវី ហ្វ្រង់ស្វ័រ រូ ចង់មានយោបល់ចំពោះតុលាការ ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោក ហ្វ្រង់ស្វ័រ រូ តើចង់មានយោបល់អីទៅ?

**លោក ហ្វ្រង់ស្វ័រ រូ៖**

ខ្ញុំសូមអភ័យទោស ដោយសារការសុំនិយាយកាត់ ចំណុចនេះមិនមានទំនាក់ទំនងទាក់ទងទៅនឹង សំណួរ ហើយខ្ញុំយល់ថា គឺជាសំណួរធុំក្លិន ប៉ុន្តែយើងសុំឲ្យឃើញមានផ្សែងក្លិនដូចជាឆេះនៅកន្លែងនេះ អ៊ីចឹងសូមអញ្ជើញសន្តិសុខមកពិនិត្យ សូមមេត្តាចាត់ចែងឲ្យមានការពិនិត្យ ។

**លោកស្រី ម៉ាទីន ហ្សាកកាំង៖**

យើងក៏ធុំក្លិនផងដែរ ។

**ប្រធានអង្គជំនុំ៖**

ផ្នែកខាងមន្ត្រីតុលាការ និងសន្តិសុខ ចាត់ការពិនិត្យមើលស្ថានការណ៍ ពិនិត្យមើល តើវាមាន ហេតុការណ៍អីទេ?

**សួរដោយចៅក្រម ស៊ីលយ៉ា ខាតវ៉ាយថ៍៖**

លោកប្រធាន ខ្ញុំអាចបន្តបានដែរឬទេ ពីព្រោះខ្ញុំមើលទៅដូចមិនឃើញមានផ្សែងទេ ។

**ស៖ ឆ**សំណួរតទៅទៀត ។ តើអ្នកទោសសញ្ជាតិផ្សេងៗទៀត ដូចជាពួកអ្នកទោសឥណ្ឌា ពួក ឡាវ តើលោកបានឃើញអ្នកទោស ដែលមានសញ្ជាតិនៅក្នុងស-២១ កាលនោះ?

**ឆ៖** បាទ, ខ្ញុំសូមជម្រាប ខ្ញុំអត់បានដឹងទេ ។

**ស៖** ហើយសាធារណជនមិនចាំបាច់មានការភ័យខ្លាចទេ មានការដុតសំរាមនៅខាងក្រៅ ។ ដូច្នេះខ្ញុំបន្តទៅសំណួរទៀតទាក់ទងទៅនឹងពួកចាមមូស្លីម ដែលអាចនឹងត្រូវគេយកមកឃុំខ្លួននៅស-២១ ហើយខ្ញុំសូមយោងទៅលេខERN លេខ 00078437 ជាសៀវភៅមួយដែលហៅថា "សៀវភៅអ្នកគូបះ" ដែលសរសេរឡើងដោយលោក ឧស្មាន ហើយជាពិសេសនៅទំព័រ ERN78457 នៅក្នុងសៀវភៅនេះ មានជនជាតិចាមមូស្លីមមួយចំនួនត្រូវបានគេកំណត់ដោយអ្នកសរសេរសៀវភៅនេះ ថាគេយកមកឃុំខ្លួននៅស-២១ ។ ហើយការសម្លាប់នោះ ធ្វើនៅប្រហែលជាពីរភាគបី អ្នកទាំងអស់នោះក៏ត្រូវបានកត់ត្រាផងដែរ ។ តើលោកនៅចាំទេ ថាមានពួកចាមមូស្លីម ដែលគេយកមកឃុំខ្លួននៅ ស-២១ដែរឬទេ?

**ឆ៖** បាទ, ខ្ញុំអត់បាន១ដឹងទេ ។

[១៥:៣៣:៥៥]

**ចៅក្រម ស៊ីលយ៉ា ខាតវ៉ាយថ៍៖**

ឥឡូវនេះ ខ្ញុំចូលទៅដល់ឯកសារលេខ ERN លេខ 00242285 សូមអភ័យទោស ខ្ញុំមានអត្ថបទតែភាសាអង់គ្លេសទេ សូមឲ្យមន្ត្រីតុលាការអាចរកអត្ថបទជាភាសាខ្មែរឃើញឬទេ?

ដូច្នេះ ខ្ញុំសូមឲ្យមន្ត្រីតុលាការដាក់បង្ហាញបញ្ជី សូមឲ្យខាងសោតទស្សន៍ដាក់បង្ហាញនូវបញ្ជីនេះនៅក្នុងអេក្រង់ ។

សូមឲ្យបង្វិលទៅខាងលើ ដើម្បីមើលឃើញលេខ ERN គឺលេខ ERN ក្នុងភាសាខ្មែរ គឺ 0000 6728 ។

**សួរដោយចៅក្រម ស៊ីលយ៉ា ខាតវ៉ាយថ៍៖**

**ស៖** តើលោកមើលឃើញទេ លោក ហ៊ឹម ហ៊ុយ? នេះគឺជាបញ្ជីមួយដែលមានចំណងជើងថា "ឈ្មោះអ្នកទោសកម្ទេចដោយបង ហ៊ុយ ស្រែ" តើលោកអាចអានបានទេ តើលោកត្រូវការឲ្យខ្ញុំប្រាប់ថាបញ្ជីនោះមានអ្វីខ្លះនៅក្នុងនោះឬទេ?

**ឆ៖** បាទ, សូមលោកបញ្ជាក់ឲ្យខ្ញុំ ។

**ស៖** នៅក្នុងបញ្ជីនេះ គឺមានមនុស្ស១៧នាក់ ដែលដាក់ឈ្មោះ ដែលជាអ្នកទោស ដែលត្រូវបានកម្ទេចដោយបង ហ៊ុយ ស្រែ ។ បញ្ជីនោះចុះថ្ងៃបរិច្ឆេទថ្ងៃទី២៣ ខែកក្កដា ឆ្នាំ១៩៧៧ ហើយនៅខាងក្រោមបញ្ជីនេះ ពាក្យដូចខាងក្រោមនេះ គេបានសរសេរនៅកន្លែងនោះ "រួមទាំងអ្នកទោសនិងកុមារ គឺមាន១៦០នាក់ ត្រូវបានកម្ទេចទាំងអស់ ដោយផ្នែកស្រែ គឺ១៧៨នាក់" សំណួរខ្ញុំសួរទៅលោកនោះ គឺតើ

ខ្ញុំនិយាយត្រូវទេដោយបញ្ជាក់ថា មនុស្សអ្នកទោសទាំង១៧៨នាក់ រួមទាំងកុមារ១៦០នាក់ផងត្រូវបានសម្លាប់នៅជើងឯកនោះ?

**ឆ៖** បាទ, ខ្ញុំសូមជម្រាបថា ខ្ញុំអត់បានដឹងទេ ។

**ស៖** នៅស-២១ តើលោកបានឃើញកុមារដែលគេឃុំខ្លួនជាមួយឪពុកម្ដាយ ជាមួយម្ដាយនៅកន្លែងឃុំខ្លួននោះដែរឬទេ?

**ឆ៖** បាទ, ខ្ញុំសូមជម្រាប ដូចខ្ញុំបានជម្រាបពីមុនអ៊ីចឹង ឃើញគេឃុំខ្លួនកុមារនិងម្ដាយ គឺនៅក្នុងគុកជាមួយគ្នាទាំងអស់ ។

**ស៖** តើកុមារទាំងអស់ ក្រោយមកគេជួបនឹងជោគវាសនាដូចម្ដេចដែរ?

**ឆ៖** បាទ, ខ្ញុំសូមជម្រាបថា កុមារទាំងអស់នោះ ដែលជាប់នៅស-២១ហ្នឹង គឺ ពូប៉េង ជាអ្នកសម្រេចយកទៅសម្លាប់ចោល ដូចខ្ញុំជម្រាបអ៊ីចឹង ។ រឿងដឹកយកទៅជើងឯក ខ្ញុំអត់បានដឹងទេ អត់បានឃើញយកទៅទេ ។

**ស៖** នៅទីបំផុត ខ្ញុំត្រឡប់ទៅរកពួកបស្ចិមប្រទេស ដែលលោកនិយាយថា គេបានសម្លាប់ហើយហើយគេប្រើកង់ឡាន ដើម្បីដុតអ្នកទាំងនោះ ។ តើគេសម្លាប់អ្នកទាំងអស់នោះ ដោយរបៀបណាហើយគេសម្លាប់នៅកន្លែងណា?

**ឆ៖** បាទ, ចំនួនដែលខ្ញុំបានឃើញ គឺបួននាក់ហ្នឹង គឺនៅម្ដុំដែលគេហៅថា *បេប្លេហ៊ីម* គេសម្លាប់នៅកន្លែងហ្នឹង ។ ហើយបានស្លាប់ហើយ បានគេដុតនឹងកង់ឡានហ្នឹង នៅកន្លែងផ្លូវជាតិហ្នឹងម្ដុង នៅថ្នល់កៅស៊ូហ្នឹង ។

[១៥:៤០:១៥]

**ស៖** តើលោកអាចរំឭកប្រាប់ខ្ញុំបានទេ តើផ្លូវហ្នឹង ផ្លូវអ្វី ផ្លូវលេខប៉ុន្មានដែរ?

**ឆ៖** បាទ, ខ្ញុំស្គាល់តែ បេប្លេហ៊ីម អត់ដឹងថា ផ្លូវហ្នឹងលេខប៉ុន្មានៗទេ ។

**ចៅក្រម ស៊ីលយ៉ា ខាតវ៉ាយថ៍៖**

លោកប្រធាន ខ្ញុំមិនមានសំណួរអ្វីទៀតទេ ចំពោះសាក្សីនេះ ។ តើខ្ញុំអាចសួរសំណួរទៅជនជាប់ចោទទាក់ទងនឹងអង្គហេតុនេះបានដែរឬទេ?

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកស្រីចៅក្រម ។

**ចៅក្រម ស៊ីលយ៉ា ខាតវ៉ាយថ៍៖**

សូមអរគុណលោកប្រធាន ។ លោក កាំង ហ្គេកអ៊ាវ តើលោកបានបញ្ជាក់បានដែរឬទេថា ពួកចាមមូស្លីមក៏ត្រូវបានឃុំខ្លួននៅស-២១ ដែរនោះ?

**ជនជាប់ចោទ៖**

ជម្រាបប្រសាសន៍លោកជំទាវ! ខ្ញុំឃើញបញ្ហានេះដោយសារបញ្ជី តាមការវិភាគរបស់ខ្ញុំ ពួកនេះគឺប្រជាជនដែលរកស៊ីនៅភូមិអារ៉ាប់ អ្នកភ្នំពេញស្គាល់ហើយភូមិអារ៉ាប់ ជាកន្លែងដែលពួកមូស្លីមកម្ពុជាចិញ្ចឹមគោក្របីលក់ ហើយដល់ពេលជម្លៀសៗចេញទៅខាងតំបន់២៥ ដល់ក្រោយមក ណាត ប្រមូលដាក់គុកតាខ្មៅ រួចបានយកបញ្ជូនទៅសម្លាប់ ដូច្នេះអត់ឃើញហ្នឹងភ្នែកទេ ប៉ុន្តែបញ្ជីនៅសល់តាមខ្ញុំចាំដូចជាសាមសិបប្លាយនាក់ ឬក៏ប៉ុន្មានទេ ខ្ញុំភ្លេចហើយ សូមទោសជាមុន ដូច្នេះខ្ញុំសូមបញ្ជាក់ប៉ុណ្ណេះ ។

**ចៅក្រម ស៊ីលយ៉ា ខាតវ៉ាយថ៍៖**

តើលោកបានដឹងថា បញ្ជីដែលខ្ញុំបានយោងពីខាងដើមដែលថា គេបញ្ជាក់នៅក្នុងសៀវភៅមួយឈ្មោះ “អូគូបះ” នោះ?

**ជនជាប់ចោទ៖**

ជម្រាបប្រសាសន៍លោកជំទាវ! បញ្ជីនេះខាងផ្នែក-- មិនដឹងជាខាងការិយាល័យសហព្រះរាជអាជ្ញាមិនដឹង ការិយាល័យសហចៅក្រមស៊ើបអង្កេតមិនដឹងឲ្យមកខ្ញុំ ឲ្យខ្ញុំធ្វើអត្ថាធិប្បាយអំពីអ្នកទោសកម្ទេចដូច្នេះខ្ញុំបានធ្វើអត្ថាធិប្បាយទៅវាឃើញពួកមូស្លីមហ្នឹងប៉ុន្មាននាក់ហ្នឹង ។ ដូច្នេះ ខ្ញុំសូមជម្រាបប្រសាសន៍ប៉ុណ្ណេះ ។ រួចសូមបញ្ជាក់បន្ថែមបន្តិចទៀតថា បញ្ជីឈ្មោះទាំងអស់នេះ ក៏វានៅមានក្នុងបញ្ជីមេរបស់ស-២១ ដែរ ។

**ចៅក្រម ស៊ីលយ៉ា ខាតវ៉ាយថ៍៖**

សូមអរគុណ ។ អ៊ីចឹងត្រឡប់មកបញ្ជីអ្នកទោសដែលកម្ទេចដោយបង ហ៊ុយ ស្រែ នេះ ដែលមានចំណារនៅខាងក្រោមដែលនិយាយថា អ្នកទោសទាំងអស់ រួមទាំងកុមារ១៦០នាក់ ត្រូវបានកម្ទេចដោយបង ហ៊ុយ ស្រែ នោះ គឺសរុបទៅ ១៧៨ ហើយខ្ញុំដឹងថា លោកបានទទួលស្គាល់អង្គហេតុនេះពីមុន ។ ប៉ុន្តែ អ្វីខ្ញុំចង់យល់ឲ្យច្បាស់ពីលោកនោះ គឺថាតើកុមារទាំងនេះ គេយកសម្លាប់ដោយវិធីណា? ហើយសម្លាប់នៅកន្លែងណា?

**ជនជាប់ចោទ៖**

ជម្រាបប្រសាសន៍លោកជំទាវ! កុមារអស់នេះ យកចេញពីស-២១ មជ្ឈមណ្ឌលស្រែព្រៃស មនុស្សទាំងដប់ប្រាំបីនាក់ ក៏យកចេញពីនោះដែរ ។ ដូច្នេះ គេដាក់ផ្នែក គេអត់និយាយថា ដោយបង ហ៊ុយ ស្រែផ្នែកបង ហ៊ុយ ស្រែ ។ អ្នកដែលស៊ីញ៉ៃនៅក្នុងអត្ថបទនេះ គឺមិត្តហ៊ី របស់ខ្ញុំនេះទេ ជាអ្នកស៊ីញ៉ៃ ។ ដូច្នេះ មិត្តហ៊ី ចាត់ចែង ខ្ញុំជឿថាសម្លាប់នៅជើងឯក ។ នេះខ្ញុំសូមបញ្ជាក់ប៉ុណ្ណោះ ។ ដោយគោរព ។

**ចៅក្រម ស៊ីលយ៉ា ខាតវ៉ាយថ៍៖**

ហើយលោកបាននិយាយពីខាងដើមថា លោកមិនច្បាស់អំពីរបៀបដែលគេសម្លាប់អ្នកទាំងនោះទេ ប៉ុន្តែលោកជឿថា ពួកគេអាចនឹងត្រូវបានគេសម្លាប់ ដោយបោកក្មេងៗទាំងនោះទៅនឹងគល់ឈើ តើអ៊ីចឹងមែនឬទេ?

[១៥:៤៥:១២]

**ជនជាប់ចោទ៖**

ជម្រាបប្រសាសន៍លោកជំទាវ! ខ្ញុំនៅតែជឿបញ្ហានេះហើយនៅតែសោកស្តាយឈឺចាប់រហូតទាល់ឥឡូវ ។ ជឿ ខ្ញុំជឿ ។

**ចៅក្រម ស៊ីលយ៉ា ខាតវ៉ាយថ៍៖**

សូមអរគុណ ដែលលោកបានឆ្លើយ ។ គឺដើម្បីកំណត់នូវអង្គហេតុដើម្បីឲ្យតុលាការមានឱកាសដើម្បីធ្វើសេចក្តីសម្រេច ដើម្បីឲ្យពលរដ្ឋកម្ពុជាអាចនឹងទទួលបានព័ត៌មានជាការពិតហ្នឹង ។ សូមអរគុណដែលលោកបានឆ្លើយសំណួរនេះ ។ សូមអរគុណលោកប្រធាន ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកចៅក្រម យ៉ា សាខន ។

**សួរដោយ ចៅក្រម យ៉ា សុខន៖**

**ស៖** លោក ហ៊ីម ហ៊ុយ កាលពីព្រឹកមិញលោកបានបញ្ជាក់ថាជនជាប់ចោទ និងហ៊ី មានទំនាស់នឹងគ្នាបីដង ។ តើទំនាស់គ្នានោះពីរឿងអ្វី លោកមានដឹងទេ?

**ឆ៖** ខ្ញុំសូមជម្រាប គឺខ្ញុំពីតាហ៊ី ប្រាប់ខ្ញុំ ។ គាត់ថាអញទំនាស់ជាមួយគាត់បីដងហើយ គឺទំនាស់រឿងបក្ខពួក គាត់ថាពួកយើងអញកាន់ជើងខាងពួកយើង ។ រឿងហ្នឹងហើយដែលខ្ញុំដឹងពីគាត់ ។ គាត់

ថាគាត់កាន់ជើង៧០៣ ។

**ស៖** ទំនាស់រវាង ឌុច និងហ៊ី វាកើតឡើងមុនពេលនៃការចាប់បុគ្គលិកស-២១ ទេ?

**ឆ៖** ខ្ញុំសូមជម្រាបលោក! គឺទំនាស់គ្នាតាំងពីមុនចាប់បុគ្គលិកនៅស-២១ ហ្នឹងណោះ ។

**ស៖** មុននេះបន្តិចលោកបានបញ្ជាក់ថា បុគ្គលិក ស-២១ ដែលបានសម្លាប់នេះសុទ្ធតែកម្លាំងមកពីកងពល៧០៣ ពុំមានសម្លាប់កម្លាំងមកពីបស្ចិមទេ ។ តើលោកចង់និយាយយ៉ាងម៉េចអំពីបញ្ហានេះ?

**ឆ៖** បញ្ហាហ្នឹងបានខ្ញុំនិយាយថា តាហ៊ី គាត់ថា តាឌុច ចោទគាត់ថា គាត់កាន់ជើងពួក៧០៣ ដែលមកនៅធ្វើការនៅកន្លែងស-២១ហ្នឹង ។ ដល់ក្រោយមក ៧០៣ ដែលគេចាប់មក ក៏ឆ្លើយដាក់ពួក ៧០៣ ដែលនៅធ្វើការនៅទួលស្លែងហ្នឹង ។ ហើយក៏ចាប់អ្នកដែលធ្វើការនៅទួលស្លែងហ្នឹងទៀត ។

**ស៖** គេចាប់បុគ្គលិកស-២១ យកទៅឃុំ គេធ្វើរបៀបម៉េច? តើដូចជាការចាប់អ្នកដទៃដែរឬយ៉ាងម៉េច?

**ឆ៖** ខ្ញុំសូមជម្រាបលោក! គឺខ្ញុំអត់បានដឹង ហើយឃើញគេចាប់របៀបយ៉ាងម៉េចៗទេ ព្រោះឃើញតែបាត់គ្នា ហើយនិងចូលគុក ដើរទៅឃើញដែលចូលក្នុងគុកហើយ ។ រឿងអត់ថាគេចាប់របៀបម៉េចៗ គឺខ្ញុំអត់ដឹង ហើយមិនដឹងថារឿងហ្នឹងវាកើតពីរឿងអីបានគេចាប់នោះ ។

**ស៖** លោកបានបញ្ជាក់ថាចំពោះអ្នកទោសស្រី មិនដាក់ខ្នោះទេ គេយកទៅ ដាក់នៅក្នុងបន្ទប់ធំ ហើយគេចាក់សោពីក្រៅ ។ តើការរងូតទឹក ឬបត់ជើង បត់ដៃរបស់អ្នកទោសស្រីហ្នឹងធ្វើយ៉ាងម៉េចវិញ?

**ឆ៖** អ្នកទោសស្រីដែលគេយកទៅដាក់ឃុំឃាំងនៅបន្ទប់ធំៗហ្នឹង គឺបត់ជើង បត់ដៃអីហ្នឹង គឺគេឲ្យស្លៀកសារុង ស្លៀកអីហ្នឹង បត់ជើងបត់ដៃក្នុងបន្ទប់ហ្នឹង ។

**ចៅក្រម យ៉ា សុខន៖**

សូមអស់សំណួរលោកប្រធាន ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកចៅក្រម ហ្សង់ម៉ាក ។

**សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

**ស៖** សួស្តី តើនៅពេលដែលលោកទៅដល់ស-២១ លោកមានតួនាទីគ្រាន់តែជាអ្នកយាមសាមញ្ញតែប៉ុណ្ណោះ តើអ៊ីចឹងមែនដែរឬទេ? ឬក៏លោកទៅដល់នោះភ្លាមមានតួនាទីខ្ពស់តែម្តងចំពោះការងាររបស់លោក?

**ឆ៖** ខ្ញុំសូមជម្រាបលោក! គឺទៅដល់នោះភ្លាម គឺខ្ញុំយុទ្ធជនទេនៅកន្លែងនោះ ។

**ស៖** បន្ទាប់មកលោកទទួលខុសត្រូវលើអង្គភាពមួយ ដែលអង្គភាពនោះទទួលខុសត្រូវទៅលើការដឹកអ្នកទោសទៅជើងឯក ហើយក៏ទទួលខុសត្រូវទៅលើចាត់ការលើការមកដល់របស់អ្នកទោស និងចាប់ខ្លួនផងដែរ ។ ថាតើតួនាទីនេះជាតួនាទីខ្ពស់ដែរឬទេ? ហើយនៅក្នុងស្ថានភាពណាដែលគេចាត់តាំងឲ្យលោកធ្វើការងារបែបនេះ? ហើយអ្នកណាគេជាអ្នកប្រគល់សិទ្ធិឲ្យលោកធ្វើការងារដូច្នេះ?

**ឆ៖** ខ្ញុំសូមជម្រាបលោក គឺខ្ញុំដែលចូលទៅដល់កន្លែងហ្នឹងនៅយូរដែរ បានឲ្យខ្ញុំ-- ខ្ញុំនៅយុទ្ធជនទេ ក្រោយមកបានគេឲ្យខ្ញុំធ្វើមេក្រុម។ ធ្វើមេក្រុមហើយក៏ពេលដែលគេចាប់ក្នុងឆ្នាំ១៩៧៧ កម្មាភិបាលកន្លែងហ្នឹង បានគេឲ្យខ្ញុំឡើងអនុកងរយបណ្ដោះអាសន្នហ្នឹង ឲ្យនៅចាំទទួលអ្នកទោសដែលគេដឹកមកពីណាពីណី ទៅចាប់នោះគ្រប់កន្លែងហ្នឹង គឺតាហ៊ី អ្នកចាត់តាំងខ្ញុំ ។

[១៥:៥២:៥៧]

**ស៖** តើមានអ្វីកើតឡើងចំពោះអ្នកទាំងឡាយដែលគាត់ពីដើមនោះមានតួនាទីដូចលោកដែរ? ថាតើអ្នកដែលគាត់ធ្លាប់មានតួនាទីដូចលោកនោះមានអ្វីកើតឡើងចំពោះពួកគាត់ ថាពួកគេនោះត្រូវបានចាប់ខ្លួន ឬយ៉ាងម៉េច?

**ឆ៖** ខ្ញុំសូមជម្រាបលោក គឺខ្ញុំអត់ដឹងថា គេមានរឿងអីៗ គឺខ្ញុំអត់ដឹងទេ ។ ដល់អស់អ្នកនេះហ្នឹងបានគេឲ្យខ្ញុំឡើងបណ្ដោះអាសន្នហ្នឹង គឺតាហ៊ី គាត់ឲ្យឡើង ។

**ស៖** តើលោកអាចជម្រាបយើងខ្ញុំយ៉ាងម៉េចអំពីវិន័យនៅស-២១? លោកបានប្រាប់លោកប្រធានពីមុននេះថាក្នុងពេលដែលលោកនៅទីនោះ គេមិនអនុញ្ញាតឲ្យលោកទៅលេងគ្រួសារនោះទេ ។ ថាតើលោកអាចជម្រាបអំពីជីវិតប្រចាំថ្ងៃនៅទីនោះដែរឬទេ? គឺវាមានវិន័យតឹងរឹងយ៉ាងម៉េច? ហើយគេអនុញ្ញាតឲ្យលោកនិយាយជាមួយនឹងអ្នកធ្វើការជាមួយលោកដែរឬទេ? ហើយគេឲ្យលោកនិយាយជាមួយនឹងផ្នែកការពារដែរឬទេ? ហើយគេឲ្យលោកធ្វើការដើរទៅណាមកណាដែរឬទេ? តើលោកអាចសុំគេឈប់សម្រាកដែរឬទេ? តើលោកអាចជម្រាបយើងខ្ញុំយ៉ាងម៉េចអំពីការងារទាំងអស់នេះ?

**ឆ៖** ពីដំបូងដែលខ្ញុំទៅនៅកន្លែងហ្នឹង ខ្ញុំឃើញគុក ខ្ញុំខ្លាចខ្ញុំ ខ្លាចៗងាប់ក្នុងគុកហ្នឹងដែរ សុនសេន មកបង្រៀនសូត្រខ្ញុំ គឺខ្ញុំនឹកឃើញកន្លែងនេះអត់រស់ សុំគាត់ទៅទ័ពកាលនោះកំពុងច្បាំងជាមួយវៀតណាម ។ ថាអ៊ំៗសុំអ៊ំឯងទ័ពវិញហើយ គាត់ថាមិត្តឯងប៉ានវ៉ៃយួនអត់? ប៉ានៗអ៊ំប៉ាន គាត់លែងមាត់ទៀតហើយ ។ ហើយមួយទៀតវិន័យដែលនៅស-២១ កាលដំបូងអត់អីទេ ប្រឡែងលេងជាមួយ

គ្នាបាន និយាយគ្នាលេងបាន ក្រោយមកនៅពេលចាប់កម្មាភិបាល ចាប់អ្នកធ្វើការនៅកន្លែងហ្នឹង គឺគែលែងឲ្យនិយាយគ្នា គេដាក់វិន័យតឹងតែងឲ្យតាមដានគ្នាទៅវិញទៅមក យុទ្ធជន និងកម្មាភិបាលតាមដានគ្នាទៅវិញទៅមក ហើយយុទ្ធជនប៊ិានរាយការណ៍ទៅថ្នាក់លើចំពោះមេកម្មាភិបាលណាដែលខុស គឺឲ្យរាយការណ៍បាន ។ ហើយការដើរហើរទៅណាមកណា គឺអត់មានពេលដើរទេ មានតែពេលគេប្រើឲ្យទៅបានទៅ អត់មានទៅណាស្រេចចិត្តបាន ។ ចំពោះទៅលេងផ្ទះសម្បែងទៀតក៏គេអត់ឲ្យទៅលេងបានដែរ ។

[១៥:៥៦:០៥]

**ស៖** តើលោកចាំដែរឬទេ? គឺវាមានឧបករណ៍មួយដែលនៅក្បែរលោកធ្វើការ គឺឧបករណ៍នោះគេប្រើសម្រាប់ធ្វើការថតការសន្ទនាតាមទូរស័ព្ទ តើលោកចាំទៅលើចំណុចនេះដែរឬទេ?

**ឆ៖** ខ្ញុំសូមជម្រាបថា ខ្ញុំអត់មានចាំពីរឿងហ្នឹងទេ ។

**ស៖** ក្នុងពេលដែលការតតាំងគ្នានៅចំពោះមុខសហចៅក្រមស៊ើបអង្កេត គឺមានលេខឧបសម្ព័ន្ធលេខD54 នៅក្នុងសំណុំរឿង សាក្សី ម៉ម ណៃ ដែលបានមកផ្ដល់សក្ខីកម្មកាលពីម្សិលមិញបានបញ្ជាក់ថា នៅជិតកន្លែងដែលលោកធ្វើការងារនោះ គឺវាមានឧបករណ៍មួយដែលគេប្រើសម្រាប់ថតការសន្ទនាតាមទូរស័ព្ទ ហើយគេសួរលោកនៅពេលនោះ នៅក្នុងចំណោមចៅក្រមស៊ើបអង្កេត គឺមានម៉ាស៊ីនមួយដែលគេបានដំឡើងនៅពេលមុនលោកទៅដល់ ហើយលោកបានឆ្លើយថា លោកគិតថាឧបករណ៍នោះវាស្រដៀងទៅនឹងឧបករណ៍សម្រាប់ស្ដាប់ ថតកាសែត ឬស្ដាប់កាសែតអីផ្សេងៗ តើលោកអាចជម្រាបខ្ញុំឡើងវិញអំពីបញ្ហានេះដែរឬទេ?

**ឆ៖** ខ្ញុំសូមជម្រាបថា ឧបករណ៍នោះគឺ ផេង អ្នកកាន់តេអូទេ អ្នកបច្ចេកទេសរៀបចំប្រដាប់ថត ប្រដាប់នេះហ្នឹង តែថតរឿងថតកន្លែងណាៗខ្ញុំអត់ដឹងដែរ ។ ព្រោះខ្ញុំអត់ចេះអាអស់ហ្នឹងផង ។

**ស៖** នៅពេលដែលសហចៅក្រមស៊ើបអង្កេតសួរលោក ហើយអ្នកស៊ើបអង្កេតសួរលោក ទាក់ទងទៅនឹងការសម្រិតសម្រាំងនិងកម្ទេចអ្នកទោសនៅស-២១ តើតាមលោកនៅក្នុងក្រុមនីមួយៗនៅស-២១ ឬក៏អង្គភាពនីមួយៗ លោកបាននិយាយថា បុគ្គលិកចិតសិបភាគរយ ត្រូវបានគេសម្រិតសម្រាំង និងកម្ទេចចោល តើចំនួនតួលេខភាគរយនេះតើលោកជឿជាក់ថាវាពិតដែរឬទេ? តើលោកផ្អែកលើចំណុចអ្វីដែលអាចដល់តួលេខ ចិតសិបភាគរយនេះបាន?

**ឆ៖** ខ្ញុំសូមជម្រាបថា កាលមុនគ្នាមួយគំនរហើយដល់យូរៗអស់គ្នា ចង់អស់គ្នាហើយ ខ្ញុំផ្អែកទៅលើហ្នឹង ។

[១៦:០០:០០]

**សៈ** ក្រៅពីបុគ្គលិកកងពល៧០៣ ថាតើមានបុគ្គលិកផ្សេងៗទៀតដែរឬទេ ដែលក្លាយទៅជាជនរងគ្រោះនៃការសម្រិតសម្រាំងនិងកម្ទេចនោះ?

**ឆ៖** បាទ, ខ្ញុំឃើញថា ភាគច្រើនគឺ៧០៣ហ្នឹងតែម្ដង ដែលធ្វើការនៅស-២១ហ្នឹងភាគច្រើនគឺ ៧០៣ ហ្នឹង ។

**សៈ** តើលោកមានលទ្ធភាពឱកាសក្នុងការជួបជាមួយនឹងជនជាប់ចោទញឹកញាប់ដែរឬទេ? ហើយថា បើសិនជួបគាត់មែនតើលោកអាចជម្រាបអំពីអាកប្បកិរិយារបស់គាត់ដែរឬទេ? ថាតើគាត់មានអាកប្បកិរិយាផ្ដាច់ការយ៉ាងម៉េច? ហើយគាត់និយាយជាមួយលោកក្នុងរបៀបយ៉ាងម៉េច? តើលោកអាចជម្រាបបានដែរឬទេ?

**ឆ៖** បាទ, ខ្ញុំសូមជម្រាបថា ការជួបជាមួយគាត់ហ្នឹងគាត់និយាយសម្ដីគាត់និយាយសឹងតែមិនឮ តែបើការងាររបស់គាត់ គឺគាត់ធ្វើហ្មត់ចត់ណាស់ការងាររបស់គាត់ ។

**សៈ** តើលោកខ្លាចគាត់ដែរឬទេ? ថាតើលោកខ្លាចទេ នៅពេលដែលលោកធ្វើការនៅស-២១?

**ឆ៖** បាទ, ខ្ញុំសូមជម្រាបលោក គឺខ្ញុំខ្លាចតាំងពីខ្ញុំចូលមកដល់ឃើញគុកហ្នឹងខ្ញុំខ្លាចគុក ដំបូងខ្ញុំខ្លាចគុក លុះជិតដល់អាពេលចាប់គ្នាច្រើន ចាប់ពី៧០៣ ចាប់អ្នកធ្វើការនៅកន្លែងហ្នឹង ខ្ញុំចាប់ផ្ដើមព្រួយចិត្តរហូត មិន តាឌុច ទេ តាហ៊ ក៏ខ្ញុំខ្លាចដែរ ។ តាហ៊ ដេរម៉ែខ្ញុំទៀត ។ ខ្ញុំយំ ខ្ញុំបើកសោ បើកសោកាំភ្លើងបម្រុងនឹងបាញ់ខ្លួនចោលទៀត គឺអស់រយៈជាងមួយម៉ោងជាង យាមម្នាក់។

[១៦:០២:៣៣]

**សៈ** លោកបានលើកឡើងថា សង្កេតឃើញអ្នកដែលនៅជុំវិញខ្លួនលោកបានបាត់ខ្លួនម្ដងបន្តិចៗ តើលោកដឹងដែរឬទេ? ថាតើគេបានប្រព្រឹត្ត បើសិនតើមានកំហុសអ្វីដែលនាំឲ្យគេបញ្ជូនអ្នកដែលប្រព្រឹត្តខុសហ្នឹងទៅអប់រំ?

**ឆ៖** បាទ, អ្នកដែលគេបញ្ជូនឲ្យទៅអប់រំនៅព្រៃស នោះអ្នកខ្លះដូច ប៉េង គ្រី ក្រឡាប់ឡានជាមួយខ្ញុំអ៊ីចឹង ដឹងថាក្រឡាប់ឡាន ។ ហើយដូច សោម ម៉េត ខ្ញុំដឹងថាដក សោម ម៉េត ទៅហ្នឹងគឺពាក់ព័ន្ធជាមួយបងម្នាក់គឺឈ្មោះ ម៉េង ដែលគេចាប់មកចូលក្នុងស-២១ ហ្នឹង ហើយអ្នកដទៃទៀតដែលគេដក

យកទៅខ្ញុំអត់ដឹងដែរថាមិនដឹងជារឿងអី?

[១៦:០៣:៣៧]

**ស៖** លោកខ្លួនឯងបានលើកឡើងនៅពេលមួយថា លោកបានទៅធ្វើការនៅស្រែ តើលោកទៅធ្វើការនៅព្រៃសដែរឬទេ? ថាតើលោកនៅទីនោះដើម្បីទទួលការអប់រំ ឬក៏លោកទៅធ្វើការងារណាមួយផ្លូវការដែលគេបញ្ជូនលោកទៅ?

**ឆ៖** បាទ, ការបញ្ជូនខ្ញុំទៅហ្នឹងគឺឲ្យទៅធ្វើ ឲ្យទៅជួយលើកទំនប់ជីកប្រឡាយ។ ដល់ទៅលើកទំនប់ជីកប្រឡាយដល់ពេលថ្ងៃរសៀលដល់យប់ម៉ោងប្រាំមួយ ម៉ោងប្រាំពីរ ចាប់ផ្ដើមទៅរែកដី អត់ស្គាល់ក្រុមខ្លួនឯង អត់ដឹងថាក្រុមខ្លួនឯងនៅក្រុមមួយណា ទៅដល់នោះគេឲ្យចូលជាមួយគ្នាទាំងអស់ចូលជាមួយគ្នា មិនដឹងក្រុមណា ដកពីនេះទៅគ្នាប៉ុន្មានក្រុម ទៅដល់នោះ ដល់ទៅរែកដី ខ្ញុំទៅរែកជាមួយខាង៧០៣ ទៅវិញ មិនដឹងក្រុមណាៗ ខ្ញុំអត់ស្គាល់ រែកមានតែពេលម៉ោងដប់មួយយប់បានៗដេក ។ ព្រលឹមឡើង រែកទៀត ជីកប្រឡាយទៀត ។

**ស៖** តើលោកទទួលខុសត្រូវទៅលើកង ឬក្រុមមួយដែរឬទេ? ថាលោកត្រួតពិនិត្យចាត់ចែងការងារទៅលើក្រុម ឬកងដែរឬទេ? ឬក៏លោកខ្លួនឯងនេះ ត្រូវបានគេចាត់តាំងឲ្យលោកទៅធ្វើការនៅស្រែនៅទីនោះតែម្ដង ឬក៏គេចាត់តាំងឲ្យលោកគ្រប់គ្រងកងណាមួយនៅស្រែនោះ?

**ឆ៖** បាទ, កាលខ្ញុំទៅធ្វើស្រែកាលនោះ ខ្ញុំអត់មានគ្រប់គ្រងកងណាទេ ទៅនៅជាមួយគេ ជីកតែទំនប់ លើកប្រឡាយហ្នឹង ។

**ស៖** នៅពេលដែលគេបញ្ជូនលោកទៅព្រៃស គេប្រាប់លោកថា គេបញ្ជូនលោកទៅនោះដើម្បីអប់រំដែរឬទេ? ហើយគេមានប្រាប់ហេតុផលអ្វីបានជាគេបញ្ជូនលោកទៅទីនោះ?

**ឆ៖** កាលនោះគឺខ្ញុំអត់ដឹងថារបៀបម៉េចទេ គឺគេឲ្យទៅៗនៅក្រុមជាមួយគេទាំងអស់នោះ ហើយនាំគ្នាជីកប្រឡាយអីលើកទំនប់ទាំងអស់ លើកតាំងពីអាផ្លូវទៅព្រៃសរហូតមកដល់ជិតមាត់ស្ទឹងឯកើតណោះ ហើយអាពីជើងទៅហួសផ្ទះ លន់ ណុន ហួសកន្លែងផ្ទះ លន់ ណុន ហ្នឹងទៅខាងត្បូងប្រហែលជាមួយគីឡូដីទៀត ពួកខ្ញុំលើករហូតទៅដល់ផ្ទះបង ហ៊ុយ ហ្នឹង។ ហ្នឹងលើកជាមួយខាង៧០៣ ព្រំជាប់គ្នា លើកដីហ្នឹង លើកផ្លូវហ្នឹង ។

**ស៖** ថាតើគេដាក់ខ្នោះលោក ខ្នោះជើងលោកនៅពេលយប់ដែរឬទេ? ហើយថាតើគេដាក់លោកនៅទីនោះយ៉ាងម៉េច? គេចាក់សោរលោកនៅក្នុងបន្ទប់ដែរឬទេ?

[១៦:០៧:១៩]

**ឆ៖** បាទ, ខ្ញុំសូមជម្រាបថា អត់មានចាក់សោរចាក់អីទេ គឺឲ្យទៅហ្នឹងទៅនៅជួយលើកធ្វើផ្លូវ បរឡានបរអីចូលទៅផ្ទះបងហ៊ុយ ហ្នឹងសម្រាប់ដឹកស្រូវដឹកអីហ្នឹង គឺយប់ដេកជាមួយគ្នាធម្មតានៅកន្លែងហ្នឹង ។

**ស៖** នៅពេលនេះខ្ញុំសូមត្រឡប់ទៅនិយាយតួនាទីរបស់ ឌុច ហើយនិងអ្វីដែលលោកបានជម្រាបយើងខ្ញុំ ។ តើលោកអាចជម្រាបយើងខ្ញុំដែរឬទេ ថាតើជនជាប់ចោទបានចូលរួមដោយខ្លួនគាត់ផ្ទាល់នេះបានចូលរួមក្នុងការចាប់ខ្លួនដែរឬទេ? ហើយថាតើតួនាទីរបស់គាត់នោះចម្បងយ៉ាងម៉េចនៅក្នុងការចាប់ខ្លួននោះ?

**ឆ៖** បាទ, តួនាទីរបស់គាត់ គឺចម្បងក្នុងការត្រួតពិនិត្យពួកខ្ញុំ ធ្វើការចាប់ខ្លួន ធ្វើម៉េចឲ្យបានឲ្យសម្រេចតាមផែនការរបស់គាត់ដែលគាត់ប្រគល់ឲ្យពួកខ្ញុំចាប់ ។

**ស៖** នៅពេលដែលអ្នកស៊ើបអង្កេតសួរលោក ខ្ញុំនិយាយអំពីឯកសារ D59/6 ទំព័រ៤ នៅក្នុងឯកសារបារាំងនោះបានលើកឡើងថា ខ្ញុំមិនដឹងថាតើ ឌុច ត្រូវចាប់មនុស្សប្រភេទណានោះទេ គាត់ចេញទៅចាប់មនុស្សនៅក្នុងភ្នំពេញ បើសិនជានៅក្រៅភ្នំពេញ គឺហ៊ី ជាអ្នកទៅចាប់ ។ ដូច្នេះ តើលោកបានឃើញផ្ទាល់ភ្នែកដែរឬទេ ដែលថា ឌុច ខ្លួនឯងផ្ទាល់នោះ គាត់ទៅចាប់ខ្លួន ឬក៏លោកដឹងទេថា ឌុច គាត់មានវត្តមានទេ នៅពេលដែលគាត់ទៅចាប់ខ្លួននៅភ្នំពេញនោះ?

**ឆ៖** បាទ, ពេលដែលទៅចាប់ខ្លួនហ្នឹង គាត់អត់មានវត្តមានចាប់ទេ តែពួកខ្ញុំទេជាអ្នកចាប់ ។ ព្រោះគាត់ស្គាល់អ្នកនោះទាំងអស់ បើគេស្គាល់គាត់ ឃើញគាត់ គេដឹងខ្លួនថាគាត់ទៅចាប់គេហើយ ។

**ស៖** ខ្ញុំសូមធ្វើការបំភ្លឺ ឲ្យលោកបំភ្លឺនូវអ្វីដែលលោកបាននិយាយមុនហ្នឹងទាក់ទងទៅនឹងវត្តមានរបស់ជនជាប់ចោទនៅជើងឯក ។ អ្នកស៊ើបអង្កេតក៏បានសម្ភាសន៍លោកលើបញ្ហានេះដែរ។ លោកបានរៀបរាប់អំពីវិធីសាស្ត្រនៃការសម្លាប់ទៅលើអ្នកទោស ដែលវាស្របគ្នាទៅនឹងអ្វីដែលលោកបាននិយាយនៅថ្ងៃនេះ។ ប៉ុន្តែ លោកក៏បាននិយាយដូច្នេះដែលថា ខ្ញុំនិយាយយោងទៅលើឯកសារ D59/6 នៅក្នុងទំព័រ៧ លោកបានលើកឡើងថា អ្នកទោសត្រូវបានគេវាយ ត្រូវបានគេដាក់ខ្នោះដៃ ហើយត្រូវបានគេអារ-ក ដោយសារតែ តាឌុច និង តាហ៊ី ចង់ឲ្យធ្វើដូច្នោះ ។ តាហ៊ី ជាអ្នកបញ្ជាឲ្យធ្វើ។ ហើយបើសិនតាឌុច មកគឺគាត់មកធ្វើការពិនិត្យមើលនិងសង្កេតទៅលើកន្លែងសម្លាប់នោះ។ ហើយគឺគាត់ហៅឲ្យប្រជុំគាត់បាននិយាយថា វាយអ្នកទោស គឺវ៉ៃនឹងដងដែកនោះគឺវាមិនគ្រប់គ្រាន់ទេ ត្រូវអារ-កទៀត។ ដូច្នេះ

ហើយនេះជាអ្វីដែលគាត់ទៅទីកន្លែងនោះ។ ហើយនៅពេលនោះ សួរថាតើគេសម្លាប់យ៉ាងម៉េច? ការឆ្លើយនោះគឺថា ឌុច និង ហ៊ី គាត់បង្រៀននៅពេលប្រជុំថា ឲ្យលុតជង្គង់ ហើយឲ្យយកដែកវាយកញ្ចឹងក រួចបានអារ-ក តើលោកចាំអំពីការប្រជុំបែបនោះទេ ហើយលោកចាំថា តើ ឌុច ពេលនោះទៅចូលរួម ហើយគាត់បានឲ្យបង្គាប់ដូច្នេះ គឺការបង្គាប់ថា ឲ្យលុតជង្គង់ ហើយវាយកញ្ចឹងក រួចអារ-ក តើលោកនៅ ចាំទេ?

**ឆ៖** បាទ, ខ្ញុំសូមជម្រាប គឺខ្ញុំនៅចាំ។ មុននឹងយកទៅសម្លាប់នឹងគេណែនាំឲ្យអ្នកទោសលុតជង្គង់ ហើយចាំឲ្យវ៉ៃ វ៉ៃហើយបានអារ-ក ព្រោះវ៉ៃមិនទាន់ងាប់ទេ ទាល់តែអារ-កទៀតបានងាប់ ។

**ស៖** ខ្ញុំបានយល់យ៉ាងច្បាស់នៅចំណុចនេះក៏បាននិយាយថ្ងៃនេះដែរ ។ ប៉ុន្តែ សំណួរខ្ញុំគឺសួរច្បាស់ណាស់ ថាតើការណែនាំនោះបានផ្តល់ការណែនាំឲ្យលោកដូច្នោះដែរឬទេ? ដូចដែលខ្ញុំបាននិយាយអម្បាញ់មិញ? ដោយសារតែនៅពេលនោះយើងឃើញមាន ឌុច ទៅចូលរួមនៅក្នុងការប្រជុំនោះ? តើលោកយល់សំណួរខ្ញុំដែរឬទេ?

**ឆ៖** បាទ, ខ្ញុំយល់សំណួរនោះ ។ មុននឹងធ្វើដូចខ្ញុំបានជម្រាបអ៊ីចឹង គេណែនាំហើយ បានគេឲ្យធ្វើរបៀបម៉េចៗ ធ្វើតាមគេ ។

**ស៖** លោកអាចជម្រាបថា តើលោកចង់ឆ្លើយសំណួរខ្ញុំដែរឬទេ? ប៉ុន្តែ ខ្ញុំសុំនិយាយចុងក្រោយ តើជនជាប់ចោទនេះ បានផ្តល់ការណែនាំទៅដល់លោកអំពីវិធីសាស្ត្រនៃការសម្លាប់ដែរឬទេ?

**ឆ៖** បាទ, យុទ្ធវិធីនេះគឺ តាហ៊ី ជាអ្នកណែនាំពួកខ្ញុំទាំងអស់គ្នា។

**ស៖** អ៊ីចឹងបានន័យថា ហ៊ី មិនមែន ឌុច នោះទេ? តើ ឌុច នោះបានបង្គាប់លោកដែរឬទេ? ឬក៏ផ្តល់ការណែនាំទៅដល់លោកដែរឬទេ ចំពោះបញ្ហានេះ?

[១៦:១៥:០០]

**ឆ៖** ខ្ញុំសូមជម្រាបថា សេចក្តីណែនាំនេះ តាហ៊ី អ្នកណែនាំ តែសេចក្តីសម្រេចការណែនាំនេះចេញពីតាឌុច បាន តាហ៊ី ណែនាំបាន ។

**ស៖** គឺឯកសារដដែល គឺឯកសារ D49 នៅក្នុងទំព័រលេខ៨ គេសួរលោកដូចតទៅ៖

តើលោកបានចូលរួមក្នុងការសម្លាប់ដែរឬទេ? ហើយលោកបានឆ្លើយដូច្នេះថា ហើយគេបានសួរទៅលោក ប្រសិនបើក្រុមលោកចូលរួមក្នុងការសម្លាប់ តើនរណាគេជាអ្នកសម្លាប់ លោកបាននិយាយថា វាអាស្រ័យទៅលើ ហ៊ី ហើយគាត់ផ្តល់ការបញ្ជានៅពេលយើងទៅតាមដើងឯក។ ហើយ ឌុច ក៏បាន

ទៅជាមួយដែរ ហើយគាត់បានសួរខ្ញុំ តើលោកផ្តាច់ការ ឬមិនផ្តាច់ការ? ហើយខ្ញុំបាននិយាយថា ខ្ញុំផ្តាច់ការ ។ ហើយប្រសិនបើខ្ញុំមិននិយាយថា ផ្តាច់ការនោះទេ ដាច់ខាត ឬមិនដាច់ខាត ប្រសិនបើខ្ញុំមិននិយាយ ដាច់ខាតទេ គឺគាត់នឹងគិតថាខ្ញុំនឹងប្រឆាំងគាត់ ហើយគឺគាត់បញ្ជាឲ្យខ្ញុំសម្លាប់អ្នកទោស ។

**ស៖** តើលោកចាំទៅសំណួរនេះដែរឬទេ? ហើយលោកចាំទៅលើចម្លើយដែលលោកបានឆ្លើយដូច្នេះដែរឬទេ?

**ឆ៖** បាទ, ខ្ញុំចាំ ចាំត្រង់ថា ការសម្លាប់ហ្នឹង គឺពេលដែលគាត់ទៅហ្នឹង គឺច្រើនណាស់ ដែលដឹកយកទៅហ្នឹង វាប់រយនាក់។ អ៊ីចឹង អាការសម្លាប់ហ្នឹង ពេលចុងបំផុតហើយ វាជិតភ្លឺហើយ ខ្ញុំមើលក៏មិនទាន់ដែរ ។ ប៉ុន្តែ អង្គុយនៅកន្លែងមាត់រណ្តៅហ្នឹង គឺឃើញច្បាស់ជាអ្នកដឹកនាំរបស់ខ្ញុំហើយ។ តែខ្ញុំថាប្រហែលជា តាឌុច តែពេលនេះខ្ញុំបង្ខំអាការប្រញាប់ប្រញាល់មួយទៀត គេបញ្ជាមក គឺខ្ញុំធ្វើការវ៉ៃ បើគេថា គេហៅទៅសួរថា មិត្តឯងដាច់ខាត ឬមិនដាច់ខាត? ខ្ញុំថាដាច់ខាតបង។ បើកាលណាមិនថាដាច់ខាត គឺមិនបានទេ ព្រោះយើងតែមិនដាច់ខាតយើងប្រឆាំងជាមួយគាត់ ហ្នឹងអាយុខ្លីហើយ ។ ពេលនោះ គឺខ្ញុំ អត់បានមើលថា អ្នកណាជានរណាទេ ព្រោះពេលជិតភ្លឺហ្នឹង ពេលជិតបង្ហើយហ្នឹង គឺគេមកទាំង តាហ៊ី អីមករណ្តៅហ្នឹង ។ ដល់ហើយខ្ញុំវ៉ៃមួយអ៊ីចឹងទៅ ដែលចុងបំផុតហ្នឹង ហើយខ្ញុំបោះដៃឲ្យគេខ្ញុំទៅវិញ ហើយ ព្រោះខ្ញុំអ្នកកាន់បញ្ជីហ្នឹង។ បញ្ជីឈ្មោះដើម្បីយកមកឲ្យទូទាត់ ឲ្យ បងធី ទូទាត់ឈ្មោះវិញ ។

**ស៖** តើជនជាប់ចោទបានបញ្ជាលោកឲ្យសម្លាប់នរណាម្នាក់ នៅក្នុងពេលមួយចំនួនច្រើនដែរឬទេ ឬក៏គាត់បញ្ជាលោកឲ្យសម្លាប់មនុស្សតែម្តង តែប៉ុណ្ណោះ?

[១៦:១៨:៣៥]

**ឆ៖** បាទ, ខ្ញុំសូមជម្រាបថា ពេលដែលដឹង គឺខ្ញុំមិនដឹងថា វាច្រឡំជាមួយនឹងគាត់ហ្នឹង ហើយនឹងជាមួយតា ហ៊ី ហ្នឹង ដូចខ្ញុំជម្រាបថាវាជិតភ្លឺហើយ រួតរះនឹងទៅវិញ ដល់អ៊ីចឹងមិនដឹងជា តាហ៊ី ឬមួយគាត់ ពេលសម្លាប់ហ្នឹង បានខ្ញុំវ៉ៃមួយទៅ ហើយបោះដៃឲ្យគេទៅ ។

**ស៖** ប្រហែលយើងអាចសុំឲ្យ ឌុច ក្រោកឈរឡើង តើលោកស្គាល់បុគ្គលនៅទីនេះដែលកំពុងឈរនៅក្នុងសវនាការនៅទីនេះដែរទេលោក ហ៊ឹម ហ៊ុយ?

**ឆ៖** បាទ, ខ្ញុំស្គាល់ ។

**ស៖** តើគាត់ជានរណាគេដែរ?

**ឆ៖** បាទ, គាត់គឺជាមេរបស់ខ្ញុំ ។

**ស៖** តើគាត់គឺជាបុគ្គលដែលនៅជិតមាត់រណ្ដៅជាមួយលោកនៅព្រលឹមៗនោះដែរឬទេ ហើយគាត់បង្គាប់បញ្ជាលោកឲ្យធ្វើការសម្លាប់នោះដែរឬទេ?

**ឆ៖** ដូចខ្ញុំជម្រាបអ៊ីចឹង ព្រោះពេលនុ៎ងពេលប្រចុចញ៉ុចប្រញាប់រូតបើកឡានចេញមកវិញ ព្រោះពេលភ្លឺខ្លាចគេដឹង បែកការណ៍ ព្រោះម៉ោងចូលម៉ោងបី ម៉ោងអីហើយ ម៉ោងបីជាងជិតបួនហើយ ។ អ៊ីចឹងប្រញាប់ប្រញាល់ព្រួសប្រាស់ៗឲ្យពួកអ្នកនៅហ្នឹងរូតកប់រូតអីទៅ ។ តែក៏មិនដឹងថា គាត់ឬក៏បង ហ៊ា ព្រោះគាត់ទៅកន្លែងហ្នឹង តាហ៊ា គាត់ទៅអង្គុយរណ្ដៅហ្នឹងដែរ ។

**ស៖** ជនជាប់ចោទអាចអង្គុយចុះ ហើយគាត់នឹងស្នើសុំឲ្យផ្ដល់យោបល់នៅពេលក្រោយ ។ បន្ទាប់ពីការបែកភ្នំពេញ តើលោកបានធ្វើការងារអ្វី តើលោកជួបបញ្ហាចំពោះខ្លួនលោកដែរឬទេ?

**ឆ៖** បាទ, ខ្ញុំសូមជម្រាបថា ពេលបែកភ្នំពេញហ្នឹង គឺពួក តាឌុច ពួកអី តាហ៊ា ហ្នឹងទៅប្រមូលពួក ខ្ញុំនៅឯស្រែហ្នឹង ហើយព្រៃសខាងពួក បងហ៊ុយ រត់ទៅព្រៃទាំងអស់គ្នា ។ ហើយទៅដល់ព្រៃនៅបានមួយខែ មួយខែជាង ដល់ពេលនោះគឺខ្ញុំបបួល តាហ៊ា រត់មកផ្ទះវិញ ។ គាត់អត់មក សួរថាបងឯងកុំនៅធ្វើបដិវត្តន៍ជាមួយគេវីវរឈ្មោះទៅគេសម្លាប់យើងចោលទៀត។ ហេ៎អញអត់ទៅទេ ខ្ញុំថាខ្ញុំអត់ដឹងទេ អ៊ីចឹង បានខ្ញុំនាំទ័ព ទាំងនារីអីនាំគ្នារត់បណ្ដោយ ។

**ស៖** តើគេចាប់លោកនៅក្នុងឆ្នាំ១៩៨៣ដែរឬទេ? បើសិនគេចាប់មែននោះដោយសារមូលហេតុអ្វី?

[១៦:២២:១២]

**ឆ៖** បាទ, ខ្ញុំសូមជម្រាបថា កាលក្នុងឆ្នាំ១៩៨៣ហ្នឹង គឺបានចាប់ខ្លួនខ្ញុំ ។ គេចោទខ្ញុំថាខ្ញុំមេគុកទួលស្លែង ។

**ស៖** ថាតើគេឃុំខ្លួនលោក ឬគេដាក់ទណ្ឌកម្មលោកផ្ដន្ទាទោសលោកដែរឬទេ មានអ្វីកើតឡើងនៅពេលដែលគេចាប់លោកនោះ?

**ឆ៖** បាទ, ខ្ញុំ ចាប់ខ្ញុំដាក់គុកហ្នឹង ក៏ខ្ញុំអត់រត់ដែរ ខ្ញុំនៅហ្នឹងរហូត ។ ដល់ហើយបានប៉ុន្មានខែបានគេយកខ្ញុំឲ្យទៅធ្វើស្រូវនៅព្រំដែនវៀតណាមនោះ។ ធ្វើស្រូវលីបាវស្រូវលីអីហ្នឹងរហូត គេអត់មានធ្វើបាបធ្វើអីទេ រហូតបានគេឲ្យ ដប់ខែបានឲ្យខ្ញុំមកផ្ទះវិញ ។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

ខ្ញុំពុំមានសំណួរបន្ថែមចំពោះសាក្សីរូបនេះទេ សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

ដំណើរការសវនាការស្តាប់សក្ខីកម្មចម្លើយសាក្សីឈ្មោះ ហ៊ីម ហ៊ុយ ដោយអង្គជំនុំជម្រះឃើញថា ថ្ងៃនេះរហូតដល់ម៉ោងបួនម្ភៃនាទី គឺលើសម៉ោងកំណត់ផង ហើយដោយសារការស្តាប់សក្ខីកម្មសាក្សីរូបនេះនៅមិនទាន់ចប់ទេ ។ អរគុណលោក ហ៊ីម ហ៊ុយ អង្គជំនុំជម្រះក៏យល់ពីបញ្ហាលោកមានការលំបាកប្រឈមក្នុងការឆ្លើយនឹងសំណួរផ្សេងៗជាច្រើន ។ ហើយរឿងហេតុនេះកើតឡើងច្រើនឆ្នាំហើយ ការចងចាំរបស់លោកក៏មានកម្រិត ។ ប៉ុន្តែ ការស្តាប់សក្ខីកម្មរបស់លោកមិនទាន់ចប់ទេ។ អ៊ីចឹងអង្គជំនុំជម្រះនឹងអញ្ជើញលោកចូលមកផ្តល់សក្ខីកម្មជាបន្តនៅថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០០៩ ចាប់ពីម៉ោងប្រាំបួនព្រឹកទៅ ។ ហើយតាមគណនាពេលវេលាប្រហែលជាលោកត្រូវមកផ្តល់សក្ខីកម្មប្រហែលជាមួយថ្ងៃទៀត គឺថ្ងៃទី២០ ឬក៏មិនដល់មួយថ្ងៃទេ ហើយប្រហែលជានឹងចប់ហើយ លោកយល់ទេ?

**លោក ហ៊ីម ហ៊ុយ៖**

បាទ ខ្ញុំយល់លោក ។

**ប្រធានអង្គជំនុំ៖**

ឥឡូវនេះ អង្គជំនុំជម្រះប្រកាសផ្អាកសម្រាប់ដំណើរការសវនាការពិភាក្សាដេញដោលថ្ងៃនេះត្រឹមនេះ ។ ហើយអង្គសវនាការលើកទៅបន្តនៅព្រឹកថ្ងៃច័ន្ទ ទី២០ ខែកក្កដា ឆ្នាំ២០០៩ ចាប់វេលាម៉ោងប្រាំបួន ។ មន្ត្រីតុលាការនាំលោក ហ៊ីម ហ៊ុយ ទៅជួបផ្នែកទាក់ទងជាមួយនឹងខាងអង្គភាពគាំពារសាក្សីនិងអ្នកជំនាញដើម្បីសម្រួលជូនគាត់ទៅរកកន្លែងសម្រាក ឬក៏លំនៅដ្ឋានរបស់គាត់ ដោយប្រាប់ឲ្យគាត់នាំ លោក ហ៊ីម ហ៊ុយ ត្រឡប់មកកាន់សាលសវនាការវិញនៅថ្ងៃច័ន្ទ តាមពេលវេលាដែលបានកំណត់រួចហើយ ។ អនុរក្សមន្ទីរឃុំឃាំងនាំជនជាប់ចោទ ទៅកាន់មន្ទីរឃុំឃាំងវិញ ហើយឲ្យនាំគាត់មកកាន់សាលសវនាការនៅព្រឹកថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០០៩ ៕

*[សវនាការផ្អាកនៅម៉ោង ១៦:២៦នាទី]*